# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: កញ្ញា **លី សុខណា**

កញ្ញា **ហុង និផាវត្តី**

ណែនាំដោយ

លោកស្រី **ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ
# ជាសាធារណៈលើកដំបូងរបស់
# កំពង់ផែស្វយ័តភ្នំពេញ

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ កញ្ញា **លី សុខណា**

កញ្ញា **ហុង និផាវត្តី**

ណែនាំដោយ

លោកស្រី **ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **លី សុខណា** និង **ហុង និដាវត្តី** ជានិស្សិតថ្នាក់បរិញ្ញាបត្រគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី១៩ ក្រុម A4B1 ឆ្នាំសិក្សា ២០២៣-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- **លោកឪពុក** និង **អ្នកម្តាយ** ដែលបានចិញ្ចឹមបីបាច់ ថែរក្សាកូនគ្រប់ៗរូប និងខិតខំជំនះរាល់ឧបសគ្គគ្រប់សព្វបែបយ៉ាង។ លើសពីនេះទៅទៀត លោកទាំងពីរបាន អប់រំទូន្មាន ប្រៀនប្រដៅ ជួយឧបត្ថម្ភ ផ្គត់ផ្គង់ ទៅលើការលូតលាស់របស់កូន ព្រមទាំងជួយគាំទ្រលើកទឹកចិត្ត ទាំងកម្លាំងកាយ និងកម្លាំងចិត្ត។
- **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រីសាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកការិយាល័យស្រាវជ្រាវ និងការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំប្រឹងប្រែងបំពេញនូវកាតព្វកិច្ច ផ្តល់ជាចំណេះដឹង ចែករំលែកបទពិសោធន៍ និងជួញសម្របសម្រួលដល់ដំណើរការសិក្សារបស់និស្សិតគ្រប់រូបឲ្យមានភាពរលូន និងទទួលបានជោគជ័យគ្រប់ៗគ្នា។
- លោកស្រី **ហេង ច័ន្ទបូលីន** ដែលបានណែនាំយើងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ដោយបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន និងផ្តល់ដំបូន្មាន ដើម្បីឲ្យយើងខ្ញុំអាចបញ្ចប់ការសរសេរដោយជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមលំឱនកាយ ថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណដល់លោកអ្នកទាំងអស់ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពមាំមួន ព្រមទាំងប្រកបការងារគ្រប់បែបយ៉ាងទទួលបានជោគជ័យ ជានិច្ចនិរន្តរ៍។

# អារម្ភកថា

វិស័យមូលបត្រជា វិស័យមួយដែលជួយក្នុងការប្រមូលនូវមូលធនពីបណ្ដាសាធារណៈជន ហើយក៏បានជួយពង្រឹងប្រព័ន្ធហិរញ្ញវត្ថុទាំងមូលរបស់ប្រទេសកម្ពុជា ឱ្យកាន់តែមានប្រសិទ្ធភាព និងជម្រុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ រហូតមកដល់បច្ចុប្បន្ននេះ ផ្សារមូលបត្រកម្ពុជា បានដំណើរការជាងមួយទសវត្សរ៍មកហើយ និងបានទាក់ទាញវិនិយោគិនជាតិ និងអន្តរជាតិជាច្រើន ក្នុងនោះផងដែរ កំពង់ផែស្វយ័តភ្នំពេញ ក៏មានវត្តមានក្នុងនាមជាស្ថាប័នបោះផ្សាយលក់មូលបត្រកម្មសិទ្ធិក្នុងព្រះរាជាណាចក្រកម្ពុជា និងបានរួមចំណែកក្នុងការអភិវឌ្ឍវិស័យមូលបត្រ ក៏ដូចជាសេដ្ឋកិច្ចជាតិ និងបានធ្វើការផ្សព្វផ្សាយឱ្យសាធារណជនបានស្គាល់ និងយល់ដឹងបន្ថែមពីវិស័យនេះ។

ដោយមើលឃើញពីគុណតម្លៃនៃមូលបត្រកម្មសិទ្ធនៅប្រទេសកម្ពុជា ទើបយើងខ្ញុំជានិស្សិតត្រៀមនឹងបញ្ចប់ការសិក្សា និងមានឱកាសបានសរសេរសារណា មានគោលបំណងក្នុងការស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ស្ថាប័ននេះ សម្រាប់ធ្វើជាសារណាស្រាវជ្រាវបញ្ចប់ការសិក្សា និងសម្រាប់រក្សាទុកជាឯកសារព័ត៌មានដល់សិស្សប្អូនជំនាន់ក្រោយ។ ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីពង្រឹង និងពង្រីកចំណេះដឹងបន្ថែមទាក់ទងនឹងវិស័យមូលបត្រ និងជាស្ពានមួយជួយផ្សព្វផ្សាយនូវដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិដល់បណ្ដាក្រុមហ៊ុន/សហគ្រាស និងមិត្តអ្នកអានទាំងអស់។

យើងខ្ញុំជឿជាក់ថា សារណាបញ្ចប់ការសិក្សានេះនៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះបីយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាមិត្តអ្នកអានទាំងអស់ ពិតជាមានការអធ្យាស្រ័យរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំសូមទទួលយកមតិរិះគន់ក្នុងន័យស្ថាបនា កែលំអដោយក្ដីសោមនស្សរីករាយ ដើម្បីទុកជាបទពិសោធន៍ សម្រាប់ការស្រាវជ្រាវក្រោយៗឲ្យកាន់តែមានលក្ខណៈប្រសើរឡើងថែមមួយកម្រិតទៀត។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណដល់មិត្តអ្នកអាន និងសូមឲ្យអ្នកទាំងអស់គ្នាទទួលជោគជ័យក្នុងគ្រប់ភារកិច្ច មានសុខភាពល្អ និងប្រើប្រាស់សារណាស្រាវជ្រាវនេះ ឲ្យមានប្រសិទ្ធភាពដើម្បីចូលរួមអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅប្រទេសកម្ពុជាឲ្យមានភាពរីកចម្រើនតទៅមុខ។

# មាតិកា

បញ្ជីអក្សរកាត់ ......vi

បញ្ជីតារាង ......vii

បញ្ជីរូបភាព ......ix

បញ្ជីក្រាហ្វិក ...... x

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ......១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...... ២

៣. គោលបំណងនៃការស្រាវជ្រាវ ...... ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ...... ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ...... ៣

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ...... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ......៤

## ជំពូកទី១

## រំលឹកទ្រឹស្តី

១.១. ទីផ្សារមូលបត្រ ......៦

១.១.១. ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ឬទីផ្សារភាគហ៊ុន ......៦

១.១.២. និយមន័យទីផ្សារមូលបត្រ ...... ៧

១.១.៣. មុខងារទីផ្សារមូលបត្រ ......៨

១.១.៣.១. ការបង្កើតទុន ......៨

១.១.៣.២. សន្ទនីយភាព ......៨

១.២. ប្រភេទនៃទីផ្សារមូលបត្រ ......៨

១.២.១. ទីផ្សារដំបូង (Primary market) ......៨

១.២.១.១. ទីផ្សារគោល ......៩

១.២.១.២. ទីផ្សារកំណើន ........ ៩
១.២.២. ទីផ្សារបន្ទាប់ (Secondary market) ........ ១០
១.៣. ប្រភេទមូលបត្រ ........ ១០
១.៣.១. មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន ........ ១១
១.៣.១.១. ភាគហ៊ុនធម្មតា (Common stock) ........ ១១
១.៣.១.២. ភាគហ៊ុនបុរិមា (Preferred stock) ........ ១១
១.៣.២. មូលបត្របំណុល ........ ១២
១.៣.៣. ឧបករណ៍និស្សន្ទ ឬដេរីវ៉េទីវ ........ ១២
១.៤. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រកម្ពុជា ........ ១២
១.៤.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក) ........ ១២
១.៤.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ១២
១.៤.៣. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ........ ១៣
១.៤.៤. ក្រុមហ៊ុនមូលបត្រ ........ ១៤
១.៤.៥. វិនិយោគិនមូលបត្រ ........ ១៥
១.៤.៦. តួអង្គចូលរួមដទៃទៀត ........ ១៥
១.៥. ការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ........ ១៧
១.៥.១. និយមន័យការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ........ ១៧
១.៥.២. ដំណាក់កាលទាំង១២នៃការធ្វើ IPO ........ ១៧

## ជំពូកទី២

## ស្ថានភាពទូទៅនៃ កំពង់ផែស្វយ័តភ្នំពេញ

២.១. ប្រវត្តិនៃកំពង់ផែស្វយ័តភ្នំពេញ ........ ២១
២.២. លក្ខណៈធុរកិច្ចរបស់កំពង់ផែស្វយ័តភ្នំពេញ ........ ២២
២.៣. ទស្សនវិស័យ និងបេសកកម្មរបស់កំពង់ផែស្វយ័តភ្នំពេញ ........ ២៤

២.៣.១. ទស្សនវិស័យ......២៤
២.៣.២. បេសកកម្ម......២៤
២.៥. រចនាសម្ព័ន្ធរបស់កំពង់ផែស្វយ័តភ្នំពេញ......២៥
២.៦. ក្រុមប្រឹក្សាភិបាល......២៥
២.៧. តួនាទី និងការទទួលខុសត្រូវនៃនាយកដ្ឋាន......២៧
២.៨. ស្ថានភាពហរិញ្ញវត្ថុរបស់កំពង់ផែស្វយ័តភ្នំពេញ......២៨
២.៨.១. ទ្រព្យសកម្ម បំណុល និងមូលធនសរុប......២៨
២.៨.២. ចំណូលសរុប ចំណាយសរុប និងចំណេញសុទ្ធ......២៩
២.២. យុទ្ធសាស្ត្រអាជីវកម្ម និងផែនការអនាគត......៣២
២.២.១. ផែនការយុទ្ធសាស្ត្របច្ចុប្បន្ន......៣២
២.២.២. ផែនការយុទ្ធសាស្ត្រអនាគត......៣២

## ជំពូកទី៣
## ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់កំពង់ផែស្វយ័តភ្នំពេញ

៣.១. ព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការបោះផ្សាយ......៣៦
៣.១.១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុនធានាទិញមូលបត្រ......៣៦
៣.១.២. ព័ត៌មានស្ដីពីក្រុមហ៊ុនគណនេយ្យជំនាញ និងសវនកម្មឯករាជ្យ......៣៨
៣.១.៣. ព័ត៌មានស្ដីពីក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ និងអ្នកវាយតម្លៃឯករាជ្យ......៣៩
៣.១.៤. មេធាវី......៤០
៣.២. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់......៤១
៣.២.១. ចំនួនមូលបត្រកម្មសិទ្ធិ......៤២
៣.២.២. លក្ខខណ្ឌនៃសំណើលក់......៤២
៣.២.៣. ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើរលក់......៤២

៣.៣. លក្ខខណ្ឌនៃការបែងចែក និងនីតិវិធីនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម.....................................៤៣
៣.៣.១. ដំណើរការធ្វើប៊ុកបៀលឌីង និងដំណើរការធ្វើបរិវិសកម្ម ....................................... ៤៨
៣.៣.១.១. ដំណើរការធ្វើប៊ុកបៀលឌីង ........................................................................ ៤៨
៣.៣.១.២. ដំណើរការធ្វើបរិវិសកម្ម............................................................................ ៤៩
៣.៣.១.៣. ការធ្វើបរិវិសកម្ម ..................................................................................... ៤៩
៣.៤. រចនាសម្ព័ន្ធនៃមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ......................................................... ៥០
៣.៤.១. ភាគរយនៃផាប់ប្លិកហ្លូត (Public Floats) និងឡុកអាប់ (lock-up) ..................................... ៥០
៣.៥. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងពាក់ព័ន្ធនឹង ចំណាយការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក ............................................................... ៥១
៣.៥.១. ចំណាយសរុបពាក់ព័ន្ធនឹងការធានាទិញមូលបត្រ ........................................................... ៥១
៣.៥.២. ចំណាយពាក់ព័ន្ធនឹងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ផ.ម.ក........................................ ៥១
៣.៥.៣. ចំណាយពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក ................................................ ៥១
៣.៥.៤. ចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ............................................៥២
៣.៥.៥. ការចំណាយផ្សេងៗ ........................................................................................... ៥២
៣.៦. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ............ ៥២
៣.៧. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ.................................................................................... ៥៤
៣.៧.១. គម្រោងវិនិយោគ ............................................................................................. ៥៤
៣.៧.២. ព័ត៌មានស្តីអំពីកត្តាហានិភ័យ.................................................................................. ៥៥
៣.៨. រចនាសម្ព័ន្ធភាគហ៊ុនិក.................................................................................................. ៥៦
៣.៨.១. សិទ្ធិរបស់ភាគហ៊ុនិក ..........................................................................................៥៧
៣.៨.១.១. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" .........................................៥៧
៣.៨.១.២. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" ......................................... ៥៨
៣.៨.១.៣. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ" .......................................... ៥៨
៣.៨.១.៤. សិទ្ធិផ្សេងៗទៀតរបស់ភាគហ៊ុនិក ..................................................................... ៥៩

៣.៨.២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត ..... ៥៩
៣.៨.៣. មហាសន្និបាតភាគហ៊ុន ..... ៦០
៣.៨.៣.១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុន និងការបោះឆ្នោត ..... ៦០
៣.៨.៣.២. ព័ត៌មានមហាសន្និបាតភាគហ៊ុន ..... ៦១
៣.៨.៤. ការបែងចែកភាគលាភ ..... ៦១
៣.៨.៤.១. គោលនយោបាយភាគលាភ ..... ៦១
៣.៨.៤.២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល៣ (បី) ឆ្នាំចុងក្រោយ ..... ៦៣
៣.៩. ទិដ្ឋភាពទូទៅនៃការជួញដូរមុលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ ..... ៦៣
៣.៩.១. មូលធនូបនីយកម្មទីផ្សារ ..... ៦៣
៣.៩.២. ទំហំជួញដូរ (ភាគហ៊ុន) ..... ៦៥
៣.៩.៣. ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) ..... ៦៦
៣.៩.៤. តម្លៃជួញដូរ (លានរៀល) ..... ៦៧
៣.៩.៥. តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) ..... ៦៨

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..... ៧០
២. អនុសាសន៍ ..... ៧១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ន.ម.ក. | ៖ | និយ័តករមូលបត្រកម្ពុជា |
| ផ.ម.ក. | ៖ | ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| គ.ម.ក. | ៖ | គណៈកម្មាការមូលបត្រកម្ពុជា |
| ក.ស.ភ. | ៖ | កំពង់ផែស្វយ័តភ្នំពេញ |
| OE | ៖ | Organized Exchange |
| OCT | ៖ | Over the Counter |
| CSX | ៖ | Cambodia Securities Exchange (ផ្សារមូលបត្រកម្ពុជា) |
| IPO | ៖ | Initial Public Offering (ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង) |

# បញ្ជីតារាង

តារាង២.១៖ បញ្ជីឈ្មោះសមាសភាពក្រុមប្រឹក្សាភិបាល ....... ២៥
តារាង២.២៖ តារាងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ. ....... ២៩
តារាង២.៣៖ លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ភ. ....... ៣០
តារាង៣.១៖ ព័ត៌មានលម្អិតពីក្រុមហ៊ុនគណនេយ្យជំនាញ ....... ៣៨
តារាង៣.២៖ ព័ត៌មានលម្អិតពីសវនករឯករាជ្យ ....... ៣៩
តារាង៣.៣៖ ព័ត៌មានលម្អិតពីក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ ....... ៣៩
តារាង ៣.៤៖ ព័ត៌មានលម្អិតពីអ្នកវាយតម្លៃឯករាជ្យ ....... ៤០
តារាង៣.៥៖ ព័ត៌មានលម្អិតពីមេធាវី ....... ៤០
តារាង៣.៦៖ ចំនួនមូលបត្រកម្មសិទ្ធិ ....... ៤២
តារាង៣.៧៖ លក្ខខណ្ឌនៃសំណើលក់ ....... ៤២
តារាង៣.៨៖ ព័ត៌មានលម្អិតពីការធ្វើប៊ិកបៀលឌីង ....... ៤៨
តារាង៣.៩៖ ព័ត៌មានលម្អិតពីការធ្វើបរិវិសកម្ម ....... ៤៩
តារាង៣.១០៖ ព័ត៌មានលម្អិតពីផាប់ប្លិកហ្លួត និងឡុកអាប់ ....... ៥០
តារាង៣.១១៖ ព័ត៌មានលម្អិតពីឡុកអាប់ ....... ៥១
តារាង៣.១២៖ ព័ត៌មានលម្អិតពីសាច់ប្រាក់សុទ្ធពីការបោះផ្សាយ ....... ៥៣
តារាង ៣.១៣៖ ផែនការបែងចែកមូលបត្រកម្មសិទ្ធិ ....... ៥៤
តារាង ៣.១៤៖ ព័ត៌មានលម្អិតពភាគហ៊ុនិកទូទៅ ....... ៥៦
តារាង ៣.១៥៖ ព័ត៌មានលម្អិតពីភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនយោជិត ....... ៥៦
តារាង ៣.១៦៖ ព័ត៌មានលម្អិតពីមហាសន្និបាតភាគហ៊ុន ....... ៦១
តារាង ៣.១៧៖ ព័ត៌មានលម្អិតពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ....... ៦៣
តារាង ៣.១៨៖ ព័ត៌មានលម្អិតពីមូលធនូបនីយកម្មទីផ្សារ ....... ៦៤
តារាង ៣.១៩៖ ព័ត៌មានលម្អិតពីទំហំជួញដូររបស់ ក.ស.ភ ....... ៦៥
តារាង ៣.២០៖ ព័ត៌មានលម្អិតនៃទំហំជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣ ....... ៦៦

តារាង ៣.២១៖ តម្លៃជួញដូររបស់ ក.ស.ភ. ឆ្នាំ២០២៣.................................................................. ៦៧
តារាង ៣.២២៖ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣........................................... ៦៨

# បញ្ជីរូបភាព

រូបភាព ២.១៖ រចនាសម្ព័ន្ធចាត់តាំងរបស់កំពង់ផែស្វយ័តភ្នំពេញ......................................................២៥
រូបភាព ២.២៖ ក្រុមប្រឹក្សាភិបាល ........................................................................................២៦

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១៖ ស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ ឆ្នាំ២០២៣......២៩
ក្រាហ្វិកទី២៖ ប្រភពចំណូលសម្រាប់ឆ្នាំ២០២៣ របស់ ក.ស.ភ. ......៣០
ក្រាហ្វិកទី៣៖ ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២៣ របស់ ក.ស.ភ. ......៣១
ក្រាហ្វិកទី៤៖ អត្រាកំណើនចំណូលនិងចំណេញរបស់ ក.ស.ភ. ......៣១
ក្រាហ្វិកទី៥៖ ព័ត៌មានលម្អិតនៃមូលធនបូនីយកម្មទីផ្សាររបស់ ក.ស.ភ. ......៦៤
ក្រាហ្វិកទី៦៖ ទំហំនៃការជួញដូរភាគហ៊ុនរបស់ ក.ស.ភ. ឆ្នាំ២០២៣ ......៦៦
ក្រាហ្វិកទី៧៖ ទំហំនៃការជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ.ឆ្នាំ២០២៣ ......៦៦
ក្រាហ្វិកទី៨៖ តម្លៃជួញដូររបស់ ក.ស.ភ.ឆ្នាំ២០២៣ ......៦៧
ក្រាហ្វិកទី៩៖ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ.ឆ្នាំ២០២៣ ......៦៨

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាត្រូវបានគេរាប់ចូលជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដែលកំពុងតែខិតខំអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ដើម្បីបម្លែងខ្លួនឲ្យក្លាយជាប្រទេសអភិវឌ្ឍន៍នាពេលអនាគត។ ប៉ុន្មានទសវត្សចុងក្រោយនេះ ប្រទេសកម្ពុជា ត្រូវបានគេកត់សម្គាល់ឃើញថាមានភាពរីកចម្រើនជឿនលឿន លើវិស័យហិរញ្ញវត្ថុដែលជាវិស័យមួយយ៉ាងសំខាន់នៅក្នុងដង្ហើមសេដ្ឋកិច្ចជាតិ។

ប្រទេសកម្ពុជាបានសង្កេតឃើញ នូវឥទ្ធិពលនៃវិស័យមូលបត្រ ក្នុងការរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជាកម្លាំងចលករមួយដ៏សំខាន់ ក្នុងការលើកកម្ពស់វិស័យហិរញ្ញវត្ថុជាតិ ចាប់តាំងពីឆ្នាំ ២០០១ កម្ពុជា បានចាប់ផ្តើមជំរុញលើកិច្ចដំណើរការបង្កើតផ្សារមូលបត្រកម្ពុជា ដើម្បីជាមធ្យោបាយគាំទ្រដល់វិស័យហិរញ្ញវត្ថុ ក្នុងដំណើរការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា។ ជាក់ស្តែងនៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ផ្សារមូលបត្រកម្ពុជា ត្រូវបានដាក់សម្ពោធឲ្យដំណើរការជាផ្លូវការ ដោយមានតួនាទីជាប្រព័ន្ធដែលផ្តល់ជាមធ្យោបាយនៃការធ្វើសំណើរទិញ លក់ ឬផ្ទេរមូលបត្រ។ លើសពីនេះ ផ្សារមូលបត្រកម្ពុជា ក៏ជាប្រព័ន្ធមួយជួយកៀរគរមូលធនពីបណ្តាសាធារណៈជន ឬវិនិយោគិន ដើម្បីផ្តល់ជាប្រភពហិរញ្ញប្បទានសម្រាប់ ក្រុមហ៊ុន សហគ្រាស ខ្នាតធំ តូច និងមធ្យម ដែលកំពុងមានវត្តមាន និងបន្តសកម្មភាពអាជីវកម្មរបស់ខ្លួននៅប្រទេសកម្ពុជា។ ក្រុមហ៊ុនដែលបានចុះបញ្ជីមិនត្រឹមតែមានលទ្ធភាព ទទួលបាននូវហិរញ្ញប្បទានរយៈពេលវែងប៉ុណ្ណោះទេ តែថែមទាំងទទួលបាននូវការលើកទឹកចិត្តផ្នែកពន្ធដារពីរាជរដ្ឋាភិបាល រួមទាំងជួយបង្កើនកិត្តិនាម និងកេរ្តិ៍ឈ្មោះរបស់ខ្លួននៅលើទីផ្សារជាតិ អន្តរជាតិ និងទទួលបានការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់វិនិយោគិន ក៏ដូចជា សាធារណៈជនផងដែរ។

យោងទៅតាមទិន្នន័យរបស់ទីផ្សារមូលបត្រកម្ពុជាសម្រាប់ឆ្នាំ២០២៤នេះ ក្រុមហ៊ុនដែលបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិមានចំនួន ១១ ក្រុមហ៊ុន ក្នុងនោះផងដែរនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ជាស្ថាប័នមួយដែលបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[1] វត្តមានរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ក្នុងផ្សារមូលបត្រកម្ពុជា គឺជាកតាលីករមួយដែលបានជំរុញ និងលើកកម្ពស់ដល់ភាពរីកចម្រើននៃវិស័យមូលបត្រដោយជួយបង្កើននូវភាពជឿជាក់ និងធ្វើជាភាពជាគម្រូដល់ស្ថាប័ន ក៏ដូចជាក្រុមហ៊ុនដែលមានបំណងចូលរួមជាមួយផ្សារមូលបត្រកម្ពុជា ដើម្បីពង្រីកនូវវិសាលភាពអាជីវកម្មរបស់ខ្លួន។

[1] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២៤)

ដោយមើលឃើញពីសក្តានុពល និងភាពវិជ្ជមាននៃការរីកចម្រើនយ៉ាងខ្លាំង របស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) មកទល់បច្ចុប្បន្ននេះ ទើបធ្វើឲ្យក្រុមយើងខ្ញុំមានចំណាប់អារម្មណ៏យ៉ាងខ្លាំងក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សាលើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ស្ថាប័នមួយនេះឡើង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងសង្កេតឃើញថាសន្ទុះនៃការចូលរួម និង ការយល់ដឹងពីការជួញដូរមូលបត្រនៅប្រទេសកម្ពុជា គឺមានកម្រិតទាបនៅឡើយ ពីសំណាក់វិនិយោគិនជាតិ និងអន្តរជាតិ។ លើសពីនេះផងដែរ សហគ្រាសអាជីវកម្មមួយចំនួនក៏ពុំទាន់បានត្រៀមខ្លួនបានសមស្រប និងមានភាពស្ទាក់ស្ទើរ ក្នុងការចូលរួមក្នុងផ្សារមូលបត្រកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ផ្សារមូលបត្រកម្ពុជា នៅតែឈរលើគោលជំហរដ៏មោះមុតរបស់ខ្លួនក្នុងការផ្តល់ភាពជឿជាក់ និងសច្ចៈធម៌ដល់សាធារណៈជន និងសហគ្រាសអាជីវកម្មទាំងអស់។ ជាក់ស្តែងក្នុងឆ្នាំ២០១៥ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ក៏បានបង្ហាញពីឆន្ទៈនៃការគាំទ្រ និងការជឿជាក់លើវិស័យមូលបត្រនៅកម្ពុជា ដោយបានចូលរួមអភិវឌ្ឍន៍ និងជំរុញវិស័យនេះឲ្យមានការរីកចម្រើន តាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងរបស់ខ្លួន។ ដោយសង្កេតឃើញពីគុណតម្លៃនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ទើបក្រុមយើងខ្ញុំសម្រេចធ្វើការសិក្សា ដោយផ្តោតទៅលើចំណុចសំខាន់ៗ ខាងក្រោមនេះ៖

- តើស្ថានភាពទូទៅរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) មានលក្ខណៈដូចម្តេច?
- តើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) ប្រព្រឹត្តិទៅយ៉ាងដូចម្តេច?
- តើទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) នៅក្នុងផ្សារមូលបត្រកម្ពុជា មានលក្ខណៈដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ "**ការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)**" គឺមានគោលបំណងចង់សិក្សាស្វែងយល់បន្ថែម ពីដំណើរការ និងនីតិវិធីដែលកំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) បានអនុវត្តឡើងក្នុងអំឡុងពេលបោះផ្សាយមូលបត្ររបស់ខ្លួនជាសាធារណៈ មានដូចជា៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)
- ស្វែងយល់ពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.)

- ស្វែងយល់ពីទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) នៅក្នុងផ្សារមូលបត្រកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ មូលបត្រកម្មសិទ្ធិទទួលបានការយកចិត្តទុកដាក់ និងស្ថិតក្នុងការចាប់អារម្មណ៍ពីសំណាក់ក្រុមហ៊ុន/សហគ្រាស និងវិនិយោគិននានា ទាំងក្នុងប្រទេស និងក្រៅប្រទេស។ មិនត្រឹមតែប៉ុណ្ណោះ ចំណេះដឹងអំពីមូលបត្រកម្មសិទ្ធិ ទាក់ទងការបោះផ្សាយលក់ និងការជួញដូរ ក៏ត្រូវបានផ្សព្វផ្សាយទូលំទូលាយជាងមុនផងដែរ។ ហេតុនេះការធ្វើសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ គឺផ្តោតសំខាន់ទៅលើតែ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញតែប៉ុណ្ណោះ។ ចំណែកឯទិន្នន័យនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័តភ្នំពេញ ក្រុមយើងខ្ញុំនឹងធ្វើការសិក្សាដែលផ្តោតលើទិន្នន័យនៅត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤ ក្នុងឆ្នាំ ២០២៣។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

បើពិនិត្យមើលទៅលើសារៈសំខាន់នៃការសិក្សាស្រាវជ្រាវអំពីប្រធានបទដែលទាក់ទងទៅនឹង ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញ នៅកម្ពុជា គឺមានសារៈសំខាន់ និងបានផ្តល់ជាផលប្រយោជន៍ ដូចខាងក្រោម ៖

- យល់ដឹងពីដំណាក់កាលនីមួយៗ ដែលទាក់ទងនឹងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ នៅទីផ្សារមូលបត្រ ដើម្បីជាជំនួយដល់សិស្ស និស្សិតគ្រប់ជំនាន់ និងអ្នកសិក្សាស្រាវជ្រាវ ដែលមានបំណងចង់ស្វែងយល់បន្ថែមទៅលើវិស័យនេះ។
- ទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីទូទៅ ដែលធ្លាប់បានសិក្សាពីមុនមក។
- ផ្តល់ជាឯកសារ និងចំណេះដឹងសម្រាប់ក្រុមហ៊ុន/សហគ្រាស និងសាធារណៈជនទូទៅដែលមានចំណាប់អារម្មណ៍ និងចង់ស្វែងយល់អំពីការទទួលបានហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សម្រាប់ការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺមានទម្រង់ជាប្រភេទសារណា ដោយក្រុមយើងខ្ញុំនឹងប្រើវិធីសាស្ត្រ ក្នុងការពិពណ៌នាដោយការសរសេររៀបរាប់អំពី ទ្រឹស្តី ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិ យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងទិដ្ឋភាពនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័តភ្នំពេញ នៅក្នុងទីផ្សារមូលបត្រកម្ពុជា។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់ក្នុងការ

សិក្សាស្រាវជ្រាវមួយនេះ ក្រុមយើងខ្ញុំបានប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ (ទិន្នន័យដែលមានស្រាប់) ដែលទាក់ទងនឹងប្រធានបទ និងប្រភពឯកសារមួយចំនួនដែលបានមកពីៈ

- ច្បាប់ បទបញ្ញាតិ អនុក្រឹតនានា ដែលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងការចុះបញ្ជីមូលបត្រជាដើម។
- ឯកសារផ្តល់ព័ត៌មានរបស់កំពង់ផែស្វយ័តភ្នំពេញ
- ឯកសារតាមប្រព័ន្ធអ៊ីនធឺណិត តាមរយៈគេហទំព័រផ្លូវការរបស់ កំពង់ផែស្វយ័តភ្នំពេញ គេហទំព័រនិយ័តករមូលបត្រកម្ពុជា និងគេហទំព័រផ្សារមូលបត្រកម្ពុជា។
- ការស្រាវជ្រាវនៅបណ្ណាល័យ គំរូសារណារបស់សិស្សច្បង ជាដើមដែលមានខ្លឹមសារសំខាន់ៗមួយចំនួនក្នុងការបំពេញបន្ថែមលើសារណាយើងខ្ញុំ។
- ទិន្នន័យ និងព័ត៌មានដែលបានដកស្រង់ចេញពីគេហទំព័រក្នុងស្រុក និងអន្តរជាតិ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះត្រូវបានបែងចែកជា ៣ជំពូកសំខាន់ៗ ដូចជាៈ

- **សេចក្តីផ្តើមៈ**
  បង្ហាញអំពី លំនាំបញ្ហា ចំណោទបញ្ហា គោលបំណង ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី ១ៈ រំលឹកទ្រឹស្តី**
  នៅក្នុងជំពូកនេះនឹងបង្ហាញពីការរំលឹកទ្រឹស្តីទូទៅដូចជា ទីផ្សារមូលបត្រកម្ពុជា ប្រភេទនៃទីផ្សារមូលបត្រ ប្រភេទមូលបត្រ តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ និង យន្តការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ។
- **ជំពូកទី ២ៈ ស្ថានភាពទូទៅនៃកំពង់ផែស្វយ័តភ្នំពេញ**
  នៅក្នុងជំពូកនេះនិយាយអំពី ប្រវត្តិរបស់កំពង់ផែស្វយ័តភ្នំពេញ រចនាសម្ព័ន្ធ លក្ខណៈធុរៈកិច្ច ស្ថានភាពហិរញ្ញវត្ថុ យុទ្ធសាស្ត្រអាជីវកម្ម និងផែនការអនាគតរបស់កំពង់ផែស្វយ័តភ្នំពេញ។
- **ជំពូកទី ៣ៈ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់កំពង់ផែស្វយ័តភ្នំពេញ**
  នៅក្នុងជំពូកនេះនិយាយអំពី ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុន ព័ត៌មានពាក់ព័ន្ធនិងការបោះផ្សាយ លក្ខខណ្ឌ និង ដំណើរការនៃការធ្វើប៊ុកបៀលឌីង និងបរិសកម្ម ការបែងចែក

ភាគលាភ និងទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ ក្នុងផ្សារមូលបត្រកម្ពុជា។

- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**



# ជំពូកទី១
# រំលឹកទ្រឹស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ទីផ្សារមូលបត្រ

### ១.១.១. ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ឬទីផ្សារភាគហ៊ុន

ទីផ្សារភាគហ៊ុនមានប្រវត្តិក្នុងការកកើតឡើងមុនដំបូងនៅលើទឹកដីអឺរ៉ុប ចាប់តាំងពីដើមសតវត្សរ៍ទី ១៧ នៅទីក្រុងអាំស្ទែដាំ (Amsterdam) នៃសាធារណៈរដ្ឋហូឡង់ ដោយអ្នកជំនួញពាណិជ្ជកម្ម។ គេបានឃើញទីផ្សារភាគហ៊ុនដំបូងរបស់ខ្លួនលេចឡើងនៅដើមទសវត្សរ៍ឆ្នាំ ១៦០០។[2] មូលហេតុដែលធ្វើឲ្យមានការធ្វើទីផ្សារភាគហ៊ុន គឺដោយសារតែមានការចាប់ផ្តើមចេះបង្កើតសហគ្រាសធំៗ និងប្រកបអាជីវកម្មខ្នាតធំដែលត្រូវការដើមទុនច្រើន ប៉ុន្តែពួកគេបែរជាជួបនឹងបញ្ហាខ្វះទុនពង្រីកសហគ្រាស និងអាជីវកម្មរបស់ខ្លួន។ ដូច្នេះពួកគេក៏ចាប់ផ្តើមមានគំនិតបើកឲ្យមានការសន្សំដើមទុនរួម ដោយមានរបៀបផ្សេងៗគ្នា ហើយពួកគេបានផ្តល់ឱ្យអាជីវកម្មនូវដើមទុន ក៏ដូចជាអាចឱ្យអ្នកវិនិយោគិនតូចៗជាច្រើនវិនិយោគទ្រព្យសម្បត្តិរបស់ពួកគេដោយក្លាយជាម្ចាស់ ឬវិនិយោគិននៅក្នុងសាជីវកម្មធំៗទាំងនោះ។

បន្ទាប់មក ការផ្លាស់ប្តូរភាគហ៊ុនទំនើបបានលេចឡើងនៅពេលក្រោយក្នុងសម័យនេះនៅទីក្រុងឡុងដ៍ និងញូវយ៉ក។ នៅឆ្នាំ ១៦០២ ក្រុមហ៊ុនហូឡង់ឥណ្ឌាបូព៌ា (The Dutch East India Company) បានបង្កើតផ្សារហ៊ុនអាំស្ទែដាំ (Amsterdam) ដោយបង្កើតដោយការចេញមូលបត្របំណុលដល់អ្នកវិនិយោគសាធារណៈទូទៅ។ ផ្សារហ៊ុនទីក្រុងឡុងដ៍ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៧៧៣។ ការជួញដូរដំបូងបានធ្វើឡើងនៅឯផ្ទះកាហ្វេរបស់លោក ចូណាថាន (Jonathan) ជាកន្លែងដែលឈ្មួញកណ្តាល និងឈ្មួញផ្សេងៗទៀតជួបប្រជុំគ្នាដើម្បីទិញ និងលក់ភាគហ៊ុន។[3]

ចំណែកឯ ផ្សារហ៊ុនញូវយ៉ក ឬ NYSE (The New York Stock Exchange) ត្រូវបានបង្កើតឡើងនៅ Wall Street ក្នុងទីក្រុងញូវយ៉កក្នុងឆ្នាំ ១៧៩២ ដោយដំបូងឡើយគ្រាន់តែធ្វើការជួញដូរនូវមូលបត្របំណុលរដ្ឋាភិបាលមួយចំនួននៅក្រោមដើមឈើអុកមួយនៅ Wall Street មុនពេលរីកលូតលាស់យ៉ាងឆាប់រហ័សក្នុងរយៈពេលជាច្រើនទសវត្សរ៍ជាបន្តបន្ទាប់។[4] ផ្សារហ៊ុនបានណែនាំបទប្បញ្ញត្តិ និងរចនាសម្ព័ន្ធសម្រាប់ការទិញលក់ និងជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនសាធារណៈ។ ទីផ្សារភាគហ៊ុនបានចាប់ផ្តើមជាមួយនឹងការចេញភាគ

---

[2] https://www.strike.money/stock-market/history (ចូលទស្សនាថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០២៤)

[3] https://www.strike.money/stock-market/history (ចូលទស្សនាថ្ងៃទី ០៨ខែ មិថុនា ឆ្នាំ ២០២៤)

[4] https://www.investopedia.com/articles/07/stock-exchange-history.asp (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

ហ៊ុនដោយក្រុមហ៊ុនសាធារណៈ។ នៅពេលដែលក្រុមហ៊ុនបានចាប់ផ្តើមលក់ភាគហ៊ុនកម្មសិទ្ធិទៅឱ្យវិនិយោគិន ប្រព័ន្ធរៀបចំត្រូវបានទាមទារដើម្បីទិញ លក់ និងជួញដូរឧបករណ៍ហិរញ្ញវត្ថុទាំងនេះ។ ទីក្រុងអាំស្ទែដាំ ទីក្រុងឡុងដ៍ និងញូវយ៉កបានក្លាយជាផ្ទះសម្រាប់ផ្សារហ៊ុនដំបូងគេមួយចំនួនដែលបង្កើតច្បាប់ស្តង់ដារ កាលវិភាគ និងទីតាំងដើម្បីប្រមូលផ្តុំអ្នកទិញ និងអ្នកលក់។ នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៧ កម្ពុជាក៏បានប្រកាសដាក់ឲ្យដំណើរការជាផ្លូវការ "គម្រោងបង្កើតទីផ្សារមូលបត្រនៅកម្ពុជា" ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។[5]

### ១.១.២. និយមន័យទីផ្សារមូលបត្រ

យោងតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន បានឲ្យនិយមន័យដល់ទីផ្សារមូលបត្រថា គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ ហើយវាត្រូវបានគេសំដៅទៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬការទិញ-លក់មូលបត្រ។[6] ឧបករណ៍ហិរញ្ញវត្ថុដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។

ម្យ៉ាងវិញទៀត ផ្សារមូលបត្រក៏ជាកន្លែងដែលមូលបត្រ ដូចជា ភាគហ៊ុន និងសញ្ញាបណ្ណត្រូវបានទិញ-លក់ ដោយវិនិយោគិនផ្សេងៗរួមមាន ជាតិ និងអន្តរជាតិ។

ទីផ្សារមូលបត្រ ក៏ជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់ សម្រាប់សេដ្ឋកិច្ចដែលគេតែងតែនិយាយថា ទីផ្សារមូលបត្រ គឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ទីផ្សារមូលបត្របានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិដូចជា៖

- ជួយជម្រុញឲ្យមហាជនបង្កើតនូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុង សេដ្ឋកិច្ច។
- ជាមធ្យោបាយមួយប្រមែប្រមូលកៀរគរនូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ជាឧបករណ៍មួយជួយសម្រួលដល់រដ្ឋាភិបាល ក្នុងការអនុវត្តនូវកម្មវិធីអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គម។
- ជាឧបករណ៍មួយ ដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។
- ជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។

[5] ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ៥៥

[6] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រកម/០១០៧/០២៨ ចុះថ្ងៃទី២៣ តុលា ២០០៧ សន្ទានុក្រម

- ជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ជួយបង្កើននូវទម្លាក់ការវិនិយោគ។[7]

### ១.១.៣ មុខងារទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច។ ទីផ្សារនេះជាប្រភពហិរញ្ញប្បទានថ្មីមួយ បន្ទាប់ពីប្រភពហិរញ្ញប្បទានផ្ទាល់ខ្លួន និងហិរញ្ញប្បទានតាមរយៈធនាគារ។ ទីផ្សារមូលបត្រមានមុខងារ និងតួនាទីសំខាន់ៗធំៗចំនួនពីរ ដូចជា៖

#### ១.១.៣.១ ការបង្កើតទុន

ទីផ្សារមូលបត្រ គឺជាកន្លែងប្រជុំទៅដោយវិនិយោគិនទាំងអស់ដែលមានទុន ដើម្បីវិនិយោគទៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណា ដែលស្វែងរកទុនដើម្បីបង្កើតមូលធន។ ការផ្តល់ទុននេះផងដែរ ធ្វើឱ្យកម្រិតសកម្មភាពវិនិយោគនៅក្នុងប្រទេសកើនឡើង ដែលវាអាចជួយបង្កើតនូវការងារថ្មីដល់ប្រជាជន ពោល គឺវាអាចផ្តល់ប្រាក់ចំណូលបន្ថែមក្នុងការជួយបង្កើនកម្រិតជីវភាពរបស់ប្រជាជនបានមួយកម្រិតទៀតក្នុងរូបភាពថ្មី។

#### ១.១.៣.២ សន្ទនីយភាព

សន្ទនីយភាពជាលទ្ធភាពក្នុងការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយៈការផ្តល់ជាទីកន្លែងជួញដូរដល់អ្នកទិញ និងអ្នកលក់ជួបគ្នា ដើម្បីធ្វើការព្រមព្រៀងទៅលើតម្លៃ និងធ្វើសកម្មភាពជួញដូរមូលបត្រ ដែលសកម្មភាពនេះគេហៅថា ការផ្តល់សន្ទនីយភាពក្នុងការទិញ និងលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រ។[8]

## ១.២ ប្រភេទនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវបានបែងចែកជា ពីរធំៗតាមចារិតលក្ខណៈគតិយុត្តនៃទីផ្សារ គឺ ទីផ្សារដំបូង និងទីផ្សារបន្ទាប់។

### ១.២.១ ទីផ្សារដំបូង ( Primary market )

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានបោះផ្សាយដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រលក់ទៅឲ្យសាធារណៈជន ដើម្បីទទួលបានហិរញ្ញប្បទាន ឬមូលធនយកទៅវិនិយោគក្នុងគោលបំណងពង្រីក

---

[7] https://khemsaritheducation.wordpress.com/2018/05/16/តើទីផ្សារមូលបត្រជាអ្វី/ (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

[8] បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ ទំព័រ ០៨

អាជីវកម្ម។ នៅក្នុងដំណាក់កាលនេះ ដើម្បីទិញមូលបត្រពីទីផ្សារដំបូង វិនិយោគិនត្រូវបញ្ជាទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយនៅក្នុងដំណាក់កាលប៊ុកបៀលឌីង (Book building) ឬការស្ទាប់ស្ទង់ថ្លៃ និង ការធ្វើបរិវិសកម្ម (subscription) ឬការចុះឈ្មោះទិញ។ រាល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា ត្រូវបានទទួលការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក)។[9] បន្ថែមពីនេះ លំហូរសាច់ប្រាក់នៅក្នុងទីផ្សារដំបូង គឺចេញពីវិនិយោគិន ទៅកាន់ក្រុមហ៊ុនបោះផ្សាយ ហើយវិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយនឹងក្លាយជាភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយនោះ។ បន្ទាប់មក វិនិយោគិនដែលកាន់កាប់មូលបត្រដំបូងអាចបន្តកាន់កាប់មូលបត្រនេះ ឬអាចលក់មូលបត្របន្តឲ្យទៅវិនិយោគិនដទៃទៀតនៅក្នុងទីផ្សារបន្ទាប់។

#### ១.២.១.១ ទីផ្សារគោល

ទីផ្សារគោល គឺជាផ្សារដំបូងបង្អស់ដែលត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជីរបស់ក្រុមហ៊ុនចុះបញ្ជីសក្ដានុពលដែលមានស្តង់ដារ និងទំហំធំ។ ទីផ្សារនេះនឹងអនុញ្ញាតឱ្យក្រុមហ៊ុននាំយកភាគហ៊ុនទាំងអស់ក្រោយការបោះផ្សាយ មកចុះបញ្ជីនិងជួញដូរនៅក្នុងប្រព័ន្ធរបស់ ផ.ម.ក.។ ម្យ៉ាងទៀត ក្រុមហ៊ុនដែលនៅក្នុងផ្សារគោលភាគច្រើនជាក្រុមហ៊ុនដែលល្អ មានឈ្មោះបោះសម្លេងរួចទៅហើយ។ ចំពោះក្រុមហ៊ុនដែលចូលទៅក្នុងទីផ្សារគោល ប្រាក់ចំណេញរបស់ក្រុមហ៊ុនមិនសូវជាច្រើននោះទេ ប៉ុន្តែលំនឹងនៃអាជីវកម្មរបស់ពួកគេមានស្ថេរភាពល្អ និងមានហានិភ័យតិចតួច។[10]

#### ១.២.១.២ ទីផ្សារកំណើន

ទីផ្សារកំណើន ជាកន្លែងសម្រាប់ឱ្យអាជីវកម្មធុនតូច-ធុនមធ្យមចុះបញ្ជី លក្ខខណ្ឌក្នុងការចុះបញ្ជីមានតិចជាងទីផ្សារគោល។ ក្រុមហ៊ុនដែលចុះបញ្ជីក្នុងទីផ្សារកំណើន ភាគច្រើនជាក្រុមហ៊ុនតូចៗ ក្រុមហ៊ុនធុនមធ្យម និងគ្មានលំនឹង ប៉ុន្តែទទួលបានប្រាក់ចំណេញច្រើន តែទន្ទឹមនឹងនោះក៏មានហានិភ័យខ្ពស់ផងដែរ។[11] រាជរដ្ឋាភិបាល
កម្ពុជា បានផ្តួចផ្តើមឡើង ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ពាន់ដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានដុល្លារផងដែរ។[12]

---

[9] ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា ទំព័រ ៩២

[10] https://bizkhmer.com/articles/59199 (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

[11] https://bizkhmer.com/articles/59199 (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

[12] ភ្នំពេញ ប៉ុស្តិ៍ | ផ្សារមូលបត្រកម្ពុជា គឺជាជម្រើសថ្មីនៃប្រភពទុនសម្រាប់ SME (postkhmer.com) (ចូលទស្សនាថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០២៤)

### ១.២.២ ទីផ្សារបន្ទាប់ ( Secondary market )

ទីផ្សារបន្ទាប់ គឺជាកន្លែងដែលមូលបត្រត្រូវបានជួញដូរបន្ត រវាងអ្នកទិញ និងអ្នកលក់ ដែលជាវិនិយោគិន មានន័យថាវិនិយោគិនដែលបានទិញមូលបត្ររួចក្នុងទីផ្សារដំបូង អាចលក់ចេញវិញបានទៅឲ្យវិនិយោគិនមួយផ្សេងទៀត។ ចំណែកឯប្រាក់ដែលបានមកពីសកម្មភាពជួញដូរលើទីផ្សារបន្ទាប់ គឺបានទៅលើអ្នកកាន់កាប់មូលបត្រ មិនមែនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រឡើយ ពោលគឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ មិនទទួលផលប្រយោជន៍សេដ្ឋកិច្ចពីការជួញដូរលើទីផ្សារបន្ទាប់ឡើយ។ ការជួញដូរនៅទីផ្សារបន្ទាប់ គឺធ្វើនៅផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)។ ផ.ម.ក. មានតួនាទីចម្បងក្នុងការផ្ដល់ទីកន្លែង និងប្រព័ន្ធជួញដូរ សម្រាប់វិនិយោគិនងាយស្រួលរកគ្នាឃើញ (អ្នកលក់និងអ្នកទិញ) ដើម្បីជួញដូរជាមួយគ្នា។ ទីផ្សារបន្ទាប់អាចមានប្រតិបត្តិការតាមរយៈ៖

- ទីផ្សារមូលបត្រ (Organized Exchange) ៖ សំដៅលើការជួញដូរមូលបត្រតាមរយៈទីផ្សារមូលបត្រដែលមានទីកន្លែងជួញដូរជាក់លាក់មួយ មានវិធានទីផ្សារ និងមានប្រព័ន្ធជួញដូរ ដើម្បីគ្រប់គ្រងដំណើរការជួញដូរ។
- ទីផ្សារក្រៅប្រព័ន្ធ (Over-the-Counter-OTC)៖ សំដៅលើការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ ដែលពុំមានទីកន្លែងជួញដូរជាក់លាក់ និងមិនផ្លូវការនោះទេ។ វិនិយោគិនអាចធ្វើការជួញដូរមូលបត្រដោយការចរចារតាមរយៈទូរសព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ។ ភាគច្រើននៃទីផ្សារនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ជាអ្នកដាក់នូវការកំណត់ថ្លៃទិញ-លក់មូលបត្រជូនអតិថិជន និងក្រុមហ៊ុនពាណិជ្ជករមូលបត្រដទៃទៀត។

ប៉ុន្តែបច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា មានតែផ្សារមូលបត្រ (Organized Exchange) ដែលដំណើរការ និងទីផ្សារក្រៅប្រព័ន្ធ (OTC) ពុំទាន់មាននោះទេ។[13]

## ១.៣ ប្រភេទមូលបត្រ

មូលបត្រ គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលកិច្ចសន្យានេះ បញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិ ឬម្ចាស់បំណុលលើក្រុមហ៊ុនមួយ ហើយក៏អាចធ្វើការជួញដូរមូលបត្រនេះបានដែរ។ មូលបត្រមាន ៣ ប្រភេទធំៗគឺ៖ មូលបត្រកម្មសិទ្ធិ ឬ(ភាគហ៊ុន) មូលបត្របំណុល និងឧបករណ៍និស្សន្ទ។[14]

---

[13] https://www.postkhmer.com/សេដ្ឋកិច្ច/ទីផ្សារដំបូង-និងទីផ្សារបន្ទាប់នៅក្នុងទីផ្សារមូលបត្រ (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

[14] https://economy.ams.com.kh/28431 (ចូលទស្សនាថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២៤)

## ១.៣.១ មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន

មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន សំដៅដល់ផលិតផលទ្រព្យកម្មសិទ្ធិ គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីកៀងគរមូលនិធិពីសាធារណៈជន។ ហើយវាក៏ត្រូវបានរួមបញ្ចូលទាំងភាគហ៊ុនរបស់ក្រុមហ៊ុន ដែលតំណាងឲ្យភាពជាម្ចាស់របស់វិនិយោគិន នៅក្នុងក្រុមហ៊ុននោះ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ និងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ។

ភាគហ៊ុនិក គឺជាម្ចាស់នៃអាជីវកម្ម ព្រមទាំងចូលរួមទទួលនូវការចែករំលែកភាពជោគជ័យ ឬ បរាជ័យនៃអាជីវកម្មរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជីជាធម្មតា ហើយគេអាចវាយតម្លៃបាន តាមរយៈភាគលាភដែលភាគហ៊ុនិក បានទទួល និងតាមរយៈថ្លៃភាគហ៊ុន ដែលបានដាក់ថ្លៃនៅលើទីផ្សារ។ ក្នុងនោះប្រភេទនៃមូលបត្រកម្មសិទ្ធិ មាន ២ ប្រភេទ ដូចជា៖

### ១.៣.១.១ ភាគហ៊ុនធម្មតា (Common Stock)

ភាគហ៊ុនធម្មតា គឺជាភាគហ៊ុនដែលមានការលើកទឹកចិត្ត ដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុន តាមរយៈភាគលាភ ដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មី របស់ក្រុមហ៊ុននៅពេលដែលក្រុមហ៊ុនសម្រេច ក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ ចំណុចខ្លាំងរបស់ភាគហ៊ុនធម្មតា គឺការផ្តល់ផលចំណេញរយៈពេលវែង មានសិទ្ធក្នុងការសម្រេចចិត្តក្នុងរឿងរ៉ាវផ្ទៃក្នុងក្រុមហ៊ុន។

### ១.៣.១.២ ភាគហ៊ុនបុរិមា (Preferred Stock)

ភាគហ៊ុនបុរិមាក៏ជាផ្នែកមួយនៃទ្រព្យកម្មសិទ្ធិផងដែរ។ ទោះបីជាយ៉ាងណា វាមានភាពខុសគ្នាបន្តិចបន្តួចរវាង ភាគហ៊ុនបុរិមា និងភាគហ៊ុនធម្មតា គឺអ្នកកាន់កាប់ភាគហ៊ុនបុរិមា នឹងមានសិទ្ធិទទួលបានមូលនិធិ ឬប្រាក់ចំណេញរបស់ក្រុមហ៊ុនមុនភាគហ៊ុនធម្មតា តែវាខុសត្រង់ថា គេមិនទទួលបាននូវសិទ្ធិក្នុងការសម្រេចលើរឿងរ៉ាវរបស់ក្រុមហ៊ុននោះទេ។ ម្ចាស់ភាគហ៊ុនបរិមានឹងទទួលបានភាគលាភ «ថេរ» ដោយយោងទៅតាមតម្លៃភាគហ៊ុនរបស់គេដែលគេមាន និងត្រូវទូទាត់ជារៀងរាល់ឆ្នាំ ដោយមិនថាក្រុមហ៊ុនខាត ឬចំនេញនោះទេ ខុសពីម្ចាស់ភាគហ៊ុនធម្មតា ដែលទទួលបានភាគលាភអាស្រ័យលើប្រាក់ចំនេញរបស់ក្រុមហ៊ុន។

ករណីដែលក្រុមហ៊ុនមានបញ្ហា ឬជាប់បំណុល ម្ចាស់ភាគហ៊ុនបុរិមាមានសិទ្ធិទាមទារខ្ពស់ជាងម្ចាស់ភាគហ៊ុនធម្មតា ចំពោះទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ក្រុមហ៊ុនក៏អាចទិញយកភាគហ៊ុនបុរិមាត្រលប់មកពីភាគហ៊ុនិកវិញបាន ក្នុងតម្លៃចរចាទីផ្សារមួយតាមការព្រមព្រៀងរវាងភាគីទាំងពីរ។

### ១.៣.២ មូលបត្របំណុល

សញ្ញាបណ្ណ ឬមូលបត្របំណុល ជាប្រភេទមូលបត្របំណុល ដែលតំណាងឱ្យកិច្ចសន្យាខ្ចីប្រាក់រវាងបុគ្គលបោះផ្សាយមូលបត្របំណុល (រួមមានសាជីវកម្ម សហគ្រាសរដ្ឋ ឬរាជរដ្ឋាភិបាល) និងវិនិយោគិន (ម្ចាស់មូលបត្របំណុល)។ តាមរយៈកិច្ចសន្យានេះ បុគ្គលបោះផ្សាយមូលបត្របំណុល មានកាតព្វកិច្ចបង់ឱ្យវិនិយោគិន នូវទឹកប្រាក់ជាក់លាក់មួយជាទៀងទាត់ដែលហៅថា "គូប៉ុង/Coupon" ឬ "ការប្រាក់" (លើកលែងសម្រាប់សញ្ញាបណ្ណគ្មានការប្រាក់) ព្រមទាំងបង់ប្រាក់ដើម នៅពេលដែលសញ្ញាបណ្ណនោះ ដល់កាលកំណត់សងដែលហៅថា "ឥណប្រតិទាន"។ ចំណែកឯ ការប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈនៅកម្ពុជា បានធ្វើឡើងនៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៧។

### ១.៣.៣ ឧបករណ៍និស្សន្ទ ឬដេរីវេទីវ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ សំដៅទៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើម ទៅឲ្យបុគ្គលណាមួយដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ច លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។[15]

## ១.៤ តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រកម្ពុជា

### ១.៤.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក)

និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង និងត្រួតពិនិត្យរាល់ប្រតិបត្តិការដែលកើតមានឡើងនៅក្នុងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ ដោយយោងតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០១២១/ ០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និយ័តករមូលបត្រកម្ពុជា ត្រូវបានប្តូរឈ្មោះពី គណៈកម្មការមូលបត្រកម្ពុជា។[16]

### ១.៤.២ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ

[15] ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ៣១

[16] គណៈកម្មការមូលបត្រកម្ពុជា សេចក្តីជូនដំណឹង លេខ០០៧/២១ គ.ម.ក./ស.ជ.ណ. ពីការផ្លាស់ប្តូរ ឈ្មោះរបស់ គណៈកម្មការមូលបត្រកម្ពុជា ទៅជា និយ័តករមូលបត្រកម្ពុជា ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១

"ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ស្របតាមកិច្ចព្រមព្រៀងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ កាន់កាប់ភាគហ៊ុនចំនួន ៤៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាបណ្ណ ជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។[17]

### ១.៤.៣ ក្រុមហ៊ុនបោះផ្សាយមូលបត្រ

ក្រុមហ៊ុនបោះផ្សាយមូលបត្រជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលស្នើសុំ ឬបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។[18] ក្រុមហ៊ុនបោះផ្សាយមូលបត្រ គឺជាតួអង្គយ៉ាងសំខាន់ក្នុងវិស័យមូលបត្រ ដែលមានភារកិច្ចក្នុងការបោះផ្សាយលក់មូលបត្រ ប្រសិនបើគ្មានក្រុមហ៊ុនបោះផ្សាយនោះទេ នោះក៏មិនមានមូលបត្រដាក់លក់លើទីផ្សារដែរ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ មានចំនួន ១១ ក្រុមហ៊ុនដូចជា៖

| | | |
|---|---|---|
| ១. | ក្រុមហ៊ុន ម៉េងលី ជេ. គួច អេឌ្យូខេសិន ម.ក | (MJQE) |
| ២. | ក្រុមហ៊ុន ខេម ជ្ជីអេសអេម ម.ក ("ខេម ជ្ជីអេសអេម") | (CGSM) |
| ៣. | ជេអេស លែន ភីអិលស៊ី | (JSL) |
| ៤. | ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក | (DBDE) |
| ៥. | ផេសចិក (ខេមបូឌា) ម.ក | (PEPC) |
| ៦. | ធនាគារ អេស៊ីលីដា ភីអិលស៊ី | (ABC) |
| ៧. | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | (PAS) |
| ៨. | រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សិត ម.ក | (PPSP) |
| ៩. | កំពង់ផែស្វយ័តភ្នំពេញ | (PPAP) |
| ១០. | ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី | (GTI) |
| ១១. | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | (PWSA) |

[17] ផ្សារមូលបត្រកម្ពុជា (ផមក) (csx.com.kh) (ចូលទស្សនាថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០២៤)

[18] https://www.serc.gov.kh/khmer/ (ចូលទស្សនាថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០២៤)

### ១.៤.៤ ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រសំដៅលើក្រុមហ៊ុន ដែលបម្រើសេវាកម្មក្នុងនាមជាអន្តរការី ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងវិនិយោគិន និងតួអង្គដទៃទៀតក្នុងទីផ្សារមូលបត្រ។ ក្រុមហ៊ុនមូលបត្រចែកចេញជា ៣ សំខាន់ៗ មានដូចជា៖

- **ក្រុមហ៊ុនធានាទិញមូលបត្រ:** ផ្តល់ជំនួយ និងប្រឹក្សាសំខាន់ក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការដាក់តម្លៃ កំណត់ទំហំទឹកប្រាក់ និងចំនួនមូលបត្រនៃសំណើបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់ជាសាធារណៈ និងអាចជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង ព្រមទាំងជួយវិនិយោគិនក្នុងការជួញដូរមូលបត្រដោយយកកម្រៃជើងសា។
- **ក្រុមហ៊ុនពាណិជ្ជករមូលបត្រ:** ជាក្រុមហ៊ុនដែលអាចជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង និងជួយវិនិយោគិនក្នុងការជួញដូរមូលបត្រដោយយកកម្រៃជើងសា។
- **ក្រុមហ៊ុនជើងសាមូលបត្រ:** ជាក្រុមហ៊ុនដែលទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួនដោយទទួលបាននូវកម្រៃជើងសារ។[19]

បច្ចុប្បន្ន ក្រុមហ៊ុនមូលបត្រ មានចំនួន ១១ ក្រុមហ៊ុន ដូចជា៖

១. ក្រុមហ៊ុនមូលបត្រ យាន់តា (ខេមបូឌា) ម.ក
២. អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា)ម.ក
៣. ក្រុមហ៊ុនមូលបត្រ កាណាឌីយ៉ា ឯ.ក.
៤. កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី
៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី
៦. ខេមបូឌា ស៊ីឃ្យូរីធី ម.ក
៧. ក្រុមហ៊ុនមូលបត្រ រ៉ូយ៉ាល់គ្រុប ម.ក
៨. ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក
៩. ខេមបូឌា-វៀតណាម ស៊ីឃ្យូរីធី ឯ.ក
១០. ភីភី លីង ស៊ីឃ្យូរីធី ឯ.ក
១១. ហ្គោលដេន ហ្វំឈឿន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី[20]

[19] ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ៧៤-៧៥

[20] និយ័តករមូលបត្រកម្ពុជា - ន.ម.ក. (serc.gov.kh) (ចូលទស្សនាថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ២០២៤)

### ១.៤.៥. វិនិយោគិនមូលបត្រ

វិនិយោគិន ជាបុគ្គលដ៏សំខាន់ចំពោះដំណើរការ ផ.ម.ក ដោយសារតែសន្ទុះនៃការជួញដូររបស់វិនិយោគិននឹងជះឥទ្ធិពលទៅលើថ្លៃមូលបត្ររបស់ក្រុមហ៊ុននៅលើទីផ្សារ។ នៅក្នុងវិស័យមូលបត្រ វិនិយោគិន សំដៅដល់សាធារណៈជនជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី (ន.ម.ក) មានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ។[21] វិនិយោគិន ត្រូវមានជំនួយពីក្រុមហ៊ុនមូលបត្រ ដើម្បីជួយសម្របសម្រួលដល់ដំណើរការជួញដូរមូលបត្ររបស់ខ្លួន។

### ១.៤.៦ តួអង្គចូលរួមដទៃទៀត

ដើម្បីឲ្យទីផ្សារមូលបត្រនៅកម្ពុជា អាចដំណើរការបានយ៉ាងរលូន ក៏មានការចូលរួមយ៉ាងសកម្មពីតួអង្គមួយចំនួនខាងក្រោមនេះផងដែរ តួអង្គទាំងនោះមានដូចជា៖

**(ក) ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់**: ក្រុមហ៊ុនមេធាវី ឬមេធាវីជាអ្នកផ្តល់ប្រឹក្សាយោបល់លើបញ្ហា ផ្លូវច្បាប់ទាំងអស់ដែលទាក់ទងទៅនឹងពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ជាពិសេសទៅលើការពិនិត្យលើការបំពេញកាតព្វកិច្ចតាម ច្បាប់របស់ក្រុមហ៊ុនដែលមានបំណងចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ ឯកសារផ្សេងៗឲ្យបានត្រឹមត្រូវតាមការតម្រូវរបស់ច្បាប់។

**(ខ) ក្រុមហ៊ុនផ្តល់សេវាសវនកម្ម**: ក្រុមហ៊ុនផ្តល់សេវាសវនកម្ម នឹងជួយក្រុមហ៊ុនបោះផ្សាយក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវក្នុងឯកសារផ្តល់ព័ត៌មាន របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀត។

**(គ) ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ**: ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យ ប្រសិនបើក្រុមហ៊ុនកាន់កាប់ទ្រព្យសម្បត្តិ ដីធ្លី ឬបរិក្ខារដែលត្រូវ វាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី។

**(ឃ) ភ្នាក់ងារបញ្ជិកាមូលបត្រ**: ជាភ្នាក់ងារដែលបានទទួលស្គាល់ពី ន.ម.ក. ដែលគ្រប់គ្រងនូវដំណើរការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រកត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រ និងធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។

[21] ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា ទំព័រទី ៧៨

**(ង) ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**: ជាភ្នាក់ងារដែលបានទទួលស្គាល់ពី ន.ម.ក. ដែលគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រអោយមានសង្គតិភាព ការផ្លាស់ប្តូរកម្មសិទ្ធិករ ការធ្វើរបាយការណ៍ ស្ថិតិ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងសកម្មភាពរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងការរៀបចំការងារពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិករមូលបត្រ ដូចជា ការជូនដំណឹងអំពីការបែងចែកភាគលាភ ការបង់ការប្រាក់ ជាដើម។ លើសពីនេះ ពួកគេក៏មានតួនាទីបញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនបោះផ្សាយ ទៅដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់មូលបត្រពាក់ព័ន្ធនឹង សេវារបស់ភ្នាក់ងារត្រូវចុះបញ្ជីផ្ទេរមូលបត្រ ។

**(ច) ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស**: ជាភ្នាក់ងារដែលបានទទួលស្គាល់ពី ន.ម.ក. ដែលមានតួនាទីគណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀតដែលត្រូវផ្តល់ឱ្យដល់កម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធ ក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ និង បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ទាំងនោះជូនទៅក្រុមហ៊ុនបោះផ្សាយ និងន.ម.ក. តាមការចាំបាច់។

**(ឆ) ភ្នាក់ងារទូទាត់សាច់ប្រាក់ទាក់ទងនឹងមូលបត្រ:** គឺជាភ្នាក់ងារដែលគ្រប់គ្រងគណនីសាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រប្រកបដោយសុវត្ថិភាព ដូចជា ការផ្ទេរ ឬការបង្វែរសាច់ប្រាក់ រវាងគូរភាគីជួញដូរ និងបំពេញប្រតិបត្តិការអោយដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ។

**(ជ) ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល:** សំដៅដល់បុគ្គលដែលទទួលបានការទទួលស្គាល់ពី ន.ម.ក ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល តាមដានការអនុវត្តលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះលក់ និងកិច្ចព្រមព្រៀងភ្នាក់ងារតំណាងម្ចាស់បំណុល និងដោះស្រាយការទាមទាររបស់ម្ចាស់មូលបត្របំណុល ធានាថាមូលបត្របំណុលដែលបានធ្វើបដិវត្ត ឬទូទាត់សងត្រូវធ្វើឡើងដោយអនុលោមតាមលក្ខខណ្ឌនៃមូលបត្របំណុលដែលបានបោះផ្សាយលក់។

**(ឈ) ភ្នាក់ងារវាយតម្លៃលទ្ធភាពសង:** សំដៅដល់ភ្នាក់ងារដែលវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ កម្រិតហានិភ័យឥណទាន របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ រៀបចំរបាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង និងអនុវត្តការងារដោយស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**(ញ) ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ:** សំដៅដល់ភ្នាក់ងារដែលទទួលបានការទទួលស្គាល់ពីអគ្គនាយកនៃ ន.ម.ក ដើម្បីផ្តល់សេវារក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ ដែលមានតួនាទីថែរក្សាសុវត្ថិភាពទ្រព្យរបស់អតិថិជន ដាក់បញ្ជាទិញ និងលក់មូលបត្រតាមការបញ្ជាពីអតិថិជន គ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការ

សាច់ប្រាក់ និងមូលបត្រ និងទ្រព្យដទៃទៀត ធ្វើការគណនាទ្រព្យសកម្មសុទ្ធ និងធ្វើការកត់ត្រាទ្រព្យរបស់អតិថិជន តាមតម្លៃទីផ្សារ ព្រមទាំងរាយការណ៍ជូនអតិថិជន។

**(ដ) ក្រុមហ៊ុនផ្តល់សេវាបកប្រែ:** ក្រុមហ៊ុនផ្តល់សេវាបកប្រែមានតួនាទីបកប្រែឯកសារពាក់ព័ន្ធនឹង IPO ឱ្យបានត្រឹមត្រូវតាមអត្ថន័យដើម។

## ១.៥. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

### ១.៥.១. និយមន័យការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងគឺ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

### ១.៥.២. យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូងតម្រូវអោយ ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធ គប្បីត្រូវស្វែងយល់អំពីដំណើរការនេះឲ្យបានច្បាស់លាស់ ដើម្បីសម្រួលដល់ដំណើរការបោះផ្សាយមូលបត្រ ឲ្យមានភាពរលូន និងទទួលបានជោគជ័យតាមការរំពឹងទុក។ និយ័តករមូលបត្រកម្ពុជា បានចេញនូវគោលការណ៍ណែនាំ ស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាលើកដំបូង ដែលមានដូចខាងក្រោមនេះ៖

**យន្តការទី១៖ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈជូនមកនិយ័តករមូលបត្រកម្ពុជា (ន.ម.ក)**

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមកនិយ័តករមូលបត្រកម្ពុជា (ន.ម.ក) ដែលលិខិតមានខ្លឹមសារសំខាន់ ៣ ចំណុចដូចខាងក្រោម៖

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

២. គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៣. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុក រួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវីឬក្រុមមេធាវីនិងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

**យន្តការទី២៖ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ**

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់មួយព្រោះថា ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាកម្មដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រណាមួយក្នុងចំណោមក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណពី ន.ម.ក។

**យន្តការទី៣៖ ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង**

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធមួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលស្គាល់ពី ន.ម.ក ដើម្បីចូលរួមក្នុងការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

**យន្តការទី៤៖ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់**

ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូងដែលរួមមាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

**យន្តការទី៥៖ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនមូលបត្រកម្ពុជា**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនមូលបត្រ ត្រូវធ្វើការរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**យន្តការទី៦៖ ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើរសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យ ដើម្បីស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទៅ ន.ម.ក ហើយ ន.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះ

ផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននិងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើរសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។

**យន្តការទី៧៖ ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើរសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគ មុននិងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**យន្តការទី៨៖ ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រត្រូវបញ្ជាក់ថា ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រមានន័យថាថ្លៃអាចត្រូវបញ្ចូលទៅក្នុង ប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

**យន្តការទី៩៖ ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក**

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនានានៃសំណើរលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន ន.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**យន្តការទី១០៖ ការធ្វើបរិវិសកម្មមូលបត្រ**

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើរលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួញពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រដោយអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងជំពូកទី ៣ និងទី៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**យន្តការទី១១៖ ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ**

ក្រុមហ៊ុនបោះផ្សាយដោយមានជំនួញពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃបរិវិសកម្មមូលបត្រនេះភ្លាមជូនមក ន.ម.ក។

**យន្តការទី១២៖ ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិទៅឲ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ អនុលោមតាមបទបញ្ញតិជាធរមាន។[22]

[22] គោលការណ៍ណែនាំ លេខ០០១ គ.ម.ក / គ.ណ.ន ស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូង ចុះថ្ងៃទី ០៨ ខែកញ្ញា ២០១១

# ជំពូកទី២
# ស្ថានភាពទូទៅនៃកំពង់ផែស្វយ័តភ្នំពេញ

# ជំពូកទី២
# ស្ថានភាពទូទៅនៃកំពង់ផែស្វយ័តភ្នំពេញ

## ២.១. ប្រវត្តិនៃកំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) គឺជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាកំពង់ផែកុងតឺន័រអន្តរជាតិធំជាងគេទីពីរនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក.ស.ភ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩០៥ ហើយបានក្លាយជាសហគ្រាសសាធារណៈដែលមានទម្រង់ជាក្រុមហ៊ុនរដ្ឋ នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ តាមរយៈអនុក្រឹត្យលេខ ៥១ អនក្រ.បក។ [23] មុនការបោះផ្សាយលក់មូលបត្រ ក.ស.ភ ជាសហគ្រាសដែលមានភាគហ៊ុនទាំងអស់កាន់កាប់ដោយរាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាតំណាង។ ក.ស.ភ គឺជាអង្គភាពស្វយ័ត ដែលដើរតួនាទីសំខាន់ពីរនៅក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ គឺអាជ្ញាធរផែ និងប្រតិបត្តិករផែ។

កំពង់ផែស្វយ័តភ្នំពេញ មានទីតាំងស្ថិតនៅកណ្ដាលរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដោយលាតសន្ធឹងតាមបណ្ដោយដងទន្លេសាប ចម្ងាយ ០២ គីឡូម៉ែត្រ ពីទន្លេចតុមុខ ដែលជាចំណុចប្រសព្វរវាងទន្លេសាប ទន្លេមេគង្គលើ ទន្លេមេគង្គក្រោម និងទន្លេបាសាក់។ កំពង់ផែនេះមានចម្ងាយ ៣៤៨,១ គីឡូម៉ែត្រ ពីចក្រ "គូទីវ" នៃប្រទេសវៀតណាម ដែលជាច្រកចេញចូលទៅសមុទ្រចិនភាគខាងត្បូង ដែលពីព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាម ត្រង់ចំណុចក្អមសំណនៃខេត្តកណ្ដាល និងចំណុចកោះរកានៃខេត្តព្រៃវែង មកកំពង់ផែស្វយ័តភ្នំពេញមានចម្ងាយ ១០២ គីឡូម៉ែត្រ។ សម្រាប់ការដឹកជញ្ជូនទំនិញ នាវាសមុទ្រធ្វើនាវាចរណ៍ចេញពីភ្នំពេញទៅសមុទ្រ តាមដងទន្លេមេគង្គ ដែលបានទទួលស្គាល់ថាជា ផ្លូវនាវាចរណ៍អន្តរជាតិ តាមសន្ធិសញ្ញា "Regulating Convention Maritime and Inland Navigation on the Mekong on the Approach to the Port of Saigon" ដែលចុះហត្ថលេខានៅទីក្រុងប៉ារីស ដោយប្រទេសឥណ្ឌូចិនទាំងបី (រួមមាន ប្រទេសកម្ពុជា វៀតណាម និងឡាវ) នៅថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៥៤ ហើយចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៥។

ចាប់ពីឆ្នាំ ១៩០៥ ដល់ ១៩៩៨ កំពង់ផែភ្នំពេញបានបន្តកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនដើម្បីបំពេញតម្រូវការរបស់សាធារណៈជនទូទៅ និងសម្រេចបាននូវសមិទ្ធផលជាច្រើនផងដែរ។ ជាក់ស្តែងបន្ទាប់ពី កំពង់ផែភ្នំពេញ បានបង្កើតឡើងដំបូងនៅឆ្នាំ ១៩០៥ ដោយមានចំណតផែបណ្ដែត ដែលមានប៉ង់តុងចំនួន ២គ្រឿង រួចមក នៅឆ្នាំ ១៩២៩ ប៉ង់តុងមួយគ្រឿងទៀតក៏បានសាងសង់ឡើងបន្ថែម។ បន្ទាប់មក ក្នុងឆ្នាំ ១៩៥២ និង ១៩៦០ ស្ពានផែជាបេតុងអាម៉េ ត្រូវបានសាងសង់ឡើង ក្នុងគោលបំណងផ្ដល់ភាពងាយស្រួលដល់ការដឹកជញ្ជូន ចេញ ចូល និងផ្ទុកទំនិញ របស់នាវាដែលមានចំណុះរហូតដល់ ២.៥០០ តោន។ បន្ទាប់ពីរបប

[23] ឯកសារច្បាប់និងបទប្បញ្ញត្តិ - https://www.moj.gov.kh/ (ចូលទស្សនាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤)

កម្ពុជាប្រជាធិបតេយ្យបានបញ្ចប់ កំពង់ផែស្វយ័តភ្នំពេញ ត្រូវបានដំណើរការឡើងវិញ ក្នុងទម្រង់ជាមណ្ឌលផែ និងផែក្នុងស្រុក របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដែលបានធ្វើការសាងសង់ផែបណ្តែត និងស្ពានផែថ្មឡើងវិញ និងបំពាក់នូវភ្លើងអគ្គិសនី ប្រព័ន្ធបង្ហូរទឹកស្អាតចូលនាវា និងជួសជុលខ្សែកុងរ៉ូយ៍អូសទំនិញ ដោយប្រើប្រាស់ប្រាក់កម្ចីពីធនាគារពិភពលោក និងជំនួយឥតសំណងពីរាជរដ្ឋាភិបាលនៃប្រទេសជប៉ុន។

បន្ទាប់ពីបានបង្កើតជាទម្រង់សហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ រួច នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០១ ផែបណ្តែត (ប៉ង់តុងទាំង២គ្រឿង) ត្រូវបានកែប្រែឱ្យទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍ សម្រាប់ទទួលនាវាដឹកអ្នកដំណើរ និងភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ និងសម្រាប់នាវាបរទេសឆ្លងកាត់ពីប្រទេសនានា។ ក.ស.ភ បានពង្រឹងអាជីវកម្មរបស់ខ្លួនដោយបានធ្វើការសហការ និងចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន មៀង លីហេង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ដោយ ក.ស.ភ ជាប្រតិបត្តិករផែ និងផ្តល់សេវាកម្មលើកដាក់ក្រោមដងយោង ចំណែកក្រុមហ៊ុន មៀង លីហេង ផ្តល់សេវាកម្មលើកដាក់ពីឃ្លាំងទៅមកទីលានផែ និងប្រតិបត្តិការឃ្លាំងស្តុកទំនិញ។ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ កំពង់ផែស្វយ័តភ្នំពេញ បានផ្ទេរប្រតិបត្តិការចម្បងរបស់ខ្លួនពីចំណតផែពហុបំណង TS៣ ទៅចំណតផែកុងតឺន័រ LM១៧ ដែលមានចម្ងាយ ៣០គីឡូម៉ែត្រពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ ០១។ ចំណតផែកុងតឺន័រ LM១៧ នេះត្រូវបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចំណតនេះត្រូវបានបំពាក់ដោយឧបករណ៍ និងគ្រឿងចក្រលើកដាក់ទំនិញថ្មីៗ ហើយប្រតិបត្តិការផែ ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការចំណតផែ TOS (Terminal Operation System) របស់ក្រុមហ៊ុន Phaeros Group BVBA (Phaeros)។

## ២.២. លក្ខណៈធុរកិច្ចរបស់កំពង់ផែស្វយ័តភ្នំពេញ

ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) កំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ដទៃទៀតដែលជាដំណើរការធុរកិច្ចរបស់ ក.ស.ភ។[24]

### ១) ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ

ក្នុងនាមជាប្រតិបត្តិករផែ ក.ស.ភ. មានភារកិច្ចបម្រើសេវាសំខាន់ៗរួមមាន៖

- ផ្តល់សេវាលើកដាក់ទំនិញ ការស្តុកទំនិញ ការប្រេកនិងផើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រ
- សម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស

[24] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រទី២ (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

- ផ្តល់សេវាកណ្ណធារកិច្ច នាំនាវាចេញ-ចូល
- ផ្តល់សេវាចំណតផែអ្នកដំណើរ និងទេសចរ TS១
- សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា។

## ២) ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ

ក្នុងនាមជាអាជ្ញាធរផែ ក.ស.ភ. មានតួនាទី៖

- ថែទាំផ្លូវនាវាចរណ៍ បំពាក់ឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញា សម្គាល់ទិសនាវាចរណ៍ រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្ម ក.ស.ភ.
- ចាត់វិធានការធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធវិស័យកំពង់ផែ និងការដឹកជញ្ជូននានាតាមផ្លូវទឹក។

## ៣) សេវាកម្ម/អាជីវកម្មផ្សេងទៀត

ជាមួយនឹងការផ្តល់សេវាកម្មស្នូលលើការងារប្រតិបត្តិការផែ និងអាជ្ញាធរផែ ក.ស.ភ. ក៏មានសេវាកម្មអាជីវកម្មបន្ទាប់បន្សំផ្សេងទៀត ដែលអាចបង្កើតឱ្យមានចំណូលបន្ថែមដូចជា៖

- សេវាកម្មបូមស្តារ៖ ក.ស.ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្តារចំនួន ២គ្រឿង សម្រាប់ផ្តល់សេវាកម្មបូមស្តារ ដើម្បីចាក់បំពេញខ្សាច់ជូនអតិថិជន
- សេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់៖ ក.ស.ភ ទទួលបានអាជ្ញាបណ្ណបូមស្តារប្រឡាយនាវាចរណ៍ និងធ្វើអាជីវកម្ម ខ្សាច់នៅទីតាំងចំនួន ២ ដោយអនុលោមតាមប្រកាសលេខ ០១ និង០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល
- សេវាកម្មវាស់ស្ទង់ និងបំពាក់ពោង៖ ក.ស.ភ.មានទទួលផ្តល់សេវាកម្មវាស់ស្ទង់ និងបំពាក់ពោងតាមតម្រូវការ របស់អតិថិជន
- សេវាកម្មថែទាំជួសជុលសំបកកុងតឺន័រ៖ ក.ស.ភ.មានទទួលផ្តល់សេវាកម្មថែទាំជួសជុល សំបកកុងតឺន័រ គ្រប់ប្រភេទទៅតាមតម្រូវការរបស់អតិថិជន
- ការជួលអចលនទ្រព្យ និងគ្រឿងចក្រផ្សេងៗ៖ ក្រៅពីការប្រើប្រាស់អចលនទ្រព្យ និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារអាជីវកម្ម និងប្រតិបត្តិការ អចលនទ្រព្យ និងគ្រឿងចក្រទាំងនោះក៏ត្រូវបានប្រើប្រាស់ និងចាត់ចែងសម្រាប់ការជួល ដើម្បីបង្កើនចំណូលបន្ថែមជូនដល់ ក.ស.ភ ផងដែរ។

### ៤) មណ្ឌលអាជីវកម្មផែ

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩[25] មណ្ឌលអាជីវកម្មរបស់ ក.ស.ភ មាន ប្រវែង ១៦៦ គីឡូម៉ែត្រ គិតចាប់ពីទន្លេបួនមុខ ទន្លេមេគង្គលើ ១០០គីឡូម៉ែត្រ ទន្លេមេគង្គក្រោម ៦០គីឡូម៉ែត្រ និងទន្លេសាប ៦គីឡូម៉ែត្រ។ អាជ្ញាធរ ក.ស.ភ. មានតួនាទីគ្រប់គ្រងចំណតផែឯកជននានានៅក្នុងមណ្ឌល អាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក.ស.ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បងចំនួន ៦ រួមមាន៖

១. ចំណតផែកុងតឺន័រ LM១៧

២. ចំណតផែពហុបំណង TS៣

៣. ចំណតផែរណបពហុបំណង UM២

៤. ចំណតអ្នកដំណើរ និងទេសចរ TS១

៥. ចំណតផែរណបពហុបំណង TS១១

៦. ចំណតផែរណបពហុបំណង LM២៦

## ២.៣. ទស្សនវិស័យ និងបេសកកម្ម របស់កំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) មានទស្សនវិស័យ និងបេសកកម្ម ដូចខាងក្រោម៖

### ២.៣.១. ទស្សនវិស័យ

ទស្សនវិស័យរបស់ ក. ស. ភ. គឺរក្សាភាពជាអ្នកគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេ មេគង្គ និង ដើរតួនាទីជាបណ្ដាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធិភាព សមត្ថភាព និងតម្លាភាព ដើម្បីភ្ជាប់ទំនាក់ ទំនងជាមួយដៃគូពាណិជ្ជកម្មក្រៅប្រទេស។

### ២.៣.២. បេសកកម្ម

បេសកកម្មរបស់ ក.ស.ភ. គឺគ្រប់គ្រង អភិវឌ្ឍ ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និង បម្រើសេវាកម្ម ចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀត ដើម្បីធានាឱ្យមាននិរន្តរភាព នៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីក ចម្រើនក្នុងសង្គមជាតិទាំងមូល។[26]

---

[25] អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩ ស្ដីពីការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ

[26] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ i (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

## ២.៤. រចនាសម្ព័ន្ធកំពង់ផែស្វយ័តភ្នំពេញ

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) មានរចនាសម្ព័ន្ធ ដូចក្នុងរូបភាពខាងក្រោម៖




រូបភាព២.១៖ រចនាសម្ព័ន្ធចាត់តាំងរបស់ កំពង់ផែស្វយ័តភ្នំពេញ

ប្រភព៖ របាយការណ៍ប្រចាំត្រីមាសទី៣របស់ ក.ស.ភ

## ២.៥. ក្រុមប្រឹក្សាភិបាល

យោងតាមរបាយការណ៍ប្រចាំត្រីមាសទី៣ របស់ ក.ស.ភ. សមាសភាពក្រុមប្រឹក្សាភិបាល មាន ៧រូបគឺ៖

តារាង២.១៖ បញ្ជីឈ្មោះសមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះ | មុខតំណែង | សញ្ជាតិ | តួនាទី |
|---|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បាវី | ប្រធានក្រុមប្រឹក្សាភិបាល | ខ្មែរ | ជាអគ្គនាយក ក.ស.ភ. |
| ២ | ឯកឧត្តម សួន រចនា | សមាជិក | ខ្មែរ | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន |
| ៣ | ឯកឧត្តម កែន សម្បត្តិ | សមាជិក | ខ្មែរ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ៤ | ឯកឧត្តម ប៉ែន សុវិជាតិ | សមាជិក | ខ្មែរ | តំណាងក្រសួងពាណិជ្ជកម្ម |
| ៥ | ឯកឧត្តម ហ៊្គី អានវ៉ានិថ | សមាជិក | ខ្មែរ | អភិបាលឯករាជ្យ |
| ៦ | អ្នកស្រី ប៉ុក ភក្តី | សមាជិក | ខ្មែរ | អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន |
| ៧ | លោក គង់ សុធា | សមាជិក | ខ្មែរ | តំណាងនិយោជិក ក.ស.ភ. |




រូបភាព២.២៖ ក្រុមប្រឹក្សាភិបាល

## ២.៦. តួនាទី និងការទទួលខុសត្រូវនៃនាយកដ្ឋាន

យោងតាមរចនាសម្ព័ន្ធរបស់ ក.ស.ភ. ស្ថាប័នត្រូវបានចែកចេញជា ១១ នាយកដ្ឋានដែលមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

i). **នាយកដ្ឋានសវនកម្មផ្ទៃក្នុង៖** ជាសេនាធិការផ្ទាល់ឱ្យអគ្គនាយក លើការងារសវនកម្ម និងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

ii). **នាយកដ្ឋានរដ្ឋបាល៖** ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល លើការងាររដ្ឋបាលលើការងារសន្តិសុខ/សណ្តាប់ធ្នាប់ និងការងារព័ត៌មានវិទ្យា រួមទាំងអនុវត្ត និងតាមដានការគោរពនូវបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ.។

iii). **នាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស៖** ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល លើការងារគ្រប់គ្រងធនធានមនុស្ស និងការងារបណ្តុះបណ្តាល ពិនិត្យ និងតាមដានការគោរពនូវបទបញ្ជាផ្ទៃក្នុង របស់ ក.ស.ភ. រួមទាំងគ្រប់គ្រងជីវប្រវត្តិ និងពិនិត្យរាល់សកម្មភាពការងាររបស់និយោជិត និងកម្មករ។

iv). **នាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ៖** ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ រួមទាំងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

v). **នាយកដ្ឋានវិស្វកម្ម៖** ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារបច្ចេកទេសរួមមាន ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយគ្រឿងចក្រ រួមទាំងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

vi). **នាយកដ្ឋានជលធារសាស្ត្រ៖** ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារជលធារសាស្ត្ររួមមានការងារវាស់ស្ទង់ ការងារបំពាក់ពោងសញ្ញា និងការងារបូមស្តារប្រឡាយ រួមទាំងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

vii). **នាយកដ្ឋានសេវាកម្មនាវាចរណ៍៖** ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារនាវាចរណ៍ ការងារកណ្ណធារ និងការងារ SHE រួមទាំងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

viii). **នាយកដ្ឋានមណ្ឌលអាជីវកម្មផែភ្នំពេញ/ផែក្នុងស្រុក៖** ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារមណ្ឌលផែ/ផែក្នុងស្រុក ការងារផែទេសចរណ៍ ការងារចំណតផែទន្លេបិទ និងការងារផែប្រេង/ហ្គាស រួមទាំងផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

ix). **នាយកដ្ឋានផែនការ/ទីផ្សារ៖** ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារផែនការស្ថិតិ ការងារទីផ្សារ ការងារតម្លៃ និងការងារសិក្សាស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី។

x). **នាយកដ្ឋានប្រតិបត្តិការផែចាស់ TS៣៖** ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែចាស់ TS៣ និងផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូប្រតិបត្តិការ។

xi). **នាយកដ្ឋានប្រតិបត្តិការផែថ្មី LM១៧៖** ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែកុងតឺន័រថ្មី LM១៧ និងផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូប្រតិបត្តិការ។

## ២.៧. ស្ថានភាពហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តភ្នំពេញ

សម្រាប់ការអនុវត្តក្នុងឆ្នាំ២០២៣ ចំណូលសរុបពីផលអាជីវកម្ម និងសេវាកម្មមានចំនួនសរុប ១៤២.០៣៥.៤៨០ ពាន់រៀល (៣៤.៥៥៨.៥១១ ដុល្លារអាមេរិក) សម្រេចបាន ៨១,៤១% នៃផែនការឆ្នាំ២០២៣ និងធៀបនឹងឆ្នាំ២០២២ ថយចុះចំនួន ៦.៧៨០.០៨៧ ពាន់រៀល (១.៨៥៣.៤២១ ដុល្លារអាមេរិក) ឬស្មើនឹង ៤,៥៦%។ ចំណែកប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ ឆ្នាំ២០២៣ មានចំនួនសរុប ៣៨.៦០៥.៩៦៦ ពាន់រៀល (៩.៣៩៣.១៧៩ ដុល្លារអាមេរិក) សម្រេចបាន ៥៧,៨៦% នៃផែនការឆ្នាំ២០២៣ និងធៀបនឹងឆ្នាំ២០២២ ថយចុះ ចំនួន ២០.៦៨៧.៧២៤ ពាន់រៀល (៥.១១៤.៦៩៧ ដុល្លារអាមេរិក) ឬស្មើនឹង ៣៤,៨៩%។

ដោយឡែក ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិក្នុងឆ្នាំ២០២៣ (Basic Earnings Per Share) គឺមាន ចំនួន ១.៨៦៦,៤៣ រៀល (0,៤៥ ដុល្លារអាមេរិក) ។

លទ្ធផលប្រចាំឆ្នាំ២០២៣ របស់ ក. ស. ភ. មានកំណើនទាបជាងលទ្ធផលឆ្នាំ២០២២ ប៉ុន្តែសម្រាប់ ឆ្នាំ ២០២៤ នេះ ក.ស.ភ. បានដាក់ចេញនូវយន្តការបន្ថែមទៀត តាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពលើកដាក់ និងផ្ទេរផ្ទុក ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការដាក់ឱ្យប្រើប្រាស់នូវចំណតផែរណបតាមដងទន្លេ សំដៅឱ្យលទ្ធផលប្រចាំឆ្នាំ២០២៤ សម្រេចបានតាមផែនការដែលបានគ្រោងទុក។

### ២.៧.១. ទ្រព្យសកម្ម បំណុល និងមូលធនសរុប

នៅក្នុងឆ្នាំ២០២៣ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣) ទ្រព្យសកម្មសរុបរបស់ ក.ស.ភ. មានចំនួន ១.០៤០.៨៨៣.៥៣៣ ពាន់រៀល ដែលក្នុងនោះមានទ្រព្យសកម្មរយៈពេលវែងសរុប ៩៩១.២៣៩.៣៧០ ពាន់រៀលដែលត្រូវជា ៩៥,២៣% នៃទ្រព្យសកម្មសរុប និងទ្រព្យសកម្មរយៈពេលខ្លីសរុប ៤៩.៦៤៤.១៦៣ ពាន់រៀលដែលត្រូវជា ៤,៧៧% នៃទ្រព្យសកម្មសរុប។ បំណុលសរុបមានចំនួន ២៤៤.១២៣.១៤៣ ពាន់រៀល ដែលត្រូវជា ២៣,៤៥% នៃទ្រព្យសកម្មសរុប។ បំណុលរយៈពេលខ្លីសរុបមានចំនួន ៣៤.៣៥៧.៨១២ ពាន់រៀលដែលត្រូវជា ១៤,០៧% នៃបំណុលសរុប ឯបំណុលរយៈពេលវែងសរុបមាន ២០៩.៧៦៥.៣៣១ ពាន់រៀលដែលត្រូវជា ៨៥,៩៣% នៃបំណុលសរុប។ មូលធនសរុបមានចំនួន ៧៩៦.៧៦០.៣៩០ ពាន់រៀល ដែលត្រូវជា ៧៦,៥៤% នៃទ្រព្យសកម្មសរុប។

តារាង២.២៖ តារាងស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ.

| បរិយាយ | ៣១ ធ្នូ ឆ្នាំ២០២៣ | ៣១ ធ្នូ ឆ្នាំ២០២២ | ០១ មករា ឆ្នាំ២០២២ |
|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល) | | | |
| ទ្រព្យសកម្មសរុប | ១.០៤០.៨៨៣.៥៣៣ | ១.០១០.៩០៨.០៨៥ | ៨៩៩.១៣០.២២០ |
| បំណុលសរុប | ២៤៤.១២៣.១៤៣ | ២៤១.២១៦.៤៥៦ | ១៩៣.២០២.៤៣៨ |
| មូលធនសរុប | ៧៩៦.៧៦០.៣៩០ | ៧៦៩.៦៩១.៦២៩ | ៧០៨.៩២៧.៧៨២ |




ក្រាហ្វិកទី១៖ ស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ. ឆ្នាំ២០២៣

### ២.៧.២. ចំណូលសរុប ចំណាយសរុប និងចំណេញសុទ្ធ

នៅក្នុងការិយបរិច្ឆេទឆ្នាំ២០២៣ (បញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣) ចំណូលសរុបរបស់ ក.ស.ភ. មានចំនួន ១៨២.០៣៥.៤៨០ ពាន់រៀលដែលជាប្រភពចំណូលធំបំផុតគឺ ចំណូលពីប្រតិបត្តិការផែ (ប្រមាណជា ៨៤,៨០%) ។ ចំណែកឯចំណាយវិញមានចំនួន ១១០.៨៧០.៣៦៥ ពាន់រៀលដែលចំណាយធំៗមានដូចជា ចំណាយលើថ្លៃដើមសេវាកម្ម ចំណាយទូទៅ និងរដ្ឋបាល ចំណាយហិរញ្ញប្បទាន និងចំណាយផ្សេងៗទៀត។ ប្រាក់ចំណេញប្រតិបត្តិការមាន ចំនួន៩៩.៥០៨.៨៧១ពាន់រៀល និងចំណេញមុនពេលបង់ពន្ធមាន ចំនួន ៥០.១១៩.១៣២ ពាន់រៀល។ ចំណេញក្រោយពេលបង់ពន្ធ ឬចំណេញប្រចាំឆ្នាំមានចំនួន ៣៨.៦០៥.៩៦៦ ពាន់រៀល។

តារាង២.៣៖ លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ភ.

| បរិយាយ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល) | | | |
| ចំណូលសរុប | ១៤២.០៣៥.៤៨០ | ១៤៨.៨១៥.៥៦៧ | ១២៥.២២៨.១៥២ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ៥០.១១៩.១៣២ | ៧៤.៨១២.២៧៤ | ៦៣.៩១៧.៧៩១ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ៣៨.៦០៥.៩៦៦ | ៥៩.២៩៣.៦៩០ | ៥១.៦៩៥.៤៥៧ |




ក្រាហ្វិកទី២៖ ប្រភពចំណូលសម្រាប់ឆ្នាំ២០២៣ របស់ ក.ស.ភ




ក្រាហ្វិកទី៣៖ ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២៣ របស់ ក.ស.ភ




ក្រាហ្វិកទី៤៖ អត្រាកំណើនចំណូលនិងចំណេញរបស់ ក.ស.ភ

## ២.៨. យុទ្ធសាស្រ្តអាជីវកម្ម និងផែនការអនាគត

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) មានយុទ្ធសាស្រ្តអាជីវកម្ម និងផែនការអនាគត ដូចខាងក្រោមៈ

### ២.៨.១. ផែនការយុទ្ធសាស្រ្តបច្ចុប្បន្ន

- បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុក
- ធានាគុណភាព តម្លៃ តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្តល់សេវាកម្មជូនអតិថិជន
- ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភ័ស្តុភារកម្ម
- ពង្រឹងការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីឆ្លើយតបនឹងការវិវឌ្ឍរបស់អង្គភាពស្របទៅនឹងការផ្លាស់ប្តូរចរន្តភាវូបនីយកម្ម និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្រ្ត ជាមួយបណ្តាកំពង់ផែក្នុងតំបន់ និងបណ្តាកំពង់ផែដទៃទៀតនៅលើពិភពលោក
- ខិតខំ និងបន្តផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដារ និងប្រព័ន្ធបច្ចេកវិទ្យា
- បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុង និងក្រៅប្រទេស
- បង្គិតសេវាកម្មកំពង់ផែឱ្យកាន់តែខិតជិតអ្នកប្រើប្រាស់
- ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

### ២.៨.២. ផែនការយុទ្ធសាស្រ្តអនាគត

#### ១. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី៤ នៃចំណតផែកុងតឺន័រ LM១៧

ចន្លោះពី ឆ្នាំ២០១៨ ដល់ ឆ្នាំ២០២៣ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ១៨% រៀងរាល់ឆ្នាំ។ ដោយសារតែកុងតឺន័រដែលបច្ចុប្បន្នឆ្លងកាត់នៅ LM១៧ មានចំនួន ៣៩៦.២២៥ ធីអ៊ីយូ ក្នុងឆ្នាំ ២០២៣ ក.ស.ភ. ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ៤៤០.០០០ ធីអ៊ីយូ ក្នុងឆ្នាំ២០២៤។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ. ត្រូវធ្វើការពង្រីកបរិវេណឃ្លាំងផែ និងបរិក្ខារបន្ថែមទៀត។ គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ និងការបំពាក់គ្រឿងចក្រផ្សេងៗ ក្នុងជំហានទី៤នេះ គឺមានគោលបំណងធានាសមត្ថភាពលើកដាក់របស់ផែ ក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំដែលរំពឹងថានឹងអាចដល់កម្រិត ៩០០.០០០ ធីអ៊ីយូ ក្នុងមួយឆ្នាំ។ គម្រោងនេះ គ្រោងនឹងចំណាយទឹកប្រាក់ប្រមាណ ១៦៨.៦១០.៦៩០.០០០ រៀល ប្រមាណជា ៤១លានដុល្លារអាមេរិក ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៤ ដល់ ២០២៧។

## ២. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង UM២

តាមរយៈគោលនយោបាយលើកទឹកចិត្ត របស់រាជរដ្ឋាភិបាលលើការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក និងជម្រុញការនាំចេញកសិផលដែលចំណតផែរណបពហុបំណង ជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រមូលផ្ដុំកសិផលដែលចំណតផែរណបពហុបំណង UM២ ជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រមូលផ្ដុំកសិផល ពីបណ្ដាខេត្តស្ថិតនៅប៉ែកឥសាន្តនៃប្រទេសកម្ពុជា។ គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែក្នុងជំហានទី២នេះ គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងបង្កភាពងាយស្រួលក្នុងការលើកដាក់ទំនិញរាយ ទំនិញជាកុងតឺន័រ និងជំរុញការនាំចេញទិន្នផលកសិផល។ គម្រោងនេះ គ្រោងនឹងចំណាយទឹកប្រាក់ប្រមាណ ២២.៧០០.៥០០.០០០ រៀល ប្រមាណជា ៥,៥លានដុល្លាអាមេរិក ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៤ ដល់ ២០២៥។

## ៣. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង UM១

ចំណតផែរណបពហុបំណង UM១ ជាចំណតដែលប្រមូលផ្ដុំ និងចែកចាយកសិផល សម្ភារៈសំណង់ និងទំនិញរាយផ្សេងៗ ពីបណ្ដាខេត្តស្ថិតនៅតាមប៉ែកឦសាន នៃប្រទេសកម្ពុជា។ គោលបំណងនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជំហានទី១ នៃចំណតផែរណបពហុបំណង UM១ គឺដើម្បីបង្កើតជាកន្លែងប្រមូលផ្ដុំ និងចែកចាយទំនិញតាមរយៈការតភ្ជាប់ការដឹកជញ្ជូនរវាងផ្លូវទឹក និងផ្លូវគោក និងបង្កើនភាពប្រកួតប្រជែងរបស់ ក.ស.ភ. បង្វិតសេវាកំពង់ផែ និងដឹកជញ្ជូនតាមផ្លូវទឹកទៅជិតអ្នកប្រើប្រាស់។ គម្រោងនេះ គ្រោងនឹងចំណាយទឹកប្រាក់ប្រមាណ ៣០.៥៤៤.០០០.០០០ រៀល ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៣ ដល់ ២០២៤។

## ៤. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែពហុបំណង TS៣

ចំណតផែពហុបំណង TS៣ ជាចំណតផែចម្បងសម្រាប់ទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមាន កម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក. ស. ភ. បានវិនិយោគលើការ អភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ បច្ចុប្បន្ន ក.ស.ភ. បាននិងកំពុងរៀបចំកែប្រែ ចំណតផែនេះ ឱ្យក្លាយទៅជាចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិ។ ការកែប្រែនេះគឺមានគោលបំណងចង់បង្កើតចំណតផែអ្នកដំណើរ និងទេសចរណ៍អន្តរជាតិដែលមានលក្ខណៈស្តង់ដារ និងដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រើប្រាស់មធ្យោបាយផ្លូវទឹក។ គម្រោងនេះគ្រោងនឹងសហការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីសាងសង់អគាររដ្ឋបាលដែលគ្រោងនឹងចំណាយទុនវិនិយោគចំនួន ៩៩.៦០០.០០០.០០០ រៀល ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៣ ដល់ ២០២៤។

## ៥. គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង LM២៦

ចំណតផែរណបពហុបំណង LM២៦ ដែលមានទីតាំងស្ថិតនៅឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង ជាទីតាំងយុទ្ធសាស្ត្រក្នុងការប្រមូលផ្តុំកសិផលពីបណ្តាខេត្តនៃប្រទេសកម្ពុជា ហើយក៏មានសក្តានុពលក្នុងវិស័យទេសចរណ៍ផងដែរ។ គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចំណតផែរណបពហុបំណង LM២៦ មានគោលបំណងបង្កើតចំណតផែដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការលើកដាក់ ផ្ទេរផ្ទុក និងជម្រុញការនាំចេញទិន្នផលកសិផលជាពិសេស ស្រូវ ពោតជាដើម។ លើសពីនេះក៏មានគោលបំណងលើកកម្ពស់ដល់ការប្រើប្រាស់សេវាកម្មដឹកជញ្ជូនផ្លូវទឹក និងបង្កើតការងារបន្ថែមសម្រាប់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ផងដែរ។ គម្រោងនេះ គ្រោងនឹងចំណាយទឹកប្រាក់ប្រមាណ ៣០.៥៤៤.០០០.០០០ រៀល ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៣ ដល់ ២០២៤។

## ៦. គម្រោងអភិវឌ្ឍន៍ចំណតផែរណបពហុបំណង TS១១

គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រតិបត្តិការ ជំហានទី២ ចំណតផែរណបពហុបំណង TS១១ ដែលជាចំណតផែរណបលើកដាក់ទំនិញរាយ និងកុងតឺន័រ និងមានទីតាំងស្ថិតនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ គឺមានគោលបំណងបង្កើតចំណតផែដើម្បីបង្កភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការលើកដាក់ទំនិញរាយ និងទំនិញកុងតឺន័រ ដែលបង្កើនសមត្ថភាពលើកដាក់របស់ ក.ស.ភ.។ គម្រោងនេះគ្រោងនឹងសហការជាមួយដៃគូវិនិយោគ ដើម្បីសាងសង់ច្រាំងទន្លេ ផ្លូវតាមមាត់ទន្លេ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដែលគ្រោងនឹងចំណាយទុនវិនិយោគចំនួន ១៥.៦៨៦.៦២៤.០០០ រៀល ដែលមានរយៈពេលអនុវត្តគម្រោងពីឆ្នាំ ២០២៤ ដល់ ២០២៥។[27]

[27] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ២០-២៦ (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

# ជំពូកទី៣

# ដំណើរការបោះផ្សាយលក់មូលបត្រ
# កម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់
# កំពង់ផែស្វយ័តភ្នំពេញ

# ជំពូកទី៣
# ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់កំពង់ផែស្វយ័តភ្នំពេញ

បើតាមសេចក្តីជូនដំណឹងរបស់ ផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ដែលបានផ្សាយទាក់ទងនឹងកំពង់ផែស្វយ័តក្រុងភ្នំពេញ នឹងត្រូវចូលក្នុងទីផ្សារ ភាគហ៊ុន នៅខែធ្នូ ឆ្នាំ ២០១៥ ហើយបានចាប់ផ្តើមដំណើរការធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (IPO) នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៥ ដោយរំពឹងថាការលក់ IPO នឹងប្រមូលទុនបានពីជាង ៤លានដុល្លារអាមេរិច ដល់ជាង ៦ លានដុល្លារអាមេរិច។ ដើម្បីអាចចុះបញ្ជី និងដាក់ឲ្យជួញដូរភាគហ៊ុនរបស់ខ្លួននៅ ផ.ម.ក កំពង់ផែស្វយ័ត (ក.ស.ភ) ត្រូវតែទទួលបានការអនុញ្ញាតឲ្យបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពីនិយ័តករមូលបត្រកម្ពុជា និងត្រូវបំពេញនូវលក្ខខណ្ឌផ្សេងៗមួយចំនួនទៀតពាក់ព័ន្ធនឹងការចុះបញ្ជីនៅ ផ.ម.ក។ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ កំពង់ផែក្រុងភ្នំពេញ បានរៀបចំធ្វើ Road Show នៅសណ្ឋាគារសូហ្វីតែលភូគីត្រាភ្នំពេញ ដើម្បីធ្វើបទបង្ហាញពាក់ព័ន្ធ ទៅនឹងដំណើរការបោះលក់ភាគហ៊ុន ជាលើកដំបូងរបស់ខ្លួន។ ដោយកំពង់ផែក្រុងភ្នំពេញ គ្រោងនឹងចាប់ផ្តើមលក់ភាគហ៊ុន ២០ ភាគរយស្មើនឹង ៤.១៣៦.៨៧៣ ហ៊ុន នៃភាគហ៊ុនទាំងអស់របស់ខ្លួន ដែលមានចំនួន ២០.៦៨៤.៣៦៥ហ៊ុន ។ តម្លៃភាគហ៊ុនរបស់កំពង់ផែភ្នំពេញ នឹងត្រូវលក់ក្នុងតម្លៃចន្លោះពី ១,០៨ដុល្លារ ដល់ ១,៥៥ដុល្លារ ក្នុង១ហ៊ុន ដូច្នេះការបោះលក់ភាគហ៊ុន របស់កំពង់ផែក្រុងភ្នំពេញ អាចនឹងទទួលបានទឹកប្រាក់ចន្លោះពី ៤.៤៦៧.៨២២,៨៤ ដុល្លារ ទៅដល់ ៦.៤១២.១៥៣,១៥ដុល្លារ ។

អគ្គនាយកកំពង់ផែក្រុងភ្នំពេញ ឯកឧត្តម **ហ៊ី បាវី** បានថ្លែងប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា ការបោះលក់មូលបត្រជាលើកដំបូង (IPO) របស់កំពង់ផែក្រុងភ្នំពេញនេះ ធ្វើឡើងស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រមូលថវិកា វិនិយោគបន្តលើហេដ្ឋារចនាសម្ព័ន្ធ របស់កំពង់ផែក្នុងការផ្ទុកទំនិញ ឲ្យបានកាន់តែច្រើនឡើងថែមទៀត ស្របតាមផែនការអនាគត។ លោក ហ៊ី បាវី បន្តថា ភាគហ៊ុនរបស់កំពង់ផែ បានលក់អស់ប្រមាណ ៥០ ភាគរយរួចហើយ ដោយ១០ ភាគរយលក់ជូនមន្ត្រី នៃកំពង់ផែស្វយ័តផ្ទាល់ និង៤០ភាគរយលក់ឲ្យវិនិយោគិន (កក់រួច) និងនៅសល់៥០ភាគរយទៀត បាននិងកំពុងលក់ជូនសាធារណជនទូទៅ។ លើសពីនេះ នៅឆ្នាំ២០១៨ កំពង់ផែស្វ័យក្រុងភ្នំពេញ នឹងធ្វើការបោះលក់ភាគហ៊ុន ១០ភាគរយទៀត (ជាង២លានហ៊ុន)។ បើតាមផែនការ ដំណើរការធ្វើ **ប៊ុកបៀលឌីង** ឬ Book building (ការកំណត់ថ្លៃ) ត្រូវចាប់ផ្តើមថ្ងៃទី១៩ រហូតដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ហើយការធ្វើ **បរិវិសកម្ម** ឬ Subscription (ការទិញយក) នឹងត្រូវធ្វើឡើងនៅថ្ងៃទី

១២ ដល់ ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ និងចុងក្រោយការជួញដូរជាសាធារណៈ ក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នឹងចាប់ផ្តើមនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥។

កំពង់ផែស្វយ័តភ្នំពេញ ជាក្រុមហ៊ុនទី៣ ដែលត្រូវចូលទីផ្សារភាគហ៊ុន ហើយក៏ជាក្រុមហ៊ុនរដ្ឋទី២ ដែលចូលផ្សារភាគហ៊ុនផងដែរ។ ក្រុមហ៊ុនទាំង ៣ រួមមាន ក្រុមហ៊ុនទី ១ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រុមហ៊ុនទី ២ ក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ Grand Twins International និង ទី៣ គឺ កំពង់ផែស្វយ័តភ្នំពេញ និងមានក្រុមហ៊ុនបន្តបន្ទាប់ទៀត។[28]

## ៣.១. ព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការបោះផ្សាយ

យោងតាមយន្តការណែនាំស្តីពីការបោះផ្សាយលក់មូលបត្រសាធារណៈជាលើកដំបូង ចេញផ្សាយដោយ ន.ម.ក. កំពង់ផែស្វយ័តភ្នំពេញ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ និងក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ជាដើម។ ក្រុមហ៊ុនទាំងនេះត្រូវតែមានការទទួលស្គាល់ពី ន.ម.ក.ផងដែរ។

### ៣.១.១ ព័ត៌មានទូទៅរបស់ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរិធី (ខេមបូឌា) ភីអិលស៊ី ជាក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រតែមួយគត់ សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈរបស់ ក.ស.ភ។[29]

កិច្ចសន្យាធានាទិញមូលបត្រ ត្រូវបានធ្វើឡើងនាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៥ ហើយត្រូវបានធ្វើវិសោធនកម្មនៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ (តទៅនេះហៅរួមគ្នាថា "កិច្ចសន្យាធានាទិញមូលបត្រ")។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបនៃកិច្ចសន្យាធានាទិញមូលបត្រ ដែលពុំបានរៀបរាប់ខ្លឹមសារសំខាន់ៗទាំងស្រុងនៃកិច្ចសន្យានោះទេ។

- **ការធានាទិញមូលបត្រ**

អាស្រ័យលើការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) និងការអនុញ្ញាតលើការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដោយផ្សារមូលបត្រកម្ពុជា (ផ.ម.ក) លើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងអាស្រ័យលើការបំពេញតាមនូវរាល់លក្ខខណ្ឌនានា ដែលមានចែងក្នុងកិច្ចសន្យាធានាទិញ

[28] http://m.freshnewsasia.com/index.php/en/11420-2015-10-19-10-47-11.html (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤)

[29] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ២៦-២៨

មូលបត្រ ក្រុមហ៊ុនធានាទិញមូលបត្រ និងទិញភាគហ៊ុនដែលពុំបានធ្វើបរិវិសកម្មដោយក្រុមវិនិយោគិន នៅពេលដែលបរិវិសកម្មបានបញ្ចប់។

❖ **មូលដ្ឋាននៃការបញ្ចប់**

កាតព្វកិច្ចរបស់ក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងការធ្វើបរិវិសកម្ម ឬរៀបចំឱ្យមានអ្នកធ្វើបរិវិសកម្មនូវភាគហ៊ុន អាចនឹងត្រូវបញ្ចប់ដោយអំណាចឆន្ទានុសិទ្ធិរបស់ក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងរយៈពេល ១៥ថ្ងៃបន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរពីការបញ្ចប់ទៅ ក.ស.ភ តាមការយល់ឃើញរបស់ក្រុមហ៊ុនធានាទិញមូលបត្រ ប្រសិនបើមានព្រឹត្តិហេតុណាមួយ ដូចខាងក្រោមកើតឡើងមុនការបញ្ចប់នៃការបោះផ្សាយ ហើយដែលព្រឹត្តិហេតុនេះមិនអាចត្រូវ បានដោះស្រាយដោយការបញ្ចប់៖ ក.ស.ភ ក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃដែលបានជូនដំណឹងពីការបញ្ចប់៖

1. ប្រសិនបើ ក.ស.ភ បានបំពានលក្ខខណ្ឌនៃកិច្ចសន្យាធានាទិញមូលបត្រ
2. ប្រសិនបើ ក.ស.ភ និងក្រុមហ៊ុនធានាទិញមូលបត្រ មិនយល់ព្រមជាមួយគ្នាលើថ្លៃមូលបត្រ សម្រាប់ការបោះផ្សាយ នៅក្នុងចន្លោះថ្លៃដែលបានកំណត់ក្នុងកិច្ចសន្យាធានាទិញ
3. ប្រសិនបើ មានការផ្លាស់ប្តូរលក្ខខណ្ឌណាមួយដូចជា លក្ខខណ្ឌហិរញ្ញវត្ថុ នយោបាយ ឬសេដ្ឋកិច្ច ឬការដាក់កំហិតលើអត្រាប្តូរប្រាក់ ឬការដាក់កំហិតលើលំហូរសាច់ប្រាក់ ឆ្លងប្រទេសនៅកម្ពុជា ឬនៅលើឆាកអន្តរជាតិ ដែលតាមការវិនិច្ឆ័យផ្ទាល់របស់ ក្រុមហ៊ុនធានាទិញមូលបត្រ យល់ថាការបោះផ្សាយលក់មូលបត្រពុំអាចបញ្ចប់ដោយជោគជ័យ
4. ប្រសិនបើមានការព្យួរ ឬកំហិតលើការជួញដូរមូលបត្រនៅ ផ.ម.ក
5. ប្រសិនបើការបង្អាក់ប្រតិបត្តិការធនាគារ ត្រូវបានប្រកាសដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសកម្ពុជា ដូចជា ធនាគារជាតិនៃកម្ពុជា បានចេញបញ្ជាទៅធនាគារពាណិជ្ជ ដើម្បីផ្អាកប្រតិបត្តិការធនាគារ
6. ប្រសិនបើមានការបង្អាក់ធ្ងន់ធ្ងរចំពោះសេវាកម្មផាត់ទាត់ និងទូទាត់មូលបត្រនៅក្នុង ឬទាក់ទងនឹងកម្ពុជាកើតឡើង
7. ប្រសិនបើមាន ការរាលដាល ឬអំពើភាវរកម្ម ការប្រកាសសង្គ្រាម ឬភាពអាសន្នក្នុង ប្រទេស ឬអន្តរជាតិ ដូចជា ភាពរារាំងដល់ដំណើរការរដ្ឋាភិបាល ចលាចលក្នុង ប្រទេស គ្រោះធម្មជាតិ ឬការប្រកាសអាសន្ន ដែលក្រុមហ៊ុនធានាទិញមូលបត្រយល់ ថា បញ្ហាទាំងនេះ ធ្វើឱ្យការបោះផ្សាយលក់មូលបត្រពុំអាចបញ្ចប់ដោយជោគជ័យ

៥. ប្រសិនបើមានការផ្លាស់ប្តូរការអនុវត្តពន្ធដារនៅកម្ពុជា អាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ ជាសារវន្តដល់ ក.ស.ភ ភាគហ៊ុនរបស់ ក.ស.ភ ឬការផ្ទេរកម្មសិទ្ធិមូលបត្រ។

ប្រសិនបើមានការផ្លាស់ប្តូរដែលអាចកើតឡើង អាចធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ ជាសារវន្តដល់ប្រាក់ចំណេញ សកម្មភាពអាជីវកម្ម ឬលទ្ធភាពអាជីវកម្មរបស់ ក.ស.ភ នាពេលបច្ចុប្បន្ន ឬនៅពេលអនាគត។

### ៣.១.២ ព័ត៌មានស្តីពីក្រុមហ៊ុនគណនេយ្យជំនាញ និងសវនកម្មឯករាជ្យ

ព័ត៌មានស្តីពីក្រុមហ៊ុនគណនេយ្យជំនាញ និងសវនកម្មឯករាជ្យ មានដូចខាងក្រោម៖[30]

❖ **ក្រុមហ៊ុនគណនេយ្យជំនាញ**

តារាង៣.១៖ ព័ត៌មានលម្អិតពីក្រុមហ៊ុនគណនេយ្យជំនាញ

| ឈ្មោះក្រុមហ៊ុន | ខេភីអឹមជី ខេមបូឌា ចំកាត់ | | |
|---|---|---|---|
| អាសយដ្ឋាន | ប្រអប់សំបុត្រលេខ២៣៥២ អគារ Delano Center ជាន់ទី៤ លេខ១៤៤ ផ្លូវ១៦៩ ភ្នំពេញ កម្ពុជា | | |
| លេខទូរស័ព្ទ | 023 216 899 | លេខទូរសារ | 023 217 279 |
| គេហទំព័រ | www.kpmg.com.kh | អ៊ីម៉ែល | kpmg@kpmg.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | Co.៣៥២E/1997 | កាលបរិច្ឆេទ | ១៩ សីហា ១៩៩៧ |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ០០០៣-CP | កាលបរិច្ឆេទ | ១៧ មករា ២០០៥ |
| លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក | ០០២ គ.ម.ក/ក.គ | កាលបរិច្ឆេទ | ០៩ កុម្ភៈ ២០១១ |

[30] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៣០

❖ **សវនករឯករាជ្យ**

តារាង៣.២៖ ព័ត៌មានលម្អិតពីសវនករឯករាជ្យ

| ឈ្មោះក្រុមហ៊ុន | ង៉ៃ ហ៊ុយ | | |
|---|---|---|---|
| អាសយដ្ឋាន | ប្រអប់សំបុត្រលេខ២៣៥២ អគារ Delano Center ជាន់ទី៤ លេខ១៤៤ ផ្លូវ១៦៩ ភ្នំពេញ កម្ពុជា | | |
| លេខទូរស័ព្ទ | 023 216 899 | លេខទូរសារ | 023 217 279 |
| គេហទំព័រ | www.kpmg.com.kh | អ៊ីម៉ែល | kpmg@kpmg.com.kh |
| លេខចុះបញ្ជីជាសមាជិក វ.គ.ស.ក | I-០០០០៥ | កាលបរិច្ឆេទ | ២៥ កញ្ញា ២០០៣ |
| លេខចុះបញ្ជីទទួលស្គាល់ដោយគ.ម.ក | ០០៨ គ.ម.ក/ស.ឯ | កាលបរិច្ឆេទ | ០៩ កុម្ភៈ ២០១១ |

### ៣.១.៣ ក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ និងអ្នកវាយតម្លៃឯករាជ្យ

❖ **ក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ** មានព័ត៌មានដូចខាងក្រោម៖[31]

តារាង៣.៣៖ ព័ត៌មានលម្អិតពីក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យ

| ឈ្មោះក្រុមហ៊ុន | វីត្រាស់ អ៊ីព្រេហ្សល | | |
|---|---|---|---|
| អាសយដ្ឋាន | លេខ១១៣ អគារ ផាកវ៉េ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | | |
| លេខទូរស័ព្ទ | 023 220098 | លេខទូរសារ | 023 220 098 |
| គេហទំព័រ | www.vtrustappraisal.com | អ៊ីម៉ែល | vap@vtrustappraisal.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | Co.២៨២៧KH/២០១១ | កាលបរិច្ឆេទ | ២៩ កញ្ញា ២០០៣ |

[31] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៣០-៣១

| | | | |
|---|---|---|---|
| លេខអាជ្ញាបណ្ណអាជីវកម្ម | អជ្ញាប័ណ្ណលេខ០១២ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | កាលបរិច្ឆេទ | ០៨ មករា ២០១៥ |
| លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក | លេខ០០១ទទួលស្គាល់ដោយ គ.ម.ក | កាលបរិច្ឆេទ | ០២ កុម្ភៈ ២០១១ |

❖ **អ្នកវាយតម្លៃឯករាជ្យ**

តារាង៣.៤៖ ព័ត៌មានលម្អិតពីអ្នកវាយតម្លៃឯករាជ្យ

| | | | |
|---|---|---|---|
| ឈ្មោះក្រុមហ៊ុន | ស៊ឹម ហ៊ុយ ឈ័ង | | |
| អាសយដ្ឋាន | លេខ១១៣ អគារ ផាកវេ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | | |
| លេខទូរស័ព្ទ | 023 220098 | លេខទូរសារ | 023 220 098 |
| គេហទំព័រ | N/A | អ៊ីម៉ែល | chhuong@vtrustappraisal.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | Co.២៨២៧KH/២០១១ | កាលបរិច្ឆេទ | ២៩ កញ្ញា ២០០៣ |
| វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃអចលនវត្ថុ | លេខ០០១ទទួលស្គាល់ដោយ គ.ម.ក | កាលបរិច្ឆេទ | ០២ កុម្ភៈ ២០១៥ |
| លេខចុះបញ្ជីទទួលស្គាល់ដោយ គ.ម.ក | លេខ០០៨ គ.ម.ក/អ.ឯ | កាលបរិច្ឆេទ | ០២ កុម្ភៈ ២០១១ |

### ៣.១.៤ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

តារាង៣.៥៖ ព័ត៌មានលម្អិតពីមេធាវី

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ការិយាល័យមេធាវីសិទ្ធិស័ក្តិ |
| ឈ្មោះមេធាវីតំណាង | ១.លោកមេធាវី តាន់ ម៉េងស្រួយ<br>២. លោកមេធាវី ម៉ុក ច័ន្ទសុធា |

| | | | |
|---|---|---|---|
| អាសយដ្ឋាន | អគារលេខ ៦៨ ផ្លូវលេខ ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | | |
| លេខទូរស័ព្ទ | 023 6373 168 | លេខទូរសារ | N/A |
| គេហទំព័រ | www.sithisak-lawoffice.com | អ៊ីម៉ែល | Contact@sithisak-lawoffice.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា | លេខ៧៥៣គម/១០ ចេញដោយគណៈមេធាវីនៃព្រះរាជាណាចក្រ | កាលបរិច្ឆេទ | ១៦ កញ្ញា ២០១០ |
| លេខចុះបញ្ជីទទួលស្គាល់ដោយគ.ម.ក[32] | ០០៣/គម.ម/កា ម ចេញដោយ គ.ម.ក | កាលបរិច្ឆេទ | ២៥ កក្កដា ២០១២ |

## ៣.២. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

យោងទៅតាមឯកសារផ្តល់ព័ត៌មាន សម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ កំពង់ផែស្វយ័តភ្នំពេញ ចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត ″ក″ បានអនុញ្ញាតឱ្យបោះផ្សាយមូលបត្រកម្មសិទ្ធិ ១២.០០០.០០០ ដែលមានតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ៤.០០០ រៀល និងថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ ៥.១២០ រៀល ហើយមានបរិមាណសរុបនៃមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ ៤.១៣៦.៨៧៣ មូលបត្រ។ ចំណែកឯតម្លៃសរុបនៃមូលបត្រកម្មសិទ្ធិ ដែលធ្វើសំណើរលក់ ២១.១៨០.៧៨៩.៧៦០ រៀល ដែលមានកាលបរិច្ឆេទចាប់ផ្តើមធ្វើបរិសកម្មនៅថ្ងៃ ១២ ខែវិច្ឆិកា ឆ្នាំ ២០១៥ និងត្រូវបានបញ្ចប់ការធ្វើបរិសកម្មនៅថ្ងៃ ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥។[33]

[32] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៣២

[33] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៣៣-៣៤

### ៣.២.១. ចំនួនមូលបត្រកម្មសិទ្ធិ

តារាង៣.៦៖ ចំនួនមូលបត្រកម្មសិទ្ធិ

| មូលបត្រកម្មសិទ្ធិ | ចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត"ក" | ចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត"ខ" | ចំនួនមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត"គ" |
|---|---|---|---|
| មូលបត្រកម្មសិទ្ធិ អនុញ្ញាតឱ្យបោះផ្សាយ | ១២.០០០.០០០ | ៥០.០០០.០០០ | ១០០.០០០.០០០ |
| មូលបត្រកម្មសិទ្ធិដែលមានសរុប | | ១៦.៥៤៧.៤៩២ | ៩៣.៧៦៩.១២០ |

### ៣.២.២. លក្ខខណ្ឌនៃសំណើលក់

តារាង៣.៧៖ លក្ខខណ្ឌនៃសំណើលក់

| ក្រុមវិនិយោគិន | ចំនួនបែងចែក | អនុបាតបែងចែក |
|---|---|---|
| មូលបត្រកម្មសិទ្ធិលៃបម្រុងទុកសម្រាប់លក់ជូននិយោជិក | ៤១៣.៦៨៧ | ១០% |
| វិនិយោគិនសក្តានុពល | ១.៨៥៩.៥៧៣ | ៤៤,៩៥% |
| វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ិកបៀលឌីង | ១.០៥៥.០០០ | ២៥,៥០% |
| វិនិយោគិនក្នុងបរិសកម្ម | ៨០៨.៦១៣ | ១៩,៥៥% |
| សរុប | ៤.១៣៦.៨៧៣ | ១០០% |

### ៣.២.៣. ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

ថ្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់គឺស្មើនឹង ៥.១២០រៀល។ បើយោងតាមការអនុញ្ញាតពី គ.ម.ក នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥។

តម្លៃមូលធន (Equity Value) និងថ្លៃមូលបត្រកម្មសិទ្ធិ របស់សហគ្រាសត្រូវបានគណនាតាមរយៈវិធីសាស្ត្រវាយតម្លៃប្រៀបធៀប ដោយធ្វើការប្រៀបធៀប ក.ស.ភ ទៅនឹងក្រុមហ៊ុនកំពង់ផែដែលបានចុះបញ្ជីលក់មូលបត្រលើទីផ្សារមូលបត្រនានាក្នុងសកលលោក និងក្រុមហ៊ុនដែលកំពុងចុះបញ្ជីលក់ លើផ្សារមូលបត្រកម្ពុជា។

ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី ជឿជាក់ថាវិធីសាស្ត្រវាយតម្លៃប្រៀបធៀប ដែលប្រើមេគុណទីផ្សារនានា (Market Multiple) គឺជាវិធីសាស្ត្រដែលត្រឹមត្រូវបើប្រៀបធៀបនឹងវិធីសាស្ត្រដាច់ខាត ដែលតម្រូវឱ្យមានការសម្រេចចិត្តបែបអត្តនោម័តទៅលើការប៉ាន់ស្មាននៃលំហូរសាច់ប្រាក់ និងអត្រាអប្បហារ។ ដោយសារពុំទាន់មានក្រុមហ៊ុនច្រើនបានចុះបញ្ជីលក់នៅកម្ពុជា ព័ត៌មានចម្បងៗសម្រាប់ធ្វើការប៉ាន់ស្មាន ថ្លៃដើមនៃមូលធន (Cost of Equity) ពុំទាន់មាន ដូចជា អត្រាហានិភ័យទីផ្សារបេតា (Beta) អត្រាចំណេញទីផ្សារគោល (Market Return) និងអត្រាចំណេញគ្មានហានិភ័យ (Risk Free Rate) ជាដើម។ ដូចនេះ ការប្រើវិធីសាស្ត្រដាច់ខាតដែលមានការសន្មតច្រើននឹង ធ្វើឱ្យការវាយតម្លៃមានកម្រិតជឿជាក់តិច។[34]

វិនិយោគិនដែលចូលរួមនៅក្នុងប៊ុកបៀលឌីង បានដាក់ថ្លៃលក់មូលបត្រនៅក្នុងថ្លៃចន្លោះដែលបានកំណត់។ ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី និងក.ស.ភ បានធ្វើការកំណត់ថ្លៃលក់មូលបត្រ ដើម្បីធ្វើសំណើលក់ដោយយកមូលដ្ឋាន លើលទ្ធផលនៃការធ្វើប៊ុកបៀលឌីង និងបរិយាកាសទីផ្សារ។ បន្ទាប់មក ក.ស.ភ ធ្វើការស្នើសុំការយល់ព្រមលើថ្លៃដែលបានកំណត់នេះ និងដាក់ស្នើឯកសារផ្តល់ព័ត៌មានជាមួយថ្លៃដែលបានកំណត់នេះទៅ គ.ម.ក ដើម្បីទទួលការយល់ព្រមលើថ្លៃមូលបត្រកម្មសិទ្ធិ និងធ្វើការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន មុននឹងចាប់ផ្តើមធ្វើបរិវិសកម្មមូលបត្រ។

## ៣.៣. លក្ខខណ្ឌនៃការបែងចែក និងនីតិវិធីនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម

អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន[35] ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន[36] និង

---

[34] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៤៩

[35] ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

[36] អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

ប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា លេខ ០០១ គ.ម.ក ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ [37] ព្រមទាំងបទប្បញ្ញត្តិជាធរមាន ពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យការអនុវត្តប្រកបភាពរលូន និងមានប្រសិទ្ធភាព ក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គ.ម.ក បានចេញនូវគោលការណ៍ណែនាំស្តីពី ការធ្វើប៊ុកបៀលឌីង (Book-Building) និងការធ្វើបរិវិសកម្ម (Subscription) មូលបត្រកម្មសិទ្ធិ ដូចខាងក្រោម៖[38]

**ក. ដំណាក់កាលប៊ុកបៀលឌីង៖**

១) បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុន ធានាទិញមូលបត្រ ត្រូវរៀបចំធ្វើប៊ុកបៀលឌីង ដោយត្រូវធ្វើការប្រកាសផ្សព្វផ្សាយជាសាធារណៈ ដើម្បីអញ្ជើញវិនិយោគិនឱ្យចូលរួម។

២) ដើម្បីជំរុញឱ្យវិនិយោគិន ចូលរួមយ៉ាងសកម្មក្នុងដំណើរការប៊ុកបៀលឌីង ក្នុងគោលដៅធានាថា ថ្លៃមូលបត្រកម្មសិទ្ធិ បានឆ្លុះបញ្ចាំងតម្រូវការទីផ្សារ មូលបត្រកម្មសិទ្ធិដែលត្រូវដាក់ឱ្យធ្វើប៊ុកបៀលឌីងមានចំនួន ៧០ (ចិតសិប) ភាគរយ នៃមូលបត្រកម្មសិទ្ធិសរុប ដែលនៅសល់បន្ទាប់ពីការលៃបម្រុងទុកសម្រាប់លក់ជូនបុគ្គលិកករណីក្រុមហ៊ុនបោះផ្សាយមានគោលនយោបាយលើកទឹកចិត្ត តាមរយៈការលក់មូលបត្រកម្មសិទ្ធិជូនបុគ្គលិក និងវិនិយោគិនសក្តានុពល។ ដោយឡែក ចំណែកនៃមូលបត្រកម្មសិទ្ធិដែលនៅសល់ចំនួន ៣០ (សាមសិប) ភាគរយទៀត គឺត្រូវលៃបម្រុងទុកសម្រាប់ការធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង។

៣) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង (Book-Building Form) ដែលកំណត់ដោយគណៈកម្មការមូលបត្រកម្ពុជា។ វិនិយោគិន ត្រូវជ្រើសរើសថ្លៃមួយក្នុងចន្លោះថ្លៃ (Price Range) នៃថ្លៃមូលបត្រកម្មសិទ្ធិ ក្នុងឯកសារផ្តល់ព័ត៌មានដែលទទួលបានការអនុញ្ញាតជាគោលការណ៍ពីគណៈកម្មការមូលបត្រកម្ពុជា ព្រមទាំងចំនួនមូលបត្រកម្មសិទ្ធិ ដែលមានបំណងចង់ធ្វើបរិវិសកម្ម បន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីងនេះ។

[37] ប្រកាសលេខ ០០១ គ.ម.ក ចុះថ្ងៃទី១៥ ខែ មករា ឆ្នាំ២០១០របស់គណៈកម្មការមូលបត្រកម្ពុជា ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

[38] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ iii

៤) វិនិយោគិន ដែលបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង ត្រូវតម្កល់ប្រាក់កក់ស្មើនឹង ១០ (ដប់) ភាគរយ នៃថ្លៃមូលបត្រកម្មសិទ្ធិសរុប ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៥) ក្រោយដំណើរការប៊ុកបៀលឌីងត្រូវបានបញ្ចប់ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price) ដើម្បីស្នើសុំការសម្រេចពីគណៈកម្មការមូលបត្រកម្ពុជា និងភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះវិនិយោគិន ដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ។

៦) វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សំដៅដល់វិនិយោគិនដែលបានដាក់ថ្លៃ ខ្ពស់ជាង ឬស្មើ ថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ (Offering Price)។ បុគ្គលបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវគណនាថ្លៃមូលបត្រកម្មសិទ្ធិ ដែលត្រូវធ្វើសំណើលក់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យមភាគ (Weighted-Average) លើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិ ដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង។

៧) ថ្លៃមូលបត្រកម្មសិទ្ធិដែលបានគណនាក្នុងកថាខ័ណ្ឌទី ៦ ខាងលើ អាចត្រូវបានធ្វើការកែតម្រូវ (Adjustment) ដើម្បីឱ្យឆ្លើយតបទៅនឹងស្ថានភាពទីផ្សារ ដោយមានការសម្រេចពីគណៈកម្មការ មូលបត្រកម្ពុជា។

៨) ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការជូនដំណឹងភ្លាម ដល់វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនទទួលបានជោគជ័យ បន្ទាប់ពីគណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។ ជាមួយគ្នានេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្ទេរប្រាក់កក់ ១០ (ដប់) ភាគរយ ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង វិញ ឬរក្សាទុក ក្នុងករណីវិនិយោគិនមិនទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង មានបំណងបន្តធ្វើបរិវិសកម្ម។

### ខ. ដំណាក់កាលនៃការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ៖

៩) វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនដែលមានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់ បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលបានធ្វើ។

១០) វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្មអាច ធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមទំហំនៃ បរិវិសកម្មមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើ។

១១) វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដោយត្រូវតម្កល់ប្រាក់កក់យ៉ាងតិច ១០០ (មួយរយ) ភាគរយ នៃទំហំមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្ម។

១២) ករណីទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង វិនិយោគិនដែលទទួលជោគជ័យ ត្រូវដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្នុងរយៈពេលធ្វើបរិវិសកម្ម ករណីមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មលើសពីចំនួនមូលបត្រកម្មសិទ្ធិ ដែលបានលៃបម្រុងសម្រាប់ធ្វើ ប៊ុកបៀលឌីង ហើយមានវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ប៉ុន្តែមិនទាន់ដាក់ ពាក្យស្នើសុំធ្វើបរិវិសកម្ម វិនិយោគិននោះអាចមិនដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម និងអាចដកប្រាក់ កក់ ១០ (ដប់) ភាគរយវិញបាន។

១៣) ករណីការធ្វើបរិវិសកម្មដោយវិនិយោគិន ដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជីកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូន វិនិយោគិនដែលដាក់ពាក្យធ្វើបរិវិសកម្ម តាមមូលដ្ឋានសមាមាត្រ (Pro Rata)"។

១៤) ករណីវិនិយោគិនដែលទទួលបានជោគជ័យ ក្នុងប៊ុកបៀលឌីងមានចំនួនច្រើនលើសលប់ដោយមាន ទាំងវិនិយោគិនជានីតិបុគ្គល ឬ/និងវិនិយោគិនជារូបវន្តបុគ្គល ហើយបានដាក់ពាក្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិក្នុងចំនួនច្រើនលើសលប់ លើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុង សម្រាប់ធ្វើប៊ុកបៀលឌីង នោះគណៈកម្មការមូលបត្រកម្ពុជា អាចពិនិត្យធ្វើការបែងចែកក្នុងចំនួន មិនលើសពីពីរភាគបី (២/៣) នៃមូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងសម្រាប់វិនិយោគិន ដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមប៊ុកបៀលឌីង ហើយផ្ទេរទៅបន្ថែមលើចំណែកនៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ដើម្បីបែងចែកជូនដល់វិនិយោគិនដែលបានដាក់ពាក្យធ្វើប៊ុកបៀលឌីងក្នុងចំនួនដ៏ច្រើនលើសលប់នោះ។

១៥) បន្ទាប់ពីការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ ក្នុងករណីមានអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិតាមការដាក់ពាក្យស្នើសុំ នោះក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវធ្វើការផ្ទេរសាច់ប្រាក់ ដែលនៅសល់ពីការធ្វើបរិវិសកម្ម ជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធ នោះវិញ។

១៦) ករណីវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយការធ្វើបរិវិសកម្មនេះ មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុង សម្រាប់ធ្វើប៊ុកបៀលឌីង វិនិយោគិនទាំងអស់ដែលបានទទួលជោគជ័យក្នុងប៊ុកបៀលឌីង ត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិយ៉ាងតិចស្មើនឹងប្រាក់កក់ ១០ (ដប់) ភាគរយ។

១៧) ករណីការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនតិចជាងចំនួននៃមូលបត្រកម្មសិទ្ធិ ដែលបានលៃបម្រុងសម្រាប់ធ្វើប៊ុកបៀលឌីង ផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិ ជូនវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីងតាមពាក្យស្នើសុំ។ ចំនួនមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវធ្វើការបែងចែកទៅឱ្យវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីងនិងវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង។

១៨) ករណីចំនួនមូលបត្រកម្មសិទ្ធិសរុប ដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិន ដែលមិនបានទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនលើសពីចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនតាមវិធានសមាមាត្រ (Pro Rata)។

១៩) ករណីចំនួនមូលបត្រកម្មសិទ្ធិសរុប ដែលបានស្នើសុំធ្វើបរិវិសកម្ម ដោយវិនិយោគិន ដែលមិនបាន ចូលរួមក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង មានចំនួនទាបជាងចំនួននៃមូលបត្រកម្មសិទ្ធិ ដែលត្រូវបានលៃបម្រុងទុកសម្រាប់គោលដៅនេះ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវធ្វើការបែងចែកមូលបត្រកម្ម សិទ្ធិជូនវិនិយោគិនទៅតាមពាក្យស្នើសុំធ្វើបរិវិសកម្ម ហើយមូលបត្រកម្មសិទ្ធិដែលនៅសល់ ត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ករណីវិនិយោគិនដែល ទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង បានធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ លើសពីចំនួនមូលបត្រ កម្មសិទ្ធិ ដែលត្រូវលៃបម្រុងទុកសម្រាប់ការធ្វើប៊ុកបៀលឌីង។

២០) ករណីមានមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ដូចមានចែងក្នុងគោលការណ៍ណែនាំនេះ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវទទួលទិញមូលបត្រកម្មសិទ្ធិ ដែលនៅសល់ទាំងអស់។

២១) ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពី ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្ម ហើយដាក់ជូន គ.ម.ក ភ្លាម ដើម្បីសុំការពិនិត្យ និងសម្រេច។

### ៣.៣.១. ដំណើរការធ្វើប៊ុកបៀលឌីង និងដំណើរការធ្វើបរិវិសកម្ម

#### ៣.៣.១.១. ដំណើរការធ្វើប៊ុកបៀលឌីង

យោងតាមគេហទំព័ររបស់ផ្សារមូលបត្រកម្ពុជា ដោយមានលោក ហ៊ឹ បារី អគ្គនាយក ក.ស.ភ. បាន បញ្ចេញរបាយការណ៍សង្ខេបអំពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូង កាលពីថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០១៥។ ការធ្វើប៊ុកបៀលឌីង គឺជាការស្ទាបស្ទង់ និងស្វែងរកអ្នកវិនិយោគជាយុទ្ធសាស្ត្រ (មានជំនាញ) មុន ពេលដែលក្រុមហ៊ុន ឬស្ថាប័នណាមួយមានបំណងក្នុងការបោះផ្សាយដំណើរការនៅក្នុងទីផ្សារធម្មតា។ ដំណើរ ការនៃការធ្វើប៊ុកបៀលឌីងត្រូវបានប្រព្រឹត្តឡើងនៅថ្ងៃទី ១០ ដល់ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៥ ដោយមានភាគ ហ៊ុនសម្រាប់ធ្វើប៊ុកបៀលឌីងរហូតដល់ ១.៣០៤.៥២៩ ភាគហ៊ុន និងមានចំនួនអ្នកចូលរួមក្នុងប៊ុកបៀលឌីង ១៥០ ដែលចំនួនអ្នកដែលចូលរួមទទួលបានជោគជ័យមានរហូតទៅដល់ ១០៩។ ដោយឡែកចំនួនភាគហ៊ុន ដែលទទួលបានជោគជ័យមានចំនួន ១.០៥៥.០០០ ភាគហ៊ុន ស្របនឹងអនុបាតនៃភាគហ៊ុនដែលទទួលបាន ជោគជ័យ ៨០,៨៧% ហើយចំនួនភាគហ៊ុនដែលនៅសល់ ២៤៩.៥២៩ ដែលតម្លៃមធ្យមក្នុងមួយភាគហ៊ុនស្មើ នឹង ៥.១២៦ រៀល។

តារាង៣.៨៖ ព័ត៌មានលម្អិតពីការធ្វើប៊ុកបៀលឌីង

| ប៊ុកបៀលឌីង | |
|---|---|
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ១៩-២២ តុលា ២០១៥ |
| ភាគហ៊ុនសម្រាប់ធ្វើប៊ុកបៀលឌីង | ១.៣០៤.៥២៩ |
| ចំនួនអ្នកចូលរួមក្នុងប៊ុកបៀលឌីង | ១៥០ |
| ចំនួនអ្នកចូលរួមដែលទទួលបានជោគជ័យ | ១០៩ |
| ចំនួនភាគហ៊ុនដែលទទួលបានជោគជ័យ | ១.០៥៥.០០០ |
| អនុបាតនៃភាគហ៊ុនដែលទទួលបានជោគជ័យ | ៨០,៨៧% |
| ចំនួនភាគហ៊ុនដែលនៅសល់ | ២៤៩.៥២៩ |
| ថ្លៃមធ្យម | ៥.១២៦ រៀល |

#### ៣.៣.១.២. ដំណើរការធ្វើបរិវិសកម្ម

កំពង់ផែស្វយ័ត ភ្នំពេញ មានការគាំទ្រដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី បានជូនដំណឹងពីការធ្វើបរិវិសកម្មដែលជាដំណើរការសុំចុះឈ្មោះទិញមូលបត្រ នៅពេលដែលកំពង់ផែស្វយ័ត ភ្នំពេញ ធ្វើសំណើរលក់ជាសាធារណៈ។ ការធ្វើបរិវិសកម្មនេះធ្វើឡើងចាប់ពីថ្ងៃទី

១២ និងត្រូវបានបញ្ចប់នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០១៥។ ភាគហ៊ុនសរុបសម្រាប់ធ្វើបរិវិសកម្មមានចំនួន ៤.១៣៦.៨៧៣ ភាគហ៊ុន និងមានចំនួនអ្នកចូលរួមក្នុងការធ្វើបរិវិសកម្ម ៣៩២។ ទន្ទឹមនឹងនេះអ្នកដែលបានចូលរួមទទួលបានជោគជ័យទាំងអស់គ្នាសរុប ៣៩២ ដែលគិតជាភាគហ៊ុនមានចំនួន ៤.១៣៦.៨៧៣ នៃភាគហ៊ុនស្របនឹងអនុបាតនៃភាគហ៊ុនដែលទទួលបានជោគជ័យស្មើនឹង ១០០% ដែលថ្លៃបោះផ្សាយមានតម្លៃ ៥.១២០ រៀល។

តារាង៣.៩៖ ព័ត៌មានលម្អិតពីការធ្វើបរិវិសកម្ម

| **បរិវិសកម្ម** | |
|---|---|
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ១២-១៧ វិច្ឆិកា ២០១៥ |
| ភាគហ៊ុនសម្រាប់ធ្វើបរិវិសកម្ម | ៤.១៣៦.៨៧៣ |
| ចំនួនអ្នកចូលរួមក្នុងបរិវិសកម្ម | ៣៩២ |
| ចំនួនអ្នកចូលរួមដែលទទួលបានជោគជ័យ | ៣៩២ |
| ចំនួនភាគហ៊ុនដែលទទួលបានជោគជ័យ | ៤.១៣៦.៨៧៣ |
| អនុបាតនៃភាគហ៊ុនដែលទទួលបានជោគជ័យ | ១០០% |
| ថ្លៃបោះផ្សាយ | ៥.១២០ រៀល |

#### ៣.៣.១.៣. ការធ្វើបរិវិសកម្ម

**ការបែងចែកភាគហ៊ុន**

| **ចំណាត់ថ្នាក់** | **ព័ត៌មានលម្អិត** |
|---|---|
| ចំនួនភាគហ៊ុនបោះផ្សាយសរុប | ៤.១៣៦.៨៧៣ (២០% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត) |
| ចំនួនភាគហ៊ុនបម្រុងទុកសម្រាប់បុគ្គលិក | ៤១៣.៦៨៧ (១០% នៃភាគហ៊ុនបោះផ្សាយសរុប ) |
| ចំនួនភាគហ៊ុនបម្រុងទុកសម្រាប់វិនិយោគិនសក្តានុពល | ១.៨៥៩.៥៧៣ (៤៥%នៃភាគហ៊ុនបោះផ្សាយសរុប) |

## ៣.៤. រចនាសម្ព័ន្ធនៃមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ

### ៣.៤.១. រយៈនៃផាប់ប្លិកហ្លូត (Public Floats) និងឡុកអាប់ (Lock-up)

រចនាសម្ព័ន្ធកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតមុន និងក្រោយការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង៖[39]

តារាង៣.១០៖ ព័ត៌មានលម្អិតពីផាប់ប្លិកហ្លូត និងឡុកអាប់

| ប្រភេទភាគហ៊ុនិក | | មុនបោះផ្សាយ | | ក្រោយបោះផ្សាយ | | សម្គាល់ |
|---|---|---|---|---|---|---|
| | | ចំនួនមូលបត្រកម្មសិទ្ធិ | កម្មសិទ្ធិ (%) | ចំនួនមូលបត្រកម្មសិទ្ធិ | កម្មសិទ្ធិ (%) | |
| ឡុកអាប់ | ភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិច្រើនជាងគេ | ១៦.៥៤៧.៤៩២ | ១០០% | ១៦.៥៤៧.៤៩២ | ៨០% | ១ឆ្នាំ |
| | **សរុបរង** | **១៦.៥៤៧.៤៩២** | **១០០%** | **១៦.៥៤៧.៤៩២** | **៨០%** | |
| ហ្លូតសេរី | មូលបត្រកម្មសិទ្ធិលៃបម្រុងទុកសម្រាប់មន្ត្រីនិយោជិត | - | - | ៤១៣.៦៨៧ | ២% | |
| | វិនិយោគិនសាធារណៈ | - | | ៣.៧២៣.១៨៦ | ១៨% | |
| | **សរុបរង** | - | **១០០%** | **៤.១៣៦.៨៧៣** | **២០%** | |
| **សរុប** | | **១៦.៥៤៧.៤៩២** | **១០០%** | **២០.៦៨៤.៣៦៥** | **១០០%** | |

ព័ត៌មានអំពីឡុកអាប់ដូចជា៖ ឈ្មោះភាគហ៊ុនិក ចំនួនមូលបត្រកម្មសិទ្ធិ និងរយៈពេលឡុកអាប់

[39] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ២៩

តារាង៣.១១៖ ព័ត៌មានលម្អិតពីឡុកអាប់

| ឈ្មោះភាគហ៊ុនិក | លេខអត្ត សញ្ញាណ | ចំនួនមូលបត្រ កម្មសិទ្ធិកាន់កាប់ | ចំនួនមូលបត្រ កម្មសិទ្ធិឡុកអាប់ | រយៈពេលឡុក អាប់ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រាជរដ្ឋាភិបាល ដែលតំណាង ដោយក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | | ១៦.៥៤៧.៤៩២ | ១៦.៥៤៧.៤៩២ | ១ឆ្នាំ | ភាគហ៊ុនិក កាន់កាប់ភាគ ហ៊ុនមានសិទ្ធិ បោះចំនួន ច្រើនលើស លប់ |

## ៣.៥. ការចំណាយពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លើកដំបូង និងចំណាយពាក់ព័ន្ធនឹងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន. ម. ក

### ៣.៥.១. ចំណាយសរុបពាក់ព័ន្ធនឹងសេវាធានាទិញមូលបត្រ

ក.ស.ភ ចំណាយសរុប ៣.០២៨.៥០០.០០០ (៧៥០.០០០ ដុល្លារអាមេរិក) សម្រាប់ការចំណាយពាក់ព័ន្ធនឹងការធានាទិញមូលបត្រ។[40] ***សម្គាល់៖*** អត្រាប្តូរប្រាក់ ១ ដុល្លារ= ៤.០៣៨ រៀល

### ៣.៥.២. ចំណាយពាក់ព័ន្ធនឹងការចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក

ក.ស.ភ.ត្រូវបានបង់ថ្លៃចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក ចំនួន ១២.០០០.០០០ រៀល។

### ៣.៥.៣. ចំណាយពាក់ព័ន្ធនឹងការចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក

ក.ស.ភ ត្រូវបានបង់ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក ចំនួន ៤.០០០.០០០ រៀល និងថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក ចំនួនប្រហែល ៣៤.៥៣៣.៨៩៨ រៀល។

[40] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៣២-៣៣

### ៣.៥.៤. ចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន

ក.ស.ភ ត្រូវបង់ចំណាយលើការបោះពុម្ពព័ត៌មានប្រហែល ៣៥.៨៣៣.២១២ រៀល និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មានប្រហែល ១៨១.០០៥.៥៧១ រៀល។

### ៣.៥.៥. ការចំណាយផ្សេងៗ

ចំណាយដែលបង្ហាញខាងក្រោមនឹងបង្ហាញក្នុងឯកសារផ្តល់ព័ត៌មានបន្ថែម។

- ថ្លៃសេវារក្សាទុកមូលបត្រកម្មសិទ្ធិ៖ ៤.៦៨០.០០០ រៀល
- ចំណាយលើកម្រៃភ្នាក់ងារបញ្ជិកាមូលបត្រ៖ ៤.១៩៤.៦០៧ រៀល (១.០៣៩ ដុល្លារ)
- ចំណាយលើសេវាប្រឹក្សាផ្នែកច្បាប់៖ ២០២.៨៨៩.៣១០ រៀល (៥០.២៤៥ ដុល្លារ)
- ចំណាយលើសេវាប្រឹក្សាផ្នែកគណនេយ្យ៖ ១៥៩៥០១០០ រៀល (៣៩.៥០០ ដុល្លារ)
- ចំណាយលើសេវាវាយតម្លៃទ្រព្យសកម្ម៖ ១៩.១៨៧.៨៤២ រៀល (៤.៧៥២ ដុល្លារ)

*__សម្គាល់៖__ អត្រាប្តូរប្រាក់ ១ ដុល្លារ=៤.០៣៨ រៀល

## ៣.៦. ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

តាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសារធារណៈលើកដំបូង ដែលមានចំនួន ៤.១៣៦.៨៧៣ មូលបត្រកម្មសិទ្ធិ មានសិទ្ធិបោះឆ្នោតប្រភេទ "ក" ដែលមានថ្លៃលក់មូលបត្រស្មើនឹង ៥.១២០ រៀល (១,២៥៦ ដុល្លារអាមេរិក) ក.ស.ភ រំពឹងថានឹងទទួលបានសាច់ប្រាក់សុទ្ធ ពីការបោះផ្សាយប្រមាណ ១៧.៤៩៤.៥៦៤.៣២១ រៀល (៤.២៨១.០០៧ ដុល្លារអាមេរិក) ក្រោយពេលដកកម្រៃចុះបញ្ជីឯកសារផ្តល់ព័ត៌មាន កម្រៃចុះបញ្ជីលក់មូលបត្រក្នុងផ្សារមូលបត្រ កម្រៃរក្សាទុកមូលបត្រ និងកម្រៃសេវាប្រឹក្សាផ្សេងៗ (សេវាធានាទិញមូលបត្រ សេវាប្រឹក្សាផ្នែកគណនេយ្យ សេវាប្រឹក្សាផ្នែកច្បាប់ និងសេវាដទៃទៀតដែលពាក់ព័ន្ធនឹងការបោះផ្សាយ)។ ក.ស.ភ គ្រោងនឹងប្រើប្រាស់សាច់ប្រាក់សុទ្ធដែលបានមកពី ការបោះផ្សាយលក់មូលបត្រនេះដើម្បី៖[41]

- ទទួលបានមូលធនវិនិយោគបន្ថែម សម្រាប់ការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧ ជំហានទី២ និងឧបករណ៍លើកដាក់ទំនិញ

[41] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៥២-៥៣

- ប្រសិនបើមូលធន ដែលទទួលបានពីការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង នៅសល់ពីការវិនិយោគ ក.ស.ភ នឹងប្រើប្រាស់មូលធននេះ សម្រាប់ធ្វើជាទុនបង្វិល និងគោលបំណងអាជីវកម្មទូទៅផ្សេងទៀតរបស់ ក.ស.ភ។

ក.ស.ភ គ្រោងនឹងដាក់សាច់ប្រាក់សុទ្ធទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនេះក្នុងទម្រង់ជាបញ្ញើនានានៅធនាគារមួយចំនួន ឬសន្សំរយៈពេលខ្លី មុនពេលប្រើប្រាស់សាច់ប្រាក់ទាំងនោះក្នុងកម្មវត្ថុដូចបានរៀបរាប់ខាងលើ។

## សាច់ប្រាក់សុទ្ធពីការបោះផ្សាយ៖

តារាង៣.១២៖ ព័ត៌មានលម្អិតពីសាច់ប្រាក់សុទ្ធពីការបោះផ្សាយ

| បរិយាយ | ប្រាក់រៀល | ប្រាក់ដុល្លារ |
|---|---|---|
| សាច់ប្រាក់សុទ្ធពីការបោះផ្សាយមុនពេលដកកម្រៃនានា | ២១.១៨០.៧៨៩.៧៦០ | ៥.១៩៣.៩១៦ |
| កម្រៃចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | ១២.០០០.០០០ | ២.៩៧២ |
| ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់ | ៤.០០០.០០០ | ៩៩១ |
| ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់ | ៣៤.៥៣៣.៨៩៨ | ៨.៥៥២ |
| កម្រៃរក្សាទុកមូលបត្រ | ៤.៦៨០.០០០ | ១.១៥៩ |
| កម្រៃសេវាធានាទិញទុកមូលបត្រ | ៣.០២៨.៥០០.០០០ | ៧៥០.០០០ |
| កម្រៃសេវាប្រឹក្សាផ្នែកគណនេយ្យ | ១៥៩.៥០១.០០០ | ៣៩.៥០០ |
| កម្រៃសេវាប្រឹក្សាផ្នែកច្បាប់ | ២០២.៨៨៩.៣១០ | ៥០.២៤៥ |
| កម្រៃសេវាភ្នាក់ងារបញ្ជិកាមូលបត្រ | ៤.១៩៤.៦០៧ | ១.០៣៩ |
| កម្រៃសេវាវាយតម្លៃទ្រព្យសកម្ម | ១៩.១៨៧.៨៤២ | ៤.៧៥២ |
| ចំណាយលើការបោះពុម្ព និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន | ២១៦.៨៣៨.៧៨៣ | ៥៣.៧០០ |
| **សាច់ប្រាក់សុទ្ធពីការបោះផ្សាយបន្ទាប់ដកកម្រៃនានា** | **១៧.៤៩៤.៤៦៤.៣២១** | **៤.២៨១.០០៧** |

## ៣.៧. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

តារាង៣.១៣៖ ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

| ក្រុមវិនិយោគិន | ចំនួនបែងចែក | អនុបាតបែងចែក |
|---|---|---|
| មូលបត្រកម្មសិទ្ធិលៃបម្រុងទុកសម្រាប់លក់ជូននិយោជិត | ៤១៣.៦៨៧ | ១០% |
| វិនិយោគិនសក្តានុពល | ១.៨៥៩.៥៧៣ | ៤៤,៩៥% |
| វិនិយោគិនដែលទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង | ១.០៥៥.០០០ | ២៥,៥០% |
| វិនិយោគិនក្នុងបរិវីសកម្ម | ៨០៨.៦១៣ | ១៩,៥៥% |
| **សរុប** | **៤.១៣៦.៨៧៣** | **១០០%** |

យោងតាមប្រការ ៣៧ នៃប្រកាសលេខ ០០១ គ.ម.ក ប្រ.ក ចំនួនមូលបត្រស្មើនឹង ២០% នៃ ចំនួនមូលបត្រកម្មសិទ្ធិលៃបម្រុងទុកសម្រាប់វិនិយោគិនក្នុងប៊ុកបៀលឌីង ត្រូវបែងចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរ។[42] ចំណែកឯ មូលបត្រកម្មសិទ្ធិចំនួន ៨០% ដែលនៅសល់ ត្រូវបែងចែកទៅឱ្យវិនិយោគិន សញ្ជាតិខ្មែរ និងវិនិយោគិនមិនមែនសញ្ជាតិខ្មែរ ទៅតាមវិធានសមាមាត្រ ដោយស្របតាមប្រកាស និងការណែនាំរបស់ គ.ម.ក។

### ៣.៧.១ គម្រោងវិនិយោគ

ក.ស.ភ កំពុងមានគម្រោងវិនិយោគមួយចំនួនដែលបានធ្វើផែនការរយៈពេលវែង និងរយៈពេលខ្លី។ ចំណតផែកុងតឺន័រ LM១៧ ជំហានទី ២ និងបំពាក់ឧបករណ៍លើកដាក់ទំនិញ គឺជាគម្រោងវិនិយោគ អាទិភាពដើម្បីបង្កើននូវសមត្ថភាពផែ និងបង្កើននូវទីលានស្តុកកុងតឺន័របន្ថែមទៀត។ ការវិនិយោគទាំងអស់នេះ ធ្វើឡើងដោយស្របទៅនឹងកំណើននៃតម្រូវការរបស់អតិថិជនចំពោះសេវាកម្មផែ។ ព័ត៌មាន បន្ថែមសូមពិនិត្រមើលផ្នែកឧបសម្ព័ន្ធទី១ ចំណុច ខ-៥-ផែនការណ៍អាជីវកម្ម។[43]

[42] ប្រកាសលេខ ០០១ គ.ម.ក ចុះថ្ងៃទី ១៥ មករា ២០១០ ស្តីពីការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជំពូកទី ៣ ប្រការ ៣៧

[43] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៥៣

### ៣.៧.២ ព័ត៌មានស្តីអំពីកត្តាហានិភ័យ

កត្តាហានិភ័យទាំងឡាយ ដែលត្រូវបានបញ្ចូលក្នុងឯកសារផ្តល់ព័ត៌មាននេះ ត្រូវបានសម្រេចដោយផ្អែកលើភាពធ្ងន់ធ្ងរនៃផលប៉ះពាល់របស់ហានិភ័យទាំងនោះ ជាពិសេសៈ[44]

- ❖ ហានិភ័យដែលមិនអាចមានផលប៉ះពាល់ធ្ងន់ធ្ងរឡើយនៅពេលកើតឡើងតែឯង ប៉ុន្តែប្រសិនបើកើតឡើងព្រមគ្នា នោះផលប៉ះពាល់នៃហានិភ័យនោះអាចនឹងមានភាពធ្ងន់ធ្ងរ។
- ❖ ហានិភ័យ ដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរផ្សេងទៀតក្រៅពី ផលប៉ះពាល់លើលទ្ធផលដំណើរការ ឬហិរញ្ញវត្ថុរបស់ ក.ស.ភ។
- ❖ ហានិភ័យដែលអាចមិនមានភាពធ្ងន់ធ្ងរនាពេលនេះ តែអាចនឹងមានភាពធ្ងន់ធ្ងរនាពេលអនាគត លើ ក.ស.ភ ឬបុគ្គលដែលវិនិយោគលើការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ។

សូមបញ្ជាក់ថាអវត្តមាននៃទស្សនៈថ្នាក់គ្រប់គ្រង និងវិធានការទប់ទល់ចំពោះកត្តាហានិភ័យ ណាមួយមិនមែនជាទង្វើធ្វេសប្រហែសទេ។ ចំពោះកត្តាហានិភ័យជាច្រើន វិធានការទប់ទល់មិនអាចធ្វើទៅរួចទេ ឬគ្មានវិធានការណាមួយអាចទប់ទល់នឹងហានិភ័យដែលនឹងកើតឡើង។

- **ហានិភ័យអត្រាការប្រាក់៖** អាជីវកម្មផែត្រូវការគម្រោងចំណាយមូលធនជាប្រចាំ សម្រាប់ការវិនិយោគលើសម្ភារ។ ក.ស.ភ អាចមិនមានលទ្ធភាពធានាបាននូវហិរញ្ញប្បទានដែលត្រូវការ ឬទទួលបានលក្ខខណ្ឌហិរញ្ញប្បទានដែលសមស្រប។
- **ហានិភ័យអត្រាប្តូរប្រាក់៖** ចំណូលរបស់ ក.ស.ភ ជាប្រាក់ដុល្លារ ចំណែកការទូទាត់ចំណាយប្រតិបត្តិការជាប្រាក់រៀល។
- **ហានិភ័យឧស្សាហកម្ម និងហានិភ័យពាក់ព័ន្ធនឹងបរិបទជាតិ និងអន្តរជាតិ៖** អាជីវកម្ម និងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ភ ងាយទទួលរងឥទ្ធិពលពីស្ថានភាពសេដ្ឋកិច្ច នយោបាយ និងសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងតំបន់។
- **ហានិភ័យពាក់ព័ន្ធនឹងការប្រតិបត្តិការអាជីវកម្ម៖** ការប្រើប្រាស់ថាមពលអគ្គិសនីច្រើន និងការដាច់ចរន្តអគ្គិសនី អាចប៉ះពាល់ជាអវិជ្ជមានលើប្រតិបត្តិការអាជីវកម្មរបស់ ក.ស.ភ។

[44] ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ ទំព័រ ៥៤-៥៩

## ៣.៨. រចនាសម្ព័ន្ធភាគហ៊ុនិក

### ❖ ព័ត៌មានភាគហ៊ុនិក

តារាង៣.១៤៖ ព័ត៌មានលម្អិតភាគហ៊ុនិកទូទៅ

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុន | ចំនួនភាគហ៊ុន | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ១.៤០៤ | ១.០៧២.០៤០ | ៥១,៨% |
| | | នីតិបុគ្គល | ៤ | ៥២១.៩១១ | ២,៥២% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៣១៦ | ១.០៦៥.១០៧ | ៥១,៥% |
| | | នីតិបុគ្គល | ៤ | ១.៤៧៧.៨១៥ | ៧,១៤% |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១៦.៥៤៧.៤៩២ | ៨០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន[45] |

### ❖ ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនយោជិតរបស់កំពង់ផែស្វយ័តភ្នំពេញ

តារាង៣.១៥៖ ព័ត៌មានលម្អិតពីភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនយោជិត

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៥ | ១៣៦.៥០៧ | ០,៦៦% |
| បុគ្គលិកជាន់ខ្ពស់ | ១២ | ៦០.៤៨០ | ០,២៩% |
| និយោជិត | ៤៥ | ៤៤.០៥៦ | ០,២១% |
| ***សរុប*** | **៦២** | **២៤១.០៤៣** | **១,១៦%** |

[45] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ១០៦

### ៣.៨.១ សិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ស.ក.ភ ត្រូវបានបែងចែកជា ៣ ប្រភេទរួមមាន៖[46]

#### ៣.៨.១.១. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក"

**សិទ្ធិបោះឆ្នោត** ÷ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ ភាគ ហ៊ុន ស្មើនឹង ១សំឡេង។

**សិទ្ធិទទួលបានភាគលាភ** ÷ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិទទួលបានភាគលាភ ដែលត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ" ទៅតាមសមាមាត្រ នៃការកាន់កាប់ភាគហ៊ុនក្នុងប្រភេទនីមួយៗ។ ភាគលាភអប្បបរមាត្រូវបានធានាចំពោះតែភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" តែប៉ុណ្ណោះ។ ភាគលាភអប្បបរមានេះ ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំ អាចជា សាច់ប្រាក់ ឬជាភាគហ៊ុនក្នុងអត្រា ៥% នៃចំនួនភាគហ៊ុនប្រភេទ "ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវីឌិនដ៍ គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ ការបែងចែកភាគលាភអប្បបរមានេះត្រូវបាន ធានាក្នុងរយៈពេល ៥ឆ្នាំ គិតចាប់ពីពេលដែល ក. ស. ភ. បានចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា។ ការធានាភាគលាភ អប្បបរមាជូនភាគហ៊ុនិកប្រភេទ "ក" ត្រូវបានផ្ទេរចេញពីប្រាក់ចំណេញរក្សាទុកតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

(ភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ = ៥% x ចំនួនភាគហ៊ុនប្រភេទ "ក" សរុប ដែលបានកាន់កាប់ មុនថ្ងៃអិចឌីវីឌិនដ៍ x ថ្លៃ IPO)

ក្នុងករណី ក. ស. ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានាជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមា ត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទនៅថ្ងៃជួញដូរ ១ ថ្ងៃ មុនថ្ងៃ អិចឌីវីឌិនដ៍។

(ចំនួនភាគហ៊ុនអប្បបរមាត្រូវបានធានា = ភាគលាភអប្បរមាត្រូវបានធានា - ថ្លៃបិទនៅថ្ងៃជួញដូរ ១ ថ្ងៃ មុនថ្ងៃអិចឌីវីឌិនដ៍)

[46] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ១០៦-១០៨

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណា មួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានា នឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយ ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

**សិទ្ធិទទួលបានទ្រព្យសម្បត្តិ** ៖ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" មានសិទ្ធិទទួលទ្រព្យសម្បត្តិ របស់ ក. ស. ភ. ដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់អាជីវកម្ម ដោយត្រូវគោរពសិទ្ធិបុរិមា របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ"។

### ៣.៨.១.២. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ"

**សិទ្ធិបោះឆ្នោត** ៖ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញដោយ ១ ភាគហ៊ុន ស្មើនឹង ១សំឡេង។

**សិទ្ធិទទួលបានភាគលាភ** ៖ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិទទួលបានភាគលាភដែលត្រូវបែងចែកក្នុងចំណោមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ" ទៅតាមសមាមាត្រ នៃការកាន់កាប់ភាគហ៊ុនក្នុងប្រភេទនីមួយៗ។ ប៉ុន្តែភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មិនមានសិទ្ធិទទួលបានភាគលាភជាភាគហ៊ុនទេ ក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីពេលដែល ក. ស. ភ. បានចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា និងក្នុងករណីភាគលាភអប្បបរមាត្រូវបានធានា មិនទាន់បានបែងចែកពេញលេញជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនិកប្រភេទ "ក"។

**សិទ្ធិទទួលបានទ្រព្យសម្បត្តិ** ៖ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ខ" មានសិទ្ធិទទួលទ្រព្យសម្បត្តិរបស់ ក. ស. ក. ដែលនៅសល់បន្ទាប់ពីការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់អាជីវកម្ម ដោយត្រូវគោរពតាមសិទ្ធិបុរិមារបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ"។

### ៣.៨.១.៣. សិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ"

**សិទ្ធិបោះឆ្នោត** ៖ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ" ពុំមានសិទ្ធិបោះឆ្នោតឡើយ លើកលែងតែពាក់ព័ន្ធនឹងករណីណាមួយដូចខាងក្រោមនេះ៖

- ការធ្វើវិសោធនកម្មលក្ខន្តិកៈ ដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលទៅលើសិទ្ធិឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌដែលភ្ជាប់ទៅនឹងប្រភេទនៃភាគហ៊ុន របស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "គ"
- ការស្នើរួមបញ្ចូល ក. ស. ភ. ជាមួយនីតិបុគ្គលផ្សេងទៀត
- ការស្នើរំលាយ ក. ស. ក.។

**សិទ្ធិទទួលបានទ្រព្យសម្បត្តិ** ៖ ក្នុងករណីរំលាយក្រុមហ៊ុនដោយឆន្ទៈ ឬដោយច្បាប់ ភាគហ៊ុនិកដែលកាន់ កាប់ភាគហ៊ុនប្រភេទ "គ" មានសិទ្ធិបុរិមាក្នុងការទទួលបានទ្រព្យសម្បត្តិរបស់ ក. ស. ភ. ដែលសល់បន្ទាប់ពីការ ជម្រះបញ្ជី មុនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ" ដែលទទួលបាននូវការបែងចែក ឬ ទូទាត់ជាមុនស្មើនឹងចំនួនទឹកប្រាក់សរុបតាមចំនួនភាគហ៊ុនទឹកប្រាក់សរុបតាមចំនួនភាគហ៊ុនប្រភេទ "គ" ដែលគិតតាមតម្លៃចារឹកក្នុងមួយភាគហ៊ុន។

បើទ្រព្យសម្បត្តិដែលសល់បន្ទាប់ពីការជម្រះបញ្ជីក្រុមហ៊ុន មានមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងគ្រប់ចំនួន ដូចបានកំណត់ឱ្យភាគហ៊ុនប្រភេទ "គ" ទ្រព្យសម្បត្តិទាំងអស់នឹងត្រូវបែងចែកតែម្ចាស់ភាគហ៊ុនប្រភេទ "គ" ប៉ុណ្ណោះ។

សិទ្ធិ និងលក្ខណៈរបស់ប្រភេទភាគហ៊ុននីមួយៗ ដែលបានកំណត់ដូចខាងលើ អាចត្រូវបានកែប្រែដោយ សេចក្តីសម្រេច ពីរភាគបី របស់មហាសន្និបាតភាគហ៊ុនិក តាមសេចក្តីស្នើសុំរបស់ក្រុមប្រឹក្សាភិបាល។

### ៣.៨.១.៤. សិទ្ធិផ្សេងៗទៀតរបស់ភាគហ៊ុនិក

- **សិទ្ធិបុព្វក្រយ** ៖ ភាគហ៊ុនិកទាំងអស់ មានសិទ្ធិបុព្វក្រយក្នុងការទិញបានមុននូវភាគហ៊ុនថ្មី ដែលបោះផ្សាយលក់ដោយ ក. ស. ក. ស្របតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន ហើយដែលភាគហ៊ុនថ្មីទាំងនោះ ស្ថិតក្នុងប្រភេទតែមួយជាមួយនឹងភាគហ៊ុនដែលខ្លួនកំពុងកាន់កាប់។
- **សិទ្ធិទទួលព័ត៌មាន** ៖ ភាគហ៊ុនិកទាំងអស់ មានសិទ្ធិទទួលបានព័ត៌មានសាជីវកម្ម ដែលទាក់ទងនឹង ក. ស.ភ.។
- តាមបែបបទកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។
- សិទ្ធិផ្សេងៗទៀតរបស់ភាគហ៊ុនិក ដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។

### ៣.៨.២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្ត

សម្រាប់ឆ្នាំ ២០២៣ នេះ ភាគហ៊ុនិករបស់ ក. ស. ក. បានចូលរួមក្នុងមហាសន្និបាតលើកទី ៨ កាលពីថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ដើម្បីទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបានឆ្នាំ២០២២ និងទិសដៅអនុវត្តការងារបន្ត ឆ្នាំ២០២៣ ព្រមទាំងបានចូលរួមបោះឆ្នោតអនុម័ត លើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២២ និងការបោះឆ្នោតអនុម័តលើប្រាក់លាភការក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០២៣ និងឆ្នាំបន្តបន្ទាប់ទៀតរហូតបញ្ចប់អាណត្តិទី៨។[47]

[47] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ១០៩

ភាគហ៊ុនិកភាគតិចរបស់ ក. ស. ភ. ក៏ទទួលបានការការពារសិទ្ធិស្មើគ្នាៗដូចនឹងភាគហ៊ុនិកភាគច្រើនរបស់ ក. ស. ភ. ផងដែរ។

### ៣.៨.៣. មហាសន្និបាតភាគហ៊ុន

#### ៣.៨.៣.១. នីតិវិធីនៃការរៀបចំមហាសន្និបាតភាគហ៊ុន និងការបោះឆ្នោត

មហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើង ១ (មួយ) ឆ្នាំ ម្តងក្នុងអំឡុងត្រីមាសទី១ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធដែលកាលបរិច្ឆេទ និងរបៀបវារៈត្រូវសម្រេចដោយក្រុមប្រឹក្សាភិបាល។

មហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ អាចប្រព្រឹត្តទៅបាន ក្នុងករណីមានសេចក្តីស្នើសុំ ដែលកាន់កាប់ភាគហ៊ុន យ៉ាងតិចចំនួន ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនប្រភេទ "ក" និងប្រភេទ "ខ"។

សេចក្តីស្នើសុំកោះប្រជុំរបស់ភាគហ៊ុនិក ត្រូវផ្ញើជូនយ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃ មុនថ្ងៃប្រជុំ ទៅក្រុមប្រឹក្សាភិបាល ដោយមានចុះហត្ថលេខា និងភ្ជាប់របៀបវារៈជាមួយផង។

បើមហាសន្និបាតភាគហ៊ុនិក ពុំអាចប្រព្រឹត្តទៅបានតាមនីតិវិធី ដូចចែងខាងលើ នោះសមាជិកណាម្នាក់របស់ ភាហ៊ុនិកណាម្នាក់ដែលមានសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក ឬក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកណាម្នាក់ដែលមានសិទ្ធិ អាចស្នើសុំតុលាការឱ្យចាត់ចែងកោះប្រជុំមហាសន្និបាតភាគហ៊ុនិក តាមនីតិវិធីណាមួយដែលតុលាការពិចារណាឃើញថាសមស្រប។

មហាសន្និបាតភាគហ៊ុនិកត្រូវប្រព្រឹត្តទៅនៅទីស្នាក់ការចុះបញ្ជីរបស់ ក. ស. ភ. លើកលែងតែមានការសម្រេចផ្សេងពីនេះ ដោយក្រុមប្រឹក្សាភិបាល តាមកាលៈទេសៈតម្រូវ។

សេចក្តីជូនដំណឹងពីមហាសន្និបាតភាគហ៊ុនិក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវផ្ញើទៅភាគហ៊ុនិក តាមរយៈលិខិត ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬតាមគ្រប់មធ្យោបាយសមស្របណាមួយ ដោយមានបញ្ជាក់អំពី កាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈ។

សេចក្តីជូនដំណឹង ត្រូវផ្ញើទៅភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោត ទៅអភិបាល ទៅសវនករផ្ទៃក្នុង និងសវនករឯករាជ្យរបស់ ក.ស.ភ. យ៉ាងតិច ២១ (ម្ភៃមួយ) ថ្ងៃ មុនកាលបរិច្ឆេទរបស់មហាសន្និបាតភាគហ៊ុនិក។[48]

[48] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ១០៩-១១០

### ៣.៨.៣.២. ព័ត៌មានមហាសន្និបាតភាគហ៊ុន

តារាង៣.១៦៖ ព័ត៌មានលម្អិតពីមហាសន្និបាតភាគហ៊ុន

| ល.រ | កាលបរិច្ឆេទ | ប្រភេទនៃកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្ដីសម្រេច |
|---|---|---|---|---|---|
| ១. | ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០២៣ | សាមញ្ញ | ៥០+១ | - លទ្ធផលការងារប្រចាំឆ្នាំ២០២២ និងទិសដៅអនុវត្តការងារឆ្នាំ ២០២៣ សំណើសុំពិនិត្យ និងអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិកសម្រាប់ឆ្នាំ ២០២២<br>- សំណើសុំពិនិត្យ និងបោះឆ្នោត អនុម័តលើប្រាក់លាភការក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ ២០២៣ និងឆ្នាំបន្តបន្ទាប់ទៀតរហូតបញ្ចប់អាណត្តិទី៨។ | - ការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២២ ដល់ភាគហ៊ុនិក ប្រភេទ "ក" ចំនួន ៦,៧៥% ប្រាក់លាភការរបស់ក្រុមប្រឹក្សា<br>- សម្រាប់ឆ្នាំ២០២៣ និង ឆ្នាំបន្តបន្ទាប់ទៀត រហូតដល់ បញ្ចប់អាណត្តិទី៨ ដែលមានចំនួន ១.១៥២.០០0.000(មួយ ប៊ីលានមួយរយហាសិប ពីរលាន)រៀល/ឆ្នាំ។ |

### ៣.៨.៤. ការបែងចែកភាគលាភ

### ៣.៨.៤.១. គោលនយោបាយភាគលាភ

ដើម្បីលើកទឹកចិត្តដល់វិនិយោគិនដែលទិញភាគហ៊ុនប្រភេទ "ក" របស់ ក.ស.ភ. ក្រុមប្រឹក្សាភិបាលបានអនុម័ត គោលនយោបាយភាគលាភពិសេស ដែលធានានូវទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំ ស្មើនឹងចំនួន ៥% នៃទំហំវិនិយោគដោយគិតតាមថ្លៃមូលបត្រនៃ IPO សម្រាប់រយៈពេល ៥ ឆ្នាំ បន្ទាប់ពីការចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះគឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ "ក" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាលដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ "គ" មិនទទួល

បានការធានាភាគលាភនេះទេ។ ភាគលាភអប្បបរមានេះត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំ អាចជាសាច់ប្រាក់ ឬជាភាគហ៊ុន។[49]

ក្នុងករណីដែលភាគលាភអប្បបរមាត្រូវបានធានាជាសាច់ប្រាក់ គឺស្មើនឹងអត្រា ៥% នៃចំនួនភាគហ៊ុន ប្រភេទ "ក" សរុប ដែលបានកាន់កាប់មុនថ្ងៃអិចឌីវីឌិនដ៍ (Ex-Dividend Date) គុណនឹងថ្លៃធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

ប្រសិនបើភាគលាភអប្បបរមាត្រូវបានធានា ពុំអាចត្រូវបានបែងចែកពេញលេញក្នុងឆ្នាំសារពើពន្ធណាមួយទេ នោះចំណែកនៃភាគលាភអប្បបរមាត្រូវបានធានានឹងត្រូវបង្គរទៅឆ្នាំបន្ទាប់ ឬទៅពេលវេលាសមស្របណាមួយ ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។

ក្នុងករណីដែល ក.ស.ភ. បែងចែកភាគលាភអប្បបរមាត្រូវបានធានាជាភាគហ៊ុន នោះចំនួនភាគហ៊ុនអប្បបរមា ត្រូវបានធានា ត្រូវគណនាដោយយកភាគលាភអប្បបរមាត្រូវបានធានា ចែកនឹងថ្លៃបិទការជួញដូរ១ថ្ងៃនៅមុនថ្ងៃ អិចឌីវីឌិនដ៍ (Ex-Dividend Date)។

ក្រោយពីបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដោយក្រុមប្រឹក្សាភិបាល បើពិនិត្យឃើញថាមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលនៃ ក. ស. ភ. អាចសម្រេចបែងចែកប្រាក់ចំណេញនោះដើម្បី៖

- ទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន
- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុន ហើយប្រសិនបើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖
    - ថ្លែងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិតតាមលក្ខខណ្ឌខាងក្រោម៖
        - បើប្រាក់ចំណេញនៅសល់មានចំនួន ចាប់ពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ ក.ស.ភ. សរុបក្នុងឆ្នាំ នោះប្រាក់ថ្លែងសរសើរត្រូវស្មើនឹង ១ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗសរុបជាមធ្យមប្រចាំឆ្នាំ
        - បើប្រាក់ចំណេញនៅសល់មានចំនួនលើសពី១០% ដល់ ២០% នៃចំណាយដំណើការសរុបរបស់ ក. ស. ភ. ក្នុងឆ្នាំ នោះប្រាក់ថ្លែងសសើរត្រូវស្មើនឹង ២ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំ និងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ

[49] កំពង់ផែស្វយ័តភ្នំពេញ របាយការណ៍ប្រចាំឆ្នាំ ២០២៣ ទំព័រ ១១០-១១១

- បើប្រាក់ចំណេញលើសពី ២០% នៃចំណាយដំណើរការសរុបរបស់ ក. ស. ភ. ក្នុងឆ្នាំនោះ ប្រាក់ថ្លែងសសើរស្មើនឹង ៣ខែនៃប្រាក់បៀវត្សរបស់ថ្នាក់ដឹកនាំនិងនិយោជិត សរុបជាមធ្យមប្រចាំឆ្នាំ។

➢ បង្កើតមូលនិធិបម្រុងតាមច្បាប់ចំនួន ៥% និងមូលនិធិបម្រុងសេរីចំនួន ៥% នៃប្រាក់ចំណេញសុទ្ធ

➢ មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រត្តិការចំណាយនោះ

➢ ប្រាក់ចំណេញដែលសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភឱ្យភាគហ៊ុនិកទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

➢ ប្រាក់ចំណេញនៅសល់ចុងក្រោយ ត្រូវបង្វិលចូលមូលនិធិអភិវឌ្ឍន៍ ក. ស. ភ.។

#### ៣.៨.៤.២. ព័ត៌មានអំពីកាលបរិច្ឆេទបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

តារាង៣.១៧៖ ព័ត៌មានលម្អិតពីកាលបរិច្ឆេទបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ឆ្នាំ ២០២២ | ឆ្នាំ ២០២១ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ១២ ឧសភា ២០២៣ | ១១ ឧសភា ២០២២ | ៥ ឧសភា ២០២១ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ២៥ ឧសភា ២០២៣ | ២៤ ឧសភា ២០២២ | ២០ ឧសភា ២០២១ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ០៥ មិថុនា ២០២៣ | ០២ មិថុនា ២០២២ | ២៨ ឧសភា ២០២១ |

## ៣.៩. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ

### ៣.៩.១. មូលធនូបនីយកម្មទីផ្សារ

មូលធនូបនីយកម្មទីផ្សារ អាចឱ្យយើងដឹងពីនិន្នាការឡើងចុះនៃថ្លៃភាគហ៊ុន ព្រោះថាមូលធនូបនីយកម្មត្រូវបានគណនាដោយយកចំនួនភាគហ៊ុនចុះបញ្ជីសរុបទៅគុណនឹងថ្លៃបច្ចុប្បន្ននៃភាគហ៊ុនរបស់ក្រុមហ៊ុននោះ។

តារាង៣.១៨៖ ព័ត៌មានលម្អិតពីមូលធនបូបនីយកម្មទីផ្សារ

| ត្រីមាស ឆ្នាំ ២០២៣ | មូលធនូបនីយកម្ម (លានរៀល) | បរិមាណបម្រែបម្រួល | អត្រាបម្រែបម្រួល |
|---|---|---|---|
| ត្រីមាសទី១ | ៣០៦.១២៨,៦០ | | |
| ត្រីមាសទី២ | ២៩៦.២០០,១១ | -៩.៩២៨,៤៩ | -៣,២៤ |
| ត្រីមាសទី៣ | ២៩១.២៣៥,៨៦ | -៤.៩៦៤,២៥ | -១,៦៨ |
| ត្រីមាសទី៤ | ២៨៩.៥៨១ | -១.៦៥៤,៨៦ | -០,៥៧ |

ប្រភព៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសឆ្នាំ ២០២៣ (មើលឧបសម្ព័ន្ធទី៣ )




ក្រាហ្វិកទី៥៖ ព័ត៌មានលម្អិតនៃមូលធនូបនីយកម្មទីផ្សាររបស់ ក.ស.ភ.

**បកស្រាយ៖** តាមតារាងខាងលើយើងឃើញថា នៅត្រីមាសទី១ នៃឆ្នាំ ២០២៣ មូលធនូបនីយកម្មរបស់ ក.ស.ភ . មានចំនួន ៣០៦.១២៨,៦០ លានរៀល និងត្រីមាសទី២ មានចំនួន ២៩៦.២០០,១១ លានរៀល ដែលមានការធ្លាក់ចុះចំនួន ៩.៩២៩ លានរៀល ដែលស្មើនឹង ៣,២៤%។ ចំណែកឯត្រីមាសទី៣ មូលធនូបនីយកម្មមានប្រហែល ២៩១.២៣៦ លានរៀល ដែលមានការធ្លាក់ចុះចំនួន ៤.៩៦៤ លានរៀល ដែលស្មើនឹង ១,៦៨% បើធៀបនឹងត្រីមាសទី២ ។ រីឯត្រីមាសទី៤ មានចំនួន ២៨៩.៥៨១ លានរៀល ដែលយើងឃើញថាវានៅតែបន្តធ្លាក់ចុះបើធៀបទៅនឹងត្រីមាសទី៣ ប៉ុន្តែធ្លាក់ចុះមិនច្រើនប៉ុន្មានទេគឺធ្លាក់ចុះចំនួន ១.៦៥៥ លានរៀល ដែលត្រូវនឹង ០,៥៧%។

### ៣.៩.២. ទំហំជួញដូរ (ភាគហ៊ុន)

តារាង៣.១៩៖ ព័ត៌មានលម្អិតពីទំហំជួញដូររបស់ ក.ស.ភ.

| ត្រីមាស ឆ្នាំ២០២៣ | ទំហំជួញដូរ (ភាគហ៊ុន) | បរិមាណបម្រែបម្រួល | អត្រាបម្រែបម្រួល |
|---|---|---|---|
| ត្រីមាសទី១ | ៥០.៣៧៧ | | |
| ត្រីមាសទី២ | ៦២.៩១៤ | ១២.៥៣៧ | ២៤,៨៩ |
| ត្រីមាសទី៣ | ១៧.៧៣៩ | -៤៥.១៧៥ | -៧១,៨០ |
| ត្រីមាសទី៤ | ១១.៥៥៨ | -៦.១៨១ | -៣៤,៨៤ |

ប្រភព៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសឆ្នាំ ២០២៣ (មើលឧបសម្ព័ន្ធទី៣ )




ក្រាហ្វិកទី៦៖ ទំហំនៃការជួញដូរភាគហ៊ុនរបស់ ក.ស.ភ. ឆ្នាំ២០២៣

**បកស្រាយ៖** តាមតារាងខាងលើ នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣ ទំហំនៃការជួញដូរមូលបត្ររបស់ក.ស.ភ. មានចំនួន ៥០.៣៧៧ ភាគហ៊ុន ហើយនៅត្រីមាសទី២ ទំហំនៃការជួញដូរមានចំនួន ៦២.៩១៤ ភាគហ៊ុន ដោយកើនឡើងចំនួន ១២.៥៣៧ ភាគហ៊ុន បើធៀបនិងត្រីមាសទី១។ ជាមួយគ្នានេះដែរ នៅត្រីមាសទី៣ ទំហំនៃការជួញដូរមានការថយចុះយ៉ាងខ្លាំងចំនួន ៤៥.១៧៥ ភាគហ៊ុន ដែលត្រូវនឹង ៧១,៨០% ហើយនៅត្រីមាសទី៤ បើធៀបនិងត្រីមាសទី៣ ទំហំនៃការជួញដូរមូលបត្រកម្មសិទ្ធិមានចំនួន ១១.៥៥៨ គឺមានការធ្លាក់ចុះចំនួន ៦.១៨១ ភាគហ៊ុន ស្មើនិង ៣៤,៨៤%។

### ៣.៩.៣. ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន)

តារាង៣.២០៖ ព័ត៌មានលម្អិតនៃទំហំជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣

| ត្រីមាស ឆ្នាំ២០២៣ | ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ | បរិមាណបម្រែបម្រួល | អត្រាបម្រែបម្រួល |
|---|---|---|---|
| ត្រីមាសទី១ | ៧៨៧ | | |
| ត្រីមាសទី២ | ១.០៣១ | ២៤៤ | ៣១ |
| ត្រីមាសទី៣ | ២៧៧ | -៧៥៤ | -៧៣,១៣ |
| ត្រីមាសទី៤ | ១៨៩ | -៨៨ | -៣១,៧៧ |

ប្រភព៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសឆ្នាំ ២០២៣ (មើលឧបសម្ព័ន្ធទី៣ )




ក្រាហ្វិកទី៧៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣

**បកស្រាយ៖** តាមតារាងខាងលើក្នុងត្រីមាសទី១ នៃឆ្នាំ២០២៣ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃលើមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ មានចំនួន ៧៨៧ ភាគហ៊ុន ហើយនៅត្រីមាសទី២ ទំហំនៃការជួញដូរជាមធ្យមប្រចាំថ្ងៃមានការកើនឡើងចំនួន ២៤៤ ភាគហ៊ុន ដែលស្មើនឹង ៣១%។ នៅត្រីមាសទី៣ គឺមានការថយចុះចំនួន ៧៥៤ ភាគហ៊ុន ដែលស្មើនឹង ៧៣,១៣% បើប្រៀបធៀបនឹងត្រីមាសទី២។ ជាមួយគ្នានេះដែរនៅត្រីមាសទី៤ វាក៏នៅតែបន្តថយចុះចំនួន ៨៨ ភាគហ៊ុន ដែលស្មើនឹង ៣១,៧៧% ធៀបនឹងត្រីមាសទី៣។

### ៣.៩.៤. តម្លៃជួញដូរ (លានរៀល)

តារាង៣.២១៖ តម្លៃជួញដូររបស់ ក.ស.ភ. ឆ្នាំ២០២៣

| ត្រីមាស ឆ្នាំ២០២៣ | តម្លៃជួញដូរ (លានរៀល) | បរិមាណបម្រែបម្រួល | អត្រាបម្រែបម្រួល |
|---|---|---|---|
| ត្រីមាសទី១ | ៧៤១,០៣ | | |
| ត្រីមាសទី២ | ៨៥៥,៨៦ | ១១៤,៨៣ | ១៥,៤៩ |
| ត្រីមាសទី៣ | ២៤៩,៧១ | -៦០៦,៧១ | -៧០,៨២ |
| ត្រីមាសទី៤ | ១៥៩,៦៦ | -៩០,៦៦ | -៣៦,០៦ |

ប្រភព៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសឆ្នាំ ២០២៣ (មើលឧបសម្ព័ន្ធទី៣ )




ក្រាហ្វិកទី៨៖ តម្លៃជួញដូររបស់ ក.ស.ភ. ឆ្នាំ២០២៣

**បកស្រាយ៖** តាមតារាងខាងលើយើងសង្កេតឃើញថា នៅក្នុងឆ្នាំ ២០២៣ ត្រីមាសទី ១ តម្លៃជួញដូរលើមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័តភ្នំពេញ មានចំនួន ៧៤១,០៣ លានរៀល។ នៅត្រីមាសទី២ តម្លៃជួញដូរបានកើនឡើងយ៉ាងខ្លាំងបើធៀបទៅនឹងត្រីមាសទី ១ រហូតដល់ ១១៤,៨៣ លានរៀលដែលស្មើនឹង ១៥,៤៩%។ ប៉ុន្តែ នៅត្រីមាសទី៣ តម្លៃជួញដូរមានការធ្លាក់ចុះយ៉ាងកំហុគ បើធៀបនឹងត្រីមាសទី២ គឺមានចំនួន ៦០៦,១៥ លានរៀល ដែលស្មើនឹង ៧០,៨២%។ រីឯនៅត្រីមាសទី៤ ក៏នៅតែបន្តថយចុះដដែល ដែលមានចំនួន ៩០,៦៦ លានរៀលស្មើនឹង ៣៦,០៦% ធៀបនឹងត្រីមាសទី៣។

### ៣.៩.៥. តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល)

តារាង៣.២២៖ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣

| ត្រីមាស ឆ្នាំ ២០២៣ | តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ | បរិមាណបម្រែបម្រួល | អត្រាបម្រែបម្រួល |
|---|---|---|---|
| ត្រីមាសទី១ | ១១,៥៨ | | |
| ត្រីមាសទី២ | ១៤,០៣ | ២,៤៥ | ២១,១៦ |
| ត្រីមាសទី៣ | ៣,៩០ | - ១០,១៣ | - ៧២,២០ |
| ត្រីមាសទី៤ | ២,៦២ | - ១,២៨ | - ៣២,៨២ |

ប្រភព៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រ ប្រចាំត្រីមាសឆ្នាំ ២០២៣ (មើលឧបសម្ព័ន្ធទី៣ )




ក្រាហ្វិកទី៩៖ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃរបស់ ក.ស.ភ. ឆ្នាំ២០២៣

**បកស្រាយ៖** តាមតារាងខាងលើ យើងអាចឃើញថា ក្នុងត្រីមាសទី ១ នៃឆ្នាំ ២០២៣ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃនៃមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័ត ភ្នំពេញ មានចំនួន ១១,៥៨ លានរៀល។ ចំណែកឯ នៅត្រីមាសទី ២ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃបានកើនឡើង បើធៀបទៅនឹងត្រីមាសទី ១ ចំនួន ២,៤៥ លានរៀលដែលស្មើនឹង ២១,១៦%។ ហើយនៅត្រីមាសទី៣ សញ្ញាអវិជ្ជមានក៏បានកើតឡើង ដោយតម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃមានការធ្លាក់ចុះយ៉ាងខ្លាំង បើធៀបនឹងត្រីមាសទី២ គឺមានចំនួន ១០,១៣ លានរៀល ដែលស្មើនឹង ៧២,២០%។ នៅត្រីមាសទី៤ ក៏នៅតែបន្តថយចុះ ចំនួន ១,២៨ លានរៀលស្មើនឹង ៣២,៨២%។[50]

[50] ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រប្រចាំត្រីមាស ឆ្នាំ២០២៣ លើគេហទំព័រ និយ័តករមូលបត្រកម្ពុជា - ន.ម.ក. (serc.gov.kh)

❖ **យោងតាមការវិភាគខាងលើ យើងអាចទាញសន្និដ្ឋានបានថា៖**

- នៅត្រីមាសទី២ បើប្រៀបធៀបនឹងត្រីមាសទី១ ឃើញថា ចំនួនមូលធនូបនីយកម្ម គឺមានការធ្លាក់ចុះ ដោយឡែក ទំហំជួញដូរ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ តម្លៃជួញដូរ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ គឺមានការកើនឡើង។
- នៅត្រីមាសទី៣ បើប្រៀបធៀបនឹងត្រីមាសទី២ ឃើញថា ចំនួនមូលធនូបនីយកម្ម ទំហំជួញដូរ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ តម្លៃជួញដូរ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ គឺមានការធ្លាក់ចុះ ។
- នៅត្រីមាសទី៤ បើប្រៀបធៀបនឹងត្រីមាសទី៣ ឃើញថា ចំនួនមូលធនូបនីយកម្ម ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ តម្លៃជួញដូរ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ នៅតែបន្តថយចុះ។

សរុបមកយើងអាចឃើញថា ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័តភ្នំពេញ សម្រាប់រយៈពេល ៤ ត្រីមាស ក្នុងឆ្នាំ ២០២៣ គឺត្រីមាសទី ២ មានលក្ខណៈល្អប្រសើរជាងគេ បើធៀបនឹងត្រីមាសទី១ ត្រីមាសទី៣ និងត្រីមាសទី៤។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់កំពង់ផែស្វយ័តភ្នំពេញ រួចមក ក្រុមយើងខ្ញុំបានសង្កេតឃើញថា ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ ពិតជាស្មុគស្មាញ និងតម្រូវឱ្យមានការរៀបចំជាច្រើនដំណាក់កាលដើម្បីសម្រេចបានយ៉ាងរលូន និងជោគជ័យ។ និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងដំណើរការសម្រេចផ្តល់សិទ្ធិ និងការអនុញ្ញាតដល់បណ្តាក្រុមហ៊ុនដែលបានស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ កំពង់ផែស្វយ័តភ្នំពេញ ត្រូវទទួលបានការអនុញ្ញាតពី ន.ម.ក និង ផ.ម.ក ដែលស្របតាមយន្តការ និងនីតិវិធីដែលបានចែងជាធរមាន។

លទ្ធផលនៃការស្រាវជ្រាវ បានបង្ហាញឱ្យឃើញថា កំពង់ផែស្វយ័តភ្នំពេញ បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងដំណើរបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ខ្លួន ដើម្បីក្លាយជាស្ថាប័នដែលមានលក្ខណៈគ្រប់គ្រាន់ និងមានការទទួលស្គាល់ពី និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។ ការទទួលបានជោគជ័យក្នុងការបោះជំហានចូលផ្សារមូលបត្រកម្ពុជារបស់កំពង់ផែស្វយ័តភ្នំពេញ បានយ៉ាងរលូន ក៏ព្រោះតែមានការគាំទ្រ និងជំនួយពីបណ្តាក្រុមហ៊ុនពាក់ព័ន្ធនានាដូចជា ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងក្រុមហ៊ុននានាទៀត ដែលចូលរួមក្នុងដំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ លើសពីនេះ ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិរបស់ កំពង់ផែស្វយ័តភ្នំពេញ សម្រាប់រយៈពេល ៤ ត្រីមាសក្នុងឆ្នាំ ២០២៣ គឺត្រីមាសទី ២ មានលក្ខណៈល្អប្រសើរជាងគេ បើធៀបនឹងត្រីមាសទី១ ត្រីមាសទី៣ និងត្រីមាសទី៤។ ថ្វីត្បិតតែ ចំនួនមូលធនូបនីយកម្ម មានការធ្លាក់ចុះ តែបើយើងសង្កេតមើល ទំហំជួញដូរ ទំហំជួញដូរមធ្យមប្រចាំថ្ងៃ តម្លៃជួញដូរ តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃនៅត្រីមាសទី២ មានការកើនឡើង។ លើសពីនេះទៅទៀតប្រសិនបើគម្រោងព្រែកជីកហ្វូណនតេជោ សម្រេចបានជោគជ័យតាមគម្រោងនៅឆ្នាំ២០២៨ ខាងមុខនេះ ការដឹកជញ្ជូនតាមផ្លូវទឹកនឹងមានការកើនឡើង និងជំរុញដល់ការអភិវឌ្ឍទីក្រុង នគរូបនីយកម្ម និងការជំរុញការរីកចម្រើនផ្នែកអចលនទ្រព្យជាច្រើនទៀត ដែលនឹងធ្វើឱ្យការជួញដូរមូលបត្ររបស់ ក.ស.ភ. កាន់តែមានការចាប់អារម្មណ៍ច្រើនពីសំណាក់ រូបវន្តបុគ្គល និងនីតិបុគ្គល។

សរុបសេចក្តីមក យើងអាចធ្វើការសន្និដ្ឋានជារួមបានថា ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ ក.ស.ភ. ពិតជាតម្រូវឱ្យស្ថាប័នមានការត្រៀមខ្លួនជាច្រើនដំណាក់កាល និងចំណាយពេលវេលា និងថវិកាជាច្រើន តែលទ្ធផលសម្រេចបានគឺទទួលបានមូលធនយកទៅប្រើប្រាស់ ដើម្បីអភិវឌ្ឍគម្រោងនានា និងធ្វើជាទុនបង្វិល។ ការបង្ហាញខ្លួនលើទីផ្សារមូលបត្រកម្ពុជា កំពង់ផែស្វយ័តភ្នំពេញ បានបង្ហាញឱ្យ

ឃើញពីសក្តានុភាពរបស់ខ្លួន លើសពីនេះ ក.ស.ភ. ក៏មានផែនការអភិវឌ្ឍន៍ខ្លួនបន្តទៀត ដើម្បីពង្រីកវិសាលភាពរបស់ខ្លួន និងចូលរួមអភិវឌ្ឍន៍វិស័យមូលបត្រផងដែរ។

## ២. ការផ្តល់អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ យើងខ្ញុំយល់ឃើញថា ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ គឺទទួលបាននូវភាពជោគជ័យស្របទៅតាមការរំពឹងទុករបស់ខ្លួន ប៉ុន្តែនៅមានចំណុចខ្វះខាតមួយចំនួន។ នៅក្នុងចំណុចនេះ យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវមតិយោបល់មួយចំនួនដែលយើងខ្ញុំយល់ឃើញថា វាអាចនឹងមានប្រយោជន៍សម្រាប់ការកែលម្អ និងជំរុញមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញ ឱ្យកាន់តែមានប្រជាប្រិយភាព។ មតិយោបល់របស់យើងខ្ញុំមានដូចខាងក្រោម៖

- **គួរជំរុញឱ្យមានការផ្សព្វផ្សាយកាន់តែទូលំទូលាយ៖** ផ្សព្វផ្សាយសក្តានុពលរបស់ភាគហ៊ុនខ្លួនដើម្បីទាក់ទាញវិនិយោគិនថ្មីៗ ជាពិសេសនីតិបុគ្គល អាចជួយក្នុងការធ្វើអោយមូលបត្រកម្មសិទ្ធិរបស់កំពង់ផែស្វយ័តភ្នំពេញកាន់តែមានតម្លៃនៅលើទីផ្សារ។ លើសពីនេះ ក៏គួរតែបង្កើនការផ្សព្វផ្សាយពីសកម្មភាពអាជីវកម្មរបស់ខ្លួន ប្រតិបត្តិការអាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុដែលមានតម្លាភាព ជូនដល់សាធារណៈជនទូទៅ ក៏ដូចជាអ្នកវិនិយោគដែលមានចំណាប់អារម្មណ៍ក្នុងការវិនិយោគលើភាគហ៊ុនរបស់ក្រុមហ៊ុននៅផ្សារមូលបត្រកម្ពុជា។
- **ការរួមចំណែកក្នុងសហគមន៍៖** បង្កើនការចូលរួមជាមួយសហគមន៍ និងអាជីវកម្មក្នុងតំបន់ដើម្បីបង្កើនភាពជាដៃគូរ។
- **ការពង្រឹងការប្រកួតប្រជែង៖** ការបង្កើនសមត្ថភាពក្នុងការប្រកួតប្រជែងជាមួយកំពង់ផែផ្សេងៗ អាចជួយបង្កើនភាពទាក់ទាញដល់វិនិយោគិន និងការរីកចម្រើនរបស់កំពង់ផែ។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ ប្រកាស និងគោលការណ៍ណែនាំ

- ច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រកម/០១០៧/០២៨ ២៣ តុលា ២០០៧
- ប្រកាស លេខ ០០៥/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ប្រកាសលេខ ០០១ គ.ម.ក ចុះថ្ងៃទី ១៥ មករា ២០១០ ស្តីពីការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជំពូកទី ៣ ប្រការ ៣៧
- ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- អនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ ស្តីពីការបង្កើតមណ្ឌលអាជីវកម្មផែភ្នំពេញ
- អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- គណៈកម្មការមូលបត្រកម្ពុជា សេចក្តីជូនដំណឹង លេខ០០៧/២១ គ.ម.ក./ស.ជ.ណ. ពីការផ្លាស់ប្តូរឈ្មោះរបស់ គណៈកម្មការមូលបត្រកម្ពុជា ទៅជា និយ័តករមូលបត្រកម្ពុជា ថ្ងៃទី០២ ខែមីនា ឆ្នាំ ២០២១
- គោលការណ៍ណែនាំ លេខ០០១ គ.ម.ក / គ.ណ.ន ចុះថ្ងៃទី ០៨ ខែកញ្ញា ២០១១ ស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូង
- អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងភ្នំពេញក.ស.ភ

## សៀវភៅ

- បៀន សាំង ២០១១ មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ហេង ច័ន្ទបូលីន (២០២៣-២០២៤) ទីផ្សារមូលបត្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## ឯកសារយោង


- ឯកសារផ្តល់ព័ត៌មានសម្រាប់ការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ របស់កំពង់ផែស្វយ័តភ្នំពេញ https://csx.com.kh/data/ipo/viewPost.do?MNCD=5020&postId=89
- កំពង់ផែស្វយ័តភ្នំពេញរបាយការណ៍ប្រចាំឆ្នាំ ២០២៣ https://csx.com.kh/company/annualreportppap/viewPost.do?MNCD=50803&postId=42
- ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រប្រចាំត្រីមាស ឆ្នាំ២០២៣ និយ័តករមូលបត្រកម្ពុជា - ន.ម.ក. (serc.gov.kh)
- និយមន័យទីផ្សារគោល និងទីផ្សារកំណើន https://bizkhmer.com/articles/59199
- ផ្សារមូលបត្រកម្ពុជា គឺជាជម្រើសថ្មីនៃប្រភពទុនសម្រាប់ SME ភ្នំពេញ ប៉ុស្ដិ៍ | ផ្សារមូលបត្រកម្ពុជា គឺជាជម្រើសថ្មីនៃប្រភពទុនសម្រាប់ SME (postkhmer.com)
- ប្រវត្តិផ្សារមូលបត្រកម្ពុជា (ផ.ម.ក.). https://csx.com.kh
- ទីផ្សារដំបូង និងទីផ្សារបន្ទាប់នៅក្នុងទីផ្សារមូលបត្រ ភ្នំពេញ ប៉ុស្ដិ៍ | ទីផ្សារដំបូង និងទីផ្សារបន្ទាប់នៅក្នុងទីផ្សារមូលបត្រ (postkhmer.com)
- ស្វែងយល់អំពីមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល. https://economy.ams.com.kh
- កំពង់ផែស្វយ័តក្រុងភ្នំពេញ ចាប់ផ្តើមដំណើរការបោះ IPO រំពឹងប្រមូលទុនបានពីជាង$៤លានដល់ជាង$៦លាន. http://m.freshnewsasia.com/index.php/en/11420-2015-10-19-10-47-11.html
- បញ្ជីឈ្មោះក្រុមហ៊ុនអន្តរការីទីផ្សារ. និយ័តករមូលបត្រកម្ពុជា - ន.ម.ក. (serc.gov.kh)
- តើផ្សារមូលបត្រជាអ្វី? khemsaritheducation (wordpress.com)
- The Evolution of Stock Exchanges. Investopedia. https://www.investopedia.com/articles/07/stock-exchange-history.asp

# ឧបសម្ព័ន្ធ

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ឯកសារផ្តល់ព័ត៌មានរបស់កំពង់ផែស្វយ័តភ្នំពេញ

ឧបសម្ព័ន្ធទី២៖ របាយការណ៍ប្រចាំឆ្នាំ២០២៣ របស់កំពង់ផែស្វយ័តភ្នំពេញ

ឧបសម្ព័ន្ធទី៣៖ ព្រឹត្តិបត្រទិន្នន័យជួញដូរមូលបត្រប្រចាំត្រីមាស ឆ្នាំ២០២៣ របស់កំពង់ផែស្វយ័តភ្នំពេញ

# ឧបសម្ព័ន្ធទី១៖
# ឯកសារផ្តល់ព័ត៌មានរបស់
# កំពង់ផែស្វយ័តភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



PHNOM PENH AUTONOMOUS PORT



# ឯកសារផ្តល់ព័ត៌មាន សម្រាប់ការបោះផ្សាយលក់ មូលបត្រកម្មសិទ្ធិលើកដំបូង ជាសាធារណៈ







ក្រុមហ៊ុនធានាទិញមូលបត្រ

យាន់តា ស៊ីគ្យួរីធី (ខេមបូឌា) ភីអិលស៊ី
Yuanta Securities (Cambodia) Plc

ខ-៥- ផែនការអនាគត

<u>គម្រោងអភិវឌ្ឍរយៈពេលខ្លីរបស់ ក.ស.ភ (២០១៦-២០១៨)</u>

ខាងក្រោម គឺជាគម្រោងអនាគតដែលមានតម្លៃវិនិយោគលើសពី ១០០.០០០ ដុល្លារអាមេរិក ដែលនឹងត្រូវវិនិយោគក្នុងរយៈ ១ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ។

១. គម្រោងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទីពីររបស់ចំណតផែ LM ១៧

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី ២ |
|---|---|
| បរិយាយ | ចន្លោះពី ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៤ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ២១,០៥% រៀងរាល់ឆ្នាំ។ ដោយសារតែ កុងតឺន័រដែលឆ្លងកាត់បច្ចុប្បន្ននៅ LM១៧ មានចំនួន ១៣៣.៦៦៦ TEUs ក្នុងឆ្នាំ២០១៤ ក.ស.ភ ព្យាករជាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ១៥០.០០០ TEUs ក្នុងឆ្នាំ២០១៦។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ ត្រូវធ្វើការពង្រីកបរិវេណផែ និងបរិក្ខារបន្ថែមទៀត |
| ដំណាក់កាលទី ១ នៃដំណាក់កាលទី២ ពីឆ្នាំ (២០១៦-២០១៧) | |
| គោលបំណង | ធានាសមត្ថភាពលើកដាក់របស់ផែក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រ LM១៧ ដល់កម្រិត ២៣០.០០០ TEUs ក្នុងមួយឆ្នាំ |
| ទីតាំងគម្រោង | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| ទំហំនៃគម្រោង | ៥ ហិកតា |
| ភ្នាក់ងារអនុវត្តគម្រោង | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) |
| ថវិកាត្រូវចំណាយ | - ពង្រីកទីលានកុងតឺន័រវិមាត្រសរុប (១៧.៤៥០ ម៉ែត្រការ៉េ) ដោយចាក់ថ្មម៉ិច៖ ៥៥៥.៨០០ ដុល្លារ<br>- សាងសង់ផ្លូវសម្រាប់រថស្ទូច RTG ចំនួន ០២ ខ្សែ (ប្រវែង ៨៩៨ ម៉ែត្រ)៖ ៨៣៨.៥៦៥ ដុល្លារ<br>- សាងសង់ផ្លូវសម្រាប់រថយន្តកុងតឺន័រ ចំនួន ០២ ខ្សែ (ប្រវែង ២៧២ម៉ែត្រ)៖ ៣៥៨.៣៨០ ដុល្លារ<br>- បំពាក់រថស្ទូច RTG ចំនួន ០២ គ្រឿង៖ ២.៦០០.០០០ ដុល្លារ<br>- បំពាក់ផងយោង TCC ចំនួន ០១ គ្រឿង៖ ១.៤២៥.០០០ដុល្លារ<br>- សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនី៖ ៧៥៨.០០០ ដុល្លារ<br>- សាងសង់ទំនប់ (៣០០ម x ៣១ ម)៖ ១.៧៥៨.៨៥៨ ដុល្លារ<br>- សាងសង់របង (៧៥០ ម)៖ ៧៩.៨២៨ ដុល្លារ |
| ប្រភពមូលធន | - មូលធនពីការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ<br>- មូលនិធិបម្រុងរបស់ ក.ស.ភ |
| រយៈពេលអនុវត្តគម្រោង | ២០១៦-២០១៧ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) |

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី ២ |
|---|---|
| បញ្ហាសង្គម | ការអនុវត្តគម្រោងដំណាក់កាលទី២នៃចំណតផែកុងតឺន័រ LM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| ការតាមដានសកម្មភាព | បង្កើតក្រុមការងារមួយដើម្បីតាមដានការអនុវត្តគម្រោង |
| **ជំហានទី ២ នៃដំណាក់កាលទី ២ នៅឆ្នាំ២០១៨** | |
| គោលបំណង | ធានាថាកំពង់ផែមានសមត្ថភាពទទួលកុងតឺន័រដែលកើនឡើងជារៀងរាល់ឆ្នាំ |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រ LM១៧ ដល់កម្រិត ៣០០.០០០ TEUs ក្នុងមួយឆ្នាំ |
| ទីតាំងគម្រោង | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| ភ្នាក់ងារអនុវត្តគម្រោង | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) |
| ថវិកាត្រូវចំណាយ | - ពង្រីកទីលានកុងតឺន័របរិមាត្រសរុប (១៧.៨៥០ ម៉ែត្រការ៉េ) ដោយចាក់ថ្មម៉ិច ៩៥៥.៥០០ ដុល្លារ<br>- សាងសង់ផ្លូវសម្រាប់រថស្ទូច RTG ចំនួន ០២ ខ្សែ (ប្រវែង ៥៥៨ ម៉ែត្រ)៖ ៤៣៨.៥៦៥ ដុល្លារ<br>- សាងសង់ផ្លូវសម្រាប់រថយន្តកុងតឺន័រ ចំនួន ០២ ខ្សែ (ប្រវែង ២៧២ម៉ែត្រ)៖ ៣៨៥.៣៩០ ដុល្លារ<br>- បំពាក់រថស្ទូច RTG ចំនួន ០២ គ្រឿង៖ ២.៤០០.០០០ ដុល្លារ |
| ប្រភពមូលធន | - មូលធនពីការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ<br>- មូលនិធិបម្រុង ក.ស.ភ |
| រយៈពេលអនុវត្តគម្រោង | ២០១៨ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ) |
| បញ្ហាសង្គម | ការអនុវត្តគម្រោងដំណាក់កាលទី២នៃចំណតផែកុងតឺន័រ LM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយថា នឹងមានផលប៉ះពាល់ដល់បរិស្ថានទេ |
| ការតាមដានសកម្មភាព | បង្កើតក្រុមការងារមួយដើម្បីតាមដានការអនុវត្តគម្រោង |

# ឧបសម្ព័ន្ធទី២៖
# របាយការណ៍ប្រចាំឆ្នាំ ២០២៣
# របស់កំពង់ផែស្វយ័តភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



# កំពង់ផែស្វយ័តភ្នំពេញ
## របាយការណ៍ប្រចាំឆ្នាំ២០២៣

ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប កម្មសិទ្ធិភាពភាគហ៊ុនិកធម្មតា និងស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលប្រតិបត្តិការ

### ១.១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| បរិយាយ | | ៣១ ធ្នូ ឆ្នាំ២០២៣ | ៣១ ធ្នូ (*) ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) | ០១ មករា (*) ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) |
|---|---|---|---|---|
| ស្ថានភាពហិរញ្ញវត្ថុ (ពាន់រៀល) | | | | |
| ទ្រព្យសកម្មសរុប | | ១.០៤០.៨៨៣.៥៣៣ | ១.០១០.៩០៨.០៨៥ | ៨៩៩.១៣០.២២០ |
| បំណុលសរុប | | ២៤៤.១២៣.១៤៣ | ២៤១.២១៦.៤៥៦ | ១៩៣.២០២.៤៣៨ |
| មូលធនសរុប | | ៧៩៦.៧៦០.៣៩០ | ៧៦៩.៦៩១.៦២៩ | ៧០៥.៩២៧.៧៨២ |
| លទ្ធផលហិរញ្ញវត្ថុ (ពាន់រៀល) | | ឆ្នាំ២០២៣ | ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) | ឆ្នាំ២០២១ |
| ចំណូលសរុប | | ១៤២.០៣៥.៤៨០ | ១៤៨.៨១៥.៥៦៧ | ១២៥.២២៨.១៥២ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | | ៥០.១១៩.១៣២ | ៧៤.៨១២.២៧៤ | ៦៣.៩១៧.៧៩១ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | | ៣៨.៦០៥.៩៦៦ | ៥៩.២៩៣.៦៩០ | ៥១.៦៩៥.៤៥៧ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | | ៣១.៧៣២.៧២៦ | ៦៨.១៥៧.៩០០ | ៥១.៦០៩.៨៩១ |
| អនុបាតហិរញ្ញវត្ថុ | | ៣១ ធ្នូ ឆ្នាំ២០២៣ | ៣១ ធ្នូ (*) ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) | ០១ មករា (*) ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) |
| អនុបាតសាធនភាព (ភាគរយ) | | ២៣,៥៥% | ៣១,១៧% | ៣៤,៣០% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត (ចំនួនដង) | ១,៤៤ | ១,៨៥ | ១,៨៨ |
| | អនុបាតចរន្តលឿន (ចំនួនដង) | ១,៣៥ | ១,៧៧ | ១,៨៣ |
| | | ឆ្នាំ២០២៣ | ឆ្នាំ២០២២ (បានធ្វើរបាយការណ៍ឡើងវិញ) | ឆ្នាំ២០២១ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ៣,៧១ | ៥,៨៧ | ៥,៧៤ |
| | អនុបាតចំណេញធៀបនឹងមូលធន (ភាគរយ) | ៤,៨៥ | ៧,៧០ | ៧,៣១ |
| | អនុបាតគម្លាតចំណេញដុល (ភាគរយ) | ៦២,១៤ | ៦៥,៨២ | ៦៨,១៣ |
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ២៧,១៨ | ៣៩,៨៤ | ៤១,២៨ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១.៨៦៦,៤៣ | ២.៨៦៦,៥៩ | ២.៤៩៩,២៥ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ១៧,៤៥ | ២៣,៣៤ | ១៩,៣០ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | | - | ២២៣,៨៣ | ២១១,៦០ |

## ១.៣. កម្មសិទ្ធិភាព ភាគហ៊ុនិកធម្មតា (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣)

| ភាគហ៊ុន | ចំនួនភាគហ៊ុន | កម្មសិទ្ធិភាព |
|---|---|---|
| ភាគហ៊ុនប្រភេទ ("គ") | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | ៩៣.៧៦៩.១២០ | ១០០% |
| ភាគហ៊ុនធម្មតាប្រភេទ ("ខ") | | |
| ១. រដ្ឋ តំណាងដោយ (ស.ហ.វ.) | ១៦.៥៤៧.៤៥២ | ៨០% |
| ភាគហ៊ុនធម្មតាប្រភេទ ("ក") | | |
| ១. ESOP | ២៣៤.៤៥៣ | ១,១៣% |
| ២. ភាគហ៊ុនិកឯកជន | ៣.៩០២.៤២០ | ១៨,៨៧% |
| សរុបភាគហ៊ុនធម្មតាប្រភេទ ("ក") | ៤.១៣៦.៨៧៣ | ២០% |

** ភាគហ៊ុនធម្មតាប្រភេទ ("ក") និង ("ខ") សរុបចំនួន ២០.៦៨៤.៣២៥ ភាគហ៊ុន។*




តម្លៃជួញដូរភាគហ៊ុនជាមធ្យម (គិតជារៀល)
និងបរិមាណជួញដូរជាមធ្យម (ភាគហ៊ុន) នៃភាគហ៊ុនប្រភេទ "ក"
សម្រាប់ឆ្នាំ២០២៣
២៨០០
២៤០០
២០០០
១៦០០
១២០០
៨០០
៤០០
១៦០០០
១៤០០០
១២០០០
១០០០០
៨០០០
៦០០០
៤០០០
២០០០
០
១៥.១៤០
២.៦៤២
១៥.០៥២
១៤.៥៥០
១៤.២៤៥
១៤.១០៥
១៤.០៦២
១៣.៨២០
១.២០៩
៦៥៣
៤៨៨
២៤៨
២៤៤
៤៩៤
១៥៨
២០២
១៥៥
២២៥
១៩១
មករា
កុម្ភៈ
មីនា
មេសា
ឧសភា
មិថុនា
កក្កដា
សីហា
កញ្ញា
តុលា
វិច្ឆិកា
ធ្នូ
បរិមាណជួញដូរជាមធ្យម (ភាគហ៊ុន)
តម្លៃជួញដូរជាមធ្យម (រៀល)

## ១.៤. ស្ថិតិប្រចាំឆ្នាំសន្ទេបពីលទ្ធផលប្រតិបត្តិការ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣)

### ស្ថិតិនាវាដឹកទំនិញឆ្លងកាត់ ក. ស. ភ.

ឯកតា (គ្រឿង)

| បរិយាយ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|
| នាវា-សាឡាង់អន្តរជាតិ | ៣ ៣៨០ | ៣ ២៨៧ | ១ ៧៧០ |
| នាវាប្រេង | ៤៧៩ | ៤៥៦ | ៥៣២ |
| នាវាកម្ពុជា | ០ | ០ | ០ |
| សាឡាង់កម្ពុជា | ០ | ០ | ០ |
| សរុប | ៣ ៨៥៩ | ៣ ៧៤៣ | ២ ៣០២ |

### ស្ថិតិកុងតឺន័រឆ្លងកាត់ ក. ស. ភ.

ឯកតា (TEUs)

| បរិយាយ | | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| នាំចូល | គ្មានទំនិញ | ១៣១ ៤៧៥ | ១២៩ ៦៦២ | ៩៣ ២៧៣ |
| | មានទំនិញ | ៥៤ ៦៥២ | ៦៣ ១១៥ | ៦៩ ៩៤០ |
| សរុបនាំចូល | | ១៨៦ ១២៧ | ១៩២ ៧៧៧ | ១៦៣ ២១៣ |
| នាំចេញ | គ្មានទំនិញ | ១៣ ៧៨៤ | ១៥ ៦២៤ | ១៤ ៦៣៧ |
| | មានទំនិញ | ១៩៦ ៣១៤ | ២០៩ ២៩៥ | ១៧១ ០៤៨ |
| សរុបនាំចេញ | | ២១០ ០៩៨ | ២២៤ ៩១៩ | ១៨៥ ៦៨៥ |
| សរុប | | ៣៩៦ ២២៥ | ៤១៧ ៦៩៦ | ៣៤៨ ៨៩៨ |

### ស្ថិតិនាវាទេសចរណ៍អន្តរជាតិឆ្លងកាត់ ក. ស. ភ.

ឯកតា (គ្រឿង)

| បរិយាយ | | ឆ្នាំ២០២៣ | ឆ្នាំ២០២២ | ឆ្នាំ២០២១ |
|---|---|---|---|---|
| នាវាទេសចរណ៍អន្តរជាតិ | អ្នកដំណើរ (នាក់) | ២៥ ១៥២ | ៦ ៩៤៧ | ០ |
| | នាវា (គ្រឿង) | ៤៧៦ | ២០៦ | ០ |

## ខ. ស្ថានភាពទីផ្សារ

នៅក្នុងឆ្នាំ ២០២៣ នេះ ស្ថានភាពទីផ្សាររបស់ ក. ស. ក. ហាក់ដូចជាពុំមានសភាពចូរស្មើយជាងឆ្នាំមុននោះទេ ដោយហេតុថាវិបត្តិសង្គ្រាម និងភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចសកល បានជះឥទ្ធិពលទៅលើគ្រប់វិស័យក៏ដូចជាវិស័យដឹកជញ្ជូនក្នុងប្រទេសកម្ពុជាផងដែរ។ ចំពោះទីផ្សារសំខាន់របស់ ក. ស. ក. គឺពឹងផ្អែកទៅលើកំណើននៃវិស័យអចលនទ្រព្យ និងទេសចរណ៍ក្នុងប្រទេស និងការបញ្ជាទិញទំនិញវាយនភណ្ឌពីក្រៅប្រទេស ជាពិសេសសហរដ្ឋអាមេរិក។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២៣ នេះ វិស័យអចលនទ្រព្យ និងវិស័យវាយនភណ្ឌហាក់ នៅតែបន្តមានភាពមិនច្បាស់លាស់ ដែលបណ្តាលឲ្យទីផ្សាររបស់ ក. ស. ក. មានការថយចុះចំនួន ៥,១៤% បើធៀបទៅនឹងឆ្នាំ ២០២២។

សម្រាប់ឆ្នាំ២០២៣ ការនាំចូលទំនិញ ជាវត្ថុធាតុដើមវាយនភណ្ឌមានចំនួន ៣% បើធៀបទៅនឹងការនាំចូលសរុប តែបើធៀបទៅនឹងឆ្នាំ២០២២ វិញ មានការថយចុះចំនួន ៦%។ ចំណែកឯការនាំចេញវិញ ទំនិញវាយនភណ្ឌកាត់ដេរនៅតែបន្តឈានមុខគេគឺ ៦៥% បើធៀបទៅនឹងការនាំចេញសរុប ប៉ុន្តែបើធៀបទៅនឹងឆ្នាំ២០២២ មានការថយចុះ ៩%។ *(យោងតាមក្រាហ្វិក លេខ១ លេខ២ លេខ៣ និងលេខ៤ របស់នាយកដ្ឋានផែនការ/ទីផ្សារ)*។

ការនាំចូលទំនិញតាមចំណតផែរបស់ ក. ស. ក. សម្រាប់ឆ្នាំ២០២៣ ពីក្រៅប្រទេស គឺមានប្រទេសវៀតណាមមានការថយចុះ ៧% ប៉ុន្តែការនាំចូលពីប្រទេសម៉ាឡេស៊ីថយចុះ ១៩% ប្រទេសជប៉ុនកើនឡើង ១៨% សហភាពអឺរ៉ុបថយចុះ ២៩% និងប្រទេសចិនថយចុះ ៧% បើធៀបទៅនឹងឆ្នាំ២០២២។ ដោយឡែក សម្រាប់ការនាំចេញវិញគឺការនាំចេញទៅប្រទេសចិនមានការថយចុះ ១៤% ប្រទេសជប៉ុនកើនឡើង ៧% សហរដ្ឋអាមេរិកថយចុះ ២% និងប្រទេសវៀតណាមកើនឡើង ៧៩% បើធៀបទៅនឹងឆ្នាំ២០២២។

*ក្រាហ្វិកលេខ១*

**ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ក. ប្រចាំឆ្នាំ២០២៣ ធៀបនឹងឆ្នាំ២០២២ គិតជា**
( TEUs )




*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២៣ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ក.*

## ក្រាហ្វិកលេខ២

**ស្ថិតិកុងតឺន័រនាំចូល-នាំចេញតាមច្រក ក. ស. ត. ប្រចាំឆ្នាំ២០២៣ គិតជា (TEUs)**







*(ប្រភព: ទិន្នន័យប្រចាំឆ្នាំ ២០២៣ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ក.)*

## ក្រាហ្វិកលេខ៣

**ស្ថិតិទំនិញនាំចូលតាមច្រក ក.ស.ត. ប្រចាំឆ្នាំ២០២៣ ធៀបនឹងឆ្នាំ២០២២ គិតជា ( TEUs )**




| | គ្រឿងសំណង់ | សម្ភារប្រើប្រាស់ក្នុងផ្ទះ | វត្ថុធាតុដើមវាយនភណ្ឌ | ម្ហូបអាហារ និងភេសជ្ជៈ | ផ្សេងៗ |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០២២ | ២៨៣៦០ | ៦៨៣៥ | ៦៣២៤ | ៧២៥៣ | ១៤៦០៣ |
| ប្រចាំឆ្នាំ ២០២៣ | ២៣៣៣៨ | ៦៤៧៦ | ៥៩២២ | ៥២៥៣ | ១៣៦៦៦ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២២និងប្រចាំឆ្នាំ២០២៣ | -១៨% | -៤% | -៦% | -២៨% | -៦% |

*(ប្រភព: ទិន្នន័យប្រចាំឆ្នាំ ២០២៣ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ក.)*

## ក្រាហ្វិកលេខ៤

### ស្ថិតិទំនិញនាំចេញតាមប្រភេទ ក.ស.ក. ប្រចាំឆ្នាំ២០២៣ ធៀបនឹងឆ្នាំ២០២២ គិតជា ( TEUs )




| | វាយនភណ្ឌ | ផលិតផល អគ្គីសនី | សម្ភារៈ សំណង់ | អង្ករ | ផ្សេងៗ |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០២២ | ១៥៨៤០៧ | ២០១៨៥ | ១៣៦៧៥ | ៤៤០៦ | ១៦៦១៨ |
| ប្រចាំឆ្នាំ ២០២៣ | ១២៨៤៨៥ | ៤១៧១០ | ១០៤៧៨ | ១៧៦៣ | ១៣៨៧១ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២២និងប្រចាំឆ្នាំ២០២៣ | -១៩% | ១០៧% | -២៣% | -៦០% | -១៧% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ ២០២៣ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក.ស.ក.)*

## ក្រាហ្វិកលេខ៥

### ចំណែកទីផ្សារនាំចូលទំនិញតាមប្រភេទ ក. ស. ក. ប្រចាំឆ្នាំ២០២៣ ធៀបនឹងឆ្នាំ២០២២ គិតជា ( TEUs )




| | ប្រទេសចិន | ប្រទេស វៀតណាម | ប្រទេស ម៉ាឡេស៊ី | ប្រទេសជប៉ុន | ផ្សេងៗ |
|---|---|---|---|---|---|
| ប្រចាំឆ្នាំ ២០២២ | ៣២៨៤៧ | ៩០៧៤ | ២៣៥២ | ៧៥៤ | ១៨០៤៨ |
| ប្រចាំឆ្នាំ ២០២៣ | ៣០១៣២ | ៨៤២៨ | ១៧៥៥ | ៩០៩ | ១៣៣៨៨ |
| អត្រាប្រែប្រួលជាភាគរយ ប្រចាំឆ្នាំ២០២២ និងប្រចាំឆ្នាំ២០២៣ | -៨% | -៧% | -២៥% | ២១% | -២៦% |

*(ប្រភព៖ ទិន្នន័យប្រចាំឆ្នាំ២០២៣ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ក.)*

ក្រាហ្វិកលេខ៦




*(ប្រភពៈ ទិន្នន័យប្រចាំឆ្នាំ២០២៣ និងប្រចាំឆ្នាំ២០២២ របស់នាយកដ្ឋានផែនការ/ទីផ្សារ ក. ស. ក.)*

# ឧបសម្ព័ន្ធទី៣៖
# ព្រឹត្តិបត្រទិន្នន័យជួញដូរ
# មូលបត្រប្រចាំត្រីមាស
# ឆ្នាំ២០២៣របស់
# កំពង់ផែស្វយ័តភ្នំពេញ

## ២.១.៤- សកម្មភាពជួញដូរភាគហ៊ុនរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ/2.1.4.- Trading Information of Equity Listed Companies

### ២.១.៤.៣- កំពង់ផែស្វយ័តភ្នំពេញ / 2.1.4.3.-Phnom Penh Autonomous Port (PPAP)

*តារាង 5: ទិដ្ឋភាពទូទៅនៃការជួញដូរភាគហ៊ុន PPAP/Table 5: Trading Overview of PPAP*

| ទិដ្ឋភាពទូទៅ Overview | ត្រីមាសទី២ ២០២៣ Q2 2023 | ត្រីមាសទី១ ២០២៣ Q1 2023 | បម្រែបម្រួលត្រី.២ ២០២៣ធៀបនឹង Change Compare to | |
|---|---|---|---|---|
| | | | ត្រី.១ ២០២៣ Q1 2023 | ត្រី.ទី២ ២០២២ Q2 2022 |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) / Market Cap. (Mil. KHR) | **296,200.11** | 306,128.60 | -3.24% | -6.41% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក)/ Market Cap. (Mil. USD) | **71.72** | 75.51 | | |
| ទំហំជួញដូរ (ភាគហ៊ុន) / Trading Volume (Shares) | **62,914** | 50,377 | 24.89% | -5.33% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) / Average Daily Trading Volume (Shares) | **1,031** | 787 | 31.03% | -5.33% |
| តម្លៃជួញដូរ (លានរៀល)/ Trading Value (Mil. KHR) | **855.86** | 741.03 | 15.50% | -18.23% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) / Trading Value (USD) | **207,229.51** | 182,788.76 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល)/ Average Daily Trading Value (Mil. KHR) | **14.03** | 11.58 | 21.18% | -18.23% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) / Average Daily Trading Value (USD) | **3,397.21** | 2,856.07 | | |

| ទិដ្ឋភាពទូទៅ Overview | ត្រីមាសទី៣ ២០២៣ Q3 2023 | ត្រីមាសទី២ ២០២៣ Q2 2023 | បម្រែបម្រួលត្រី.៣ ២០២៣ធៀបនឹង Change Compare to | |
|---|---|---|---|---|
| | | | ត្រី.២ ២០២៣ Q2 2023 | ត្រី.៣ ២០២២ Q3 2022 |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) / Market Cap. (Mil. KHR) | **291,235.86** | 296,200.11 | -1.68% | -2.22% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក)/ Market Cap. (Mil. USD) | **70.65** | 71.72 | | |
| ទំហំជួញដូរ (ភាគហ៊ុន) / Trading Volume (Shares) | **17,739** | 62,914 | -71.80% | -97.20% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) / Average Daily Trading Volume (Shares) | **277** | 1,031 | -73.13% | -97.15% |
| តម្លៃជួញដូរ (លានរៀល)/ Trading Value (Mil. KHR) | **249.71** | 855.86 | -70.82% | -97.40% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក) / Trading Value (USD) | **60,578.91** | 207,229.51 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល)/ Average Daily Trading Value (Mil. KHR) | **3.90** | 14.03 | -72.19% | -97.35% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) / Average Daily Trading Value (USD) | **946.55** | 3,397.21 | | |

| ទិដ្ឋភាពទូទៅនៃទីផ្សារ Overview | ត្រីមាសទី៤ ២០២៣ Q4 2023 | ត្រីមាសទី៣ ២០២៣ Q3 2023 | បម្រែបម្រួលត្រី.៤ ២០២៣ ធៀបនឹង Changes compare to | |
|---|---|---|---|---|
| | | | ត្រី.ទី៣ ២០២៣ Q3 2023 | ត្រី.ទី៤ ២០២២ Q4 2022 |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល)/ Market Cap. (Mil. KHR) | 289,581 | 291,235.86 | -0.57% | 0.00% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក)/ Market Cap. (Mil.USD) | 71 | 70.65 | | |
| ទំហំជួញដូរ (ភាគហ៊ុន)/ Trading Volume (Shares) | 11,558 | 17,739 | -34.84% | -39.83% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន)/ Daily Average of Trading Volume (Shares) | 189 | 277 | -31.64% | -38.85% |
| តម្លៃជួញដូរ (លានរៀល)/ Trading Value (Mil. KHR) | 159.66 | 249.71 | -36.06% | -40.93% |
| តម្លៃជួញដូរ (ដុល្លារអាមេរិក)/ Trading Value (USD) | 39,084.03 | 60,578.91 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល)/ Daily Average of Trading Value (Mil. KHR) | 2.62 | 3.90 | -32.92% | -39.96% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក)/ Daily Average of Trading Value (USD) | 640.72 | 946.55 | | |